ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២៦ លេខ០៨ ត្រីមាសទី០១ ឆ្នាំ២០២៦

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


| | | |
|---|---|---|
| ២០-១-២០២៦ | -ព្រះរាជក្រម នស/រកម/០១២៦/០០២ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុបនិងរដ្ឋសមាជិករបស់ខ្លួន | ៨៧៣ |


### ២~ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ១៣-១-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០១២៦/០៧៥ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់វរសេនីយ៍ឯក **អួច សុវណ្ណា** នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ | ៩៣៩ |
| ១៣-១-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០១២៦/០៧៦ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈ ដល់វរសេនីយ៍ត្រី **សុខ ផល** នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ដែលបានពលីជីវិតក្នុងបុព្វហេតុការពារបូរណភាពទឹកដី នៃការរំលោភឈ្លានពានពីបច្ចាមិត្ត | ៩៤០ |
| ១៣-១-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០១២៦/០៧៧ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈ ដល់វរសេនីយ៍ទោ **ឌុច ពោ** នាយទាហាន ថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ដែលបានពលីជីវិតក្នុងបុព្វហេតុការពារបូរណភាពទឹកដី នៃការរំលោភឈ្លានពានពីបច្ចាមិត្ត | ៩៤១ |
| ១៣-១-២០២៦ | -ព្រះរាជក្រឹត្យ នស/រកត/០១២៦/០៧៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ ឧត្តមសេនីយ៍ទោ **ចាន់ សម្បត្តិ** | ៩៤២ |


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


| | | |
|---|---|---|
| ៥-១-២០២៦ | -អនុក្រឹត្យលេខ ០២ អនក្រ.បក ស្តីពី ការផ្ទេរទ្រព្យសម្បត្តិរដ្ឋ | ៩៤៣ |
| ៥-១-២០២៦ | -អនុក្រឹត្យលេខ ២៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ *(តមកពីរាជកិច្ចលេខ ០៧)* | ៩៤៥ |

# ព្រះរាជក្រម

នស/រកម/០១២៦/ ០០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១២៣/០២០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុបនិងរដ្ឋសមាជិករបស់ខ្លួន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យនិងឯកភាពគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី៥ នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ ស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិ អាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុបនិងរដ្ឋសមាជិករបស់ខ្លួន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១ .-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុបនិងរដ្ឋសមាជិករបស់ខ្លួន ដែលព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខានៅក្រុងបាលីនៃសាធារណរដ្ឋឥណ្ឌូណេស៊ី កាលពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ។

**មាត្រា២ .-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ។

ថ្ងៃ អង្គារ ២ កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២០ ខែ មករា ឆ្នាំ២០២៦

ពរល. ២៦០១.១២៥

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល**

**ម៉ៅ ហាវណ្ណាល់**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**វង្សី វិស្សុត**

# កិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសហភាពអឺរ៉ុបនិងរដ្ឋសមាជិករបស់ខ្លួន

រដ្ឋាភិបាលនៃ៖
ព្រុយណេដារូសាឡឹម
ព្រះរាជាណាចក្រកម្ពុជា
សាធារណរដ្ឋឥណ្ឌូណេស៊ី
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
ម៉ាឡេស៊ី
សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា
សាធារណរដ្ឋហ្វីលីពីន
សាធារណរដ្ឋសិង្ហបុរី
ព្រះរាជាណាចក្រថៃ និង
សាធារណរដ្ឋសង្គមនិយមវៀតណាម

ក្នុងនាមបណ្តារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(«អាស៊ាន») (តទៅនេះហៅកាត់ជារួមថា «បណ្តារដ្ឋសមាជិកអាស៊ាន» និងហៅកាត់ដាច់ដោយឡែកថា «រដ្ឋសមាជិកអាស៊ាន»)។

និង

ព្រះរាជាណាចក្របែលហ្ស៊ិក
សាធារណរដ្ឋប៊ុលហ្គារី
សាធារណរដ្ឋឆែក
ព្រះរាជាណាចក្រដាណឺម៉ាក
សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់
សាធារណរដ្ឋអេស្តូនី
អៀរឡង់
សាធារណរដ្ឋហេឡេនិច
ព្រះរាជាណាចក្រអេស្ប៉ាញ
សាធារណរដ្ឋបារាំង

សាធារណរដ្ឋក្រូអាស៊ី
សាធារណរដ្ឋអ៊ីតាលី
សាធារណរដ្ឋស៊ីប
សាធារណរដ្ឋឡេតូនី
សាធារណរដ្ឋលីទុយអានី
ព្រះរាជាណាចក្រលុចសំបួ
ហុងគ្រី
សាធារណរដ្ឋម៉ាល់ត៍
ព្រះរាជាណាចក្រហូឡង់
សាធារណរដ្ឋអូទ្រីស
សាធារណរដ្ឋប៉ូឡូញ
សាធារណរដ្ឋព័រទុយហ្គាល់
រូម៉ានី
សាធារណរដ្ឋស្លូវេនី
សាធារណរដ្ឋស្លូវ៉ាគី
សាធារណរដ្ឋហ្វាំងឡង់ និង
ព្រះរាជាណាចក្រស៊ុយអែត

ក្នុងនាមបណ្តារដ្ឋភាគីនៃសន្ធិសញ្ញាស្តីពីសហភាពអឺរ៉ុប និងសន្ធិសញ្ញាស្តីពីការប្រព្រឹត្តទៅនៃសហភាពអឺរ៉ុប (តទៅនេះហៅថា «សន្ធិសញ្ញាសហភាពអឺរ៉ុប») និងក្នុងនាមជារដ្ឋសមាជិកនៃសហភាពអឺរ៉ុប (តទៅនេះហៅកាត់ជារួមថា «បណ្តារដ្ឋសមាជិកសហភាពអឺរ៉ុប» និងហៅកាត់ជាច់ដោយឡែកថា «រដ្ឋសមាជិកសហភាពអឺរ៉ុប»)។

និង

សហភាពអឺរ៉ុប (តទៅនេះហៅកាត់ថា «សហភាព» ឬ «សហភាពអឺរ៉ុប»)។

**ដោយមានបំណង** ដើម្បីលើកកម្ពស់អត្ថប្រយោជន៍របស់ខ្លួន ទាក់ទងនឹងការដឹកជញ្ជូនតាមផ្លូវអាកាស ជាមធ្យោបាយក្នុងការចូលរួមចំណែកដល់ទំនាក់ទំនងនយោបាយនិងសេដ្ឋកិច្ចឱ្យកាន់តែជិតស្និទ្ធរវាងតំបន់ទាំងពីរ។

**ដោយទទួលស្គាល់** សារៈសំខាន់នៃប្រសិទ្ធភាពការតភ្ជាប់ការដឹកជញ្ជូនតាមផ្លូវអាកាស ក្នុងការជំរុញវិស័យពាណិជ្ជកម្ម ទេសចរណ៍ វិនិយោគ និងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**ដោយមានបំណង** ដើម្បីលើកកម្ពស់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស និងជំរុញប្រព័ន្ធអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយឈរលើមូលដ្ឋានបរិយាកាសយុត្តិធម៌និងប្រកួតប្រជែង មិនមានការរើសអើង និងមានកាលានុវត្តភាព យុត្តិធម៌ និងស្មើភាពដល់ក្រុមហ៊ុនអាកាសចរណ៍ក្នុងការប្រកួតប្រជែង។

**ដោយមានបំណង** ដើម្បីធានាបាននូវកម្រិតសុវត្ថិភាពនិងសន្តិសុខខ្ពស់បំផុតក្នុងការដឹកជញ្ជូនតាមផ្លូវអាកាស និងបញ្ជាក់ការព្រួយបារម្ភយ៉ាងខ្លាំងរបស់ខ្លួនទាក់ទងនឹងសកម្មភាព ឬការគំរាមកំហែងដល់សន្តិសុខរបស់អាកាសយាន ដែលបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពមនុស្សឬទ្រព្យសម្បត្តិ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រតិបត្តិការរបស់អាកាសយាន និងបាត់បង់ទំនុកចិត្តលើការធ្វើដំណើរសាធារណៈលើសុវត្ថិភាពអាកាសចរណ៍ស៊ីវិល។

**ដោយកត់សម្គាល់ថា** បណ្តារដ្ឋសមាជិកអាស៊ាននិងបណ្តារដ្ឋសមាជិកសហភាពអឺរ៉ុប គឺជារដ្ឋភាគីនៃអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដែលបានចុះហត្ថលេខានៅក្រុងឈីកាហ្គោ នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៤៤។

**ដោយប្តេជ្ញា** បង្កើនអតិបរមាសក្តានុពលនៃសារប្រយោជន៍លើកិច្ចសហប្រតិបត្តិការនិយ័តកម្ម។

**ដោយទទួលស្គាល់** សារប្រយោជន៍សក្តានុពលសំខាន់ៗដែលអាចកើតឡើងពីការប្រកួតប្រជែងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស និងស្ថិរភាពឧស្សាហកម្មដឹកជញ្ជូនតាមផ្លូវអាកាស។

**ដោយមានបំណង** ដើម្បីលើកកម្ពស់កម្រិតទីលានប្រកួតប្រជែងរបស់ក្រុមហ៊ុនអាកាសចរណ៍ ទទួលស្គាល់សក្តានុពលសារប្រយោជន៍នៃការប្រកួតប្រជែងយុត្តិធម៌ និងការឧបត្ថម្ភធនមួយចំនួនអាចប៉ះពាល់ធ្ងន់ធ្ងរដល់ការប្រកួតប្រជែង និងបង្កគ្រោះថ្នាក់ដល់គោលបំណងមូលដ្ឋាននៃកិច្ចព្រមព្រៀងនេះ។

**ដោយមានបំណង** ដើម្បីកសាងលើក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងដែលមានស្រាប់ និងការព្រមព្រៀងនានារវាងរដ្ឋភាគី ក្នុងគោលបំណងបើកច្រកចូលទៅកាន់ទីផ្សារ និងបង្កើនអតិបរមាសារប្រយោជន៍ដល់អ្នកធ្វើដំណើរ ក្រុមហ៊ុនដឹកជញ្ជូន ក្រុមហ៊ុនអាកាសចរណ៍ និងអាកាសយានដ្ឋាន និងនិយោជិតរបស់ខ្លួន សហគមន៍របស់ខ្លួន និងអ្នកទទួលផលដទៃៗទៀត។

**ដោយបញ្ជាក់** សារៈសំខាន់នៃការការពារបរិស្ថានក្នុងការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយអាកាសចរណ៍អន្តរជាតិ។

**ដោយបញ្ជាក់** សេចក្តីត្រូវការនៃសកម្មភាពបន្ទាន់លើការដោះស្រាយបម្រែបម្រួលអាកាសធាតុ និងកិច្ចសហប្រតិបត្តិការបន្ត លើការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យអាកាសចរណ៍ ដោយស្របជាមួយកិច្ចព្រមព្រៀងពហុភាគីទាក់ទងបញ្ហានេះ រួមទាំងលិខិតូបករណ៍របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ (តទៅនេះហៅកាត់ថា «អាយស៊ីអេអូ-ICAO»)។

**ដោយបញ្ជាក់** សារៈសំខាន់នៃការការពារផលប្រយោជន៍អ្នកប្រើប្រាស់ រួមទាំងការការពារដែលផ្តល់ដោយអនុសញ្ញាស្តីពីឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាស ដែលបានធ្វើឡើងនៅក្រុងម៉ុងរ៉េអាល់នៃប្រទេសកាណាដា នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៩ សម្រេចបាននៃការការពារអ្នកប្រើប្រាស់ក្នុងកម្រិតខ្ពស់ និងការទទួលស្គាល់សេចក្តីត្រូវការនៃកិច្ចសហប្រតិបត្តិការ ទៅវិញទៅមកនៅក្នុងវិស័យនេះ។

**ដោយទទួលស្គាល់ថា** កាលានុវត្តភាពពាណិជ្ជកម្មមានការកើនឡើងដែលនឹងមិនមានបំណងធ្វើឱ្យប៉ះពាល់ដល់ការងារឬស្តង់ដាដែលពាក់ព័ន្ធការងាររបស់រដ្ឋភាគី និងបញ្ជាក់ឡើងវិញអំពីសារៈសំខាន់នៃការពិចារណាប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងនេះ ស្តីពីការងារ បំពេញការងារ និងលក្ខខណ្ឌការងារ និងសារប្រយោជន៍ដែលកើតមានឡើងនៅពេលទទួលផលសេដ្ឋកិច្ចសំខាន់ៗពីទីផ្សារបើកចំហនិងប្រកួតប្រជែង ដែលត្រូវបានរួមផ្សំជាមួយនឹងស្តង់ដាការងារខ្ពស់។

**ដោយកត់សម្គាល់** បំណងប្រាថ្នាស្វែងរកមធ្យោបាយដើម្បីសម្រួលការចូលទៅកាន់ទីផ្សារមូលធនកាន់តែប្រសើរ តាមរយៈឧស្សាហកម្មដឹកជញ្ជូនតាមផ្លូវអាកាសសម្រាប់ការអភិវឌ្ឍជាបន្តលើការដឹកជញ្ជូនតាមផ្លូវអាកាស និង

**ដោយមានបំណង** ដើម្បីសម្រេចកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស ដែលបន្ថែមទៅលើអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ បានចុះហត្ថលេខានៅក្រុងឈីកាហ្គោ នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៤៤។

**បានព្រមព្រៀងគ្នាដូចខាងក្រោម៖**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា១
## វិសាលភាព

១- កិច្ចព្រមព្រៀងនេះ អនុវត្តលើបទប្បញ្ញត្តិនៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសលើក្រុមហ៊ុនអាកាសចរណ៍របស់សហភាព ហោះហើរមកពី នៅក្នុង ឬទៅកាន់ដែនដីនៃបណ្តារដ្ឋសមាជិកអាស៊ាន និងលើក្រុមហ៊ុនអាកាសចរណ៍បណ្តារដ្ឋសមាជិកអាស៊ាន ហោះហើរមកពី នៅក្នុង ឬទៅកាន់ដែនដីនៃសហភាព រួមទាំងបទប្បញ្ញត្តិនៃសេវាកម្មមួយចំនួនពាក់ព័ន្ធនឹងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ។

២- ជៀសវាងការភាន់ច្រឡំ គឺពុំមានករណីណាមួយត្រូវបានបកស្រាយលើកិច្ចព្រមព្រៀងនេះថា ការអនុវត្តបទប្បញ្ញត្តិនៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសធ្វើឡើងដោយក្រុមហ៊ុនអាកាសចរណ៍ណាមួយនៃរដ្ឋសមាជិកអាស៊ានមួយ ហោះហើរមកពី នៅក្នុង ឬទៅកាន់ដែនដីនៃរដ្ឋសមាជិកអាស៊ានណាមួយផ្សេងទៀតបានទេ ឬការអនុវត្តបទប្បញ្ញត្តិនៃសេវាកម្មមួយចំនួនពាក់ព័ន្ធទៅនឹងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសទាំងនោះបានទេ។

## មាត្រា២
## និយមន័យ

១- សម្រាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ មានដូចខាងក្រោម៖

(ក) «អនុសញ្ញាក្រុងឈីកាហ្គោ» សំដៅដល់អនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិដែលបានចុះហត្ថលេខានៅក្រុងឈីកាហ្គោ នាថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៤៤ និងរួមបញ្ចូលឧបសម្ព័ន្ធណាមួយដែលបានអនុម័តក្រោមមាត្រា៩០នៃអនុសញ្ញា និងវិសោធនកម្មឧបសម្ព័ន្ធនានា ឬអនុសញ្ញាក្រោមមាត្រា៩០និងមាត្រា៩៤ ដរាបណាឧបសម្ព័ន្ធនិងវិសោធនកម្មទាំងនោះមានប្រសិទ្ធភាពសម្រាប់តែរដ្ឋភាគី។

(ខ) «អនុសញ្ញាម៉ុងរ៉េអាល់» សំដៅដល់អនុសញ្ញាស្តីពីឯកភាវូបនីយកម្មនៃវិធានមួយចំនួនពាក់ព័ន្ធនឹងការដឹកជញ្ជូនអន្តរជាតិតាមផ្លូវអាកាសដែលធ្វើឡើងនៅក្រុងម៉ុងរ៉េអាល់នៃប្រទេសកាណាដា នាថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៩។

(គ) «ការដឹកជញ្ជូនតាមផ្លូវអាកាស» សំដៅដល់ការដឹកជញ្ជូនតាមអាកាសយាននូវអ្នកដំណើរ អីវ៉ាន់ ទំនិញ និងបញ្ញើប្រៃសណីយ៍ ដោយឡែកពីគ្នាឬរួមបញ្ចូលគ្នា ដែលធ្វើឡើងជាសាធារណៈសម្រាប់ជាថ្នូរនឹងលាភការឬការជួល រួមទាំងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសតាមកាលវិភាគហោះហើរ និងក្រៅកាលវិភាគហោះហើរ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

(ឃ) «ការកំណត់សញ្ជាតិ» សំដៅដល់ការរកឃើញថា ក្រុមហ៊ុនអាកាសចរណ៍មួយដែលស្នើសុំធ្វើប្រតិបត្តិការសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងនេះ បំពេញតាមលក្ខខណ្ឌនៃមាត្រា៤ ទាក់ទងនឹងភាពជាម្ចាស់កម្មសិទ្ធិរបស់ខ្លួន ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងកន្លែងប្រកបអាជីវកម្មជាគោលដើម។

(ង) «អាជ្ញាធរមានសមត្ថកិច្ច» សំដៅដល់ទីភ្នាក់ងាររដ្ឋាភិបាលឬអង្គភាពនានាដែលទទួលខុសត្រូវចំពោះមុខងារច្បាប់និងរដ្ឋបាល គ្រប់គ្រងលើរដ្ឋភាគីក្រោមកិច្ចព្រមព្រៀងនេះ។

(ច) «អាជ្ញាធរប្រកួតប្រជែង» សំដៅដល់អាជ្ញាធរមានសមត្ថកិច្ចឬអាជ្ញាធរនានាទទួលបន្ទុកការអនុវត្តច្បាប់ប្រកួតប្រជែងនៃភាគីមួយ រួមទាំងក្នុងករណីសហភាព គឺគណៈកម្មការអឺរ៉ុប។

(ឆ) «ច្បាប់ប្រកួតប្រជែង» សំដៅដល់ច្បាប់ដែលចែងក្នុងយុត្តាធិការនៃភាគីមួយ ការប្រព្រឹត្តដូចខាងក្រោមដែលអាចប៉ះពាល់ដល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ហោះហើរទៅកាន់ មកពី ឬស្ថិតនៅក្នុងវង្វង់ភាគីនោះ៖

(i) កិច្ចព្រមព្រៀងរវាងក្រុមហ៊ុនអាកាសចរណ៍ ការសម្រេចដោយសមាគមក្រុមហ៊ុនអាកាសចរណ៍ និងការអនុវត្តរួមគ្នាដែលជាកម្មវត្ថុឬប្រសិទ្ធភាពក្នុងការទប់ស្កាត់របស់ខ្លួន ការរឹតត្បិតឬការបង្ខូចទ្រង់ទ្រាយនៃការប្រកួតប្រជែង។

(ii) ការរំលោភបំពានដោយក្រុមហ៊ុនអាកាសចរណ៍មួយឬច្រើនដែលមានឥទ្ធិពល ឬ

(iii) ការប្រមូលផ្តុំរវាងក្រុមហ៊ុនអាកាសចរណ៍នានាដែលបណ្តាលឱ្យមានការថយចុះការប្រកួតប្រជែង ហើយជាលទ្ធផលបង្កើតឱ្យមានឬពង្រឹងក្រុមហ៊ុនអាកាសចរណ៍ដែលមានឥទ្ធិពល។

(ជ) «ប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ» (តទៅនេះហៅកាត់ថា «ស៊ីអរអេស-CRS») សំដៅដល់ប្រព័ន្ធកុំព្យូទ័រដែលមានព័ត៌មាន(រួមមានកាលវិភាគហោះហើរ ភាពអាចប្រើប្រាស់បាន និងតម្លៃ) នៃក្រុមហ៊ុនអាកាសចរណ៍ច្រើនជាងមួយ ដោយមានឬគ្មានឧបករណ៍កក់ឬចេញសំបុត្រ ក្នុងវិសាលភាពដែលសេវាកម្មមួយចំនួនឬទាំងអស់ ត្រូវបានផ្តល់ជូនអតិថិជន និងរួមបញ្ចូល «ប្រព័ន្ធចែកចាយសកល» ដរាបណាសេវាកម្មទាំងនេះជាផលិតផលដឹកជញ្ជូនតាមផ្លូវអាកាស។

«ការរើសអើង» សំដៅដល់ភាពខុសគ្នានៃប្រភេទណាមួយ ដោយគ្មានមូលហេតុជាក់លាក់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(ញ) «ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព» សំដៅដល់ទំនាក់ទំនងដែលបង្កើតឡើងដោយសិទ្ធិ កិច្ចសន្យា ឬមធ្យោបាយផ្សេងទៀត ដែលដាច់ដោយឡែកពីគ្នាឬរួមបញ្ចូលគ្នា ហើយទាក់ទងនឹងការពិនិត្យជាក់ស្តែងឬតាមច្បាប់ពាក់ព័ន្ធ ដែលផ្តល់លទ្ធភាពក្នុងការអនុវត្តដោយផ្ទាល់ឬដោយប្រយោលនូវសិទ្ធិសម្រេចលើកិច្ចការជាពិសេស ដោយៈ

(i) សិទ្ធិលើការប្រើប្រាស់ទាំងស្រុងឬមួយផ្នែកនៃទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនអាកាសចរណ៍។

(ii) សិទ្ធិឬកិច្ចសន្យាដែលផ្តល់សិទ្ធិសម្រេចលើសមាសភាព ការបោះឆ្នោត ឬការសម្រេចរបស់ស្ថាប័ននៃក្រុមហ៊ុនអាកាសចរណ៍ ឬបើមិនដូច្នេះទេ ផ្តល់សិទ្ធិសម្រេចលើដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនអាកាសចរណ៍។

(ដ) «ការកំណត់កាយសម្បទា» សំដៅដល់ការរកឃើញថា ក្រុមហ៊ុនអាកាសចរណ៍មួយដែលស្នើសុំឱ្យធ្វើប្រតិបត្តិការសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងនេះ មានសមត្ថភាពហិរញ្ញវត្ថុពេញលេញ និងមានជំនាញគ្រប់គ្រងគ្រប់គ្រាន់ដើម្បីធ្វើប្រតិបត្តិការសេវាកម្មទាំងនោះ ហើយត្រូវបានចាត់ចែងឡើងដើម្បីអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងលក្ខខណ្ឌតម្រូវដែលគ្រប់គ្រងប្រតិបត្តិការនៃសេវាកម្មបែបនេះ។

(ឋ) «ការចំណាយទាំងស្រុង» សំដៅដល់ថ្លៃសេវាកម្មដែលបានផ្តល់ ដែលអាចរាប់បញ្ចូលទាំងចំនួនចំណាយសមស្របនៃដើមទុននិងរំលស់ទ្រព្យសកម្ម ព្រមទាំងថ្លៃចំណាយលើការថែទាំ ប្រតិបត្តិការ ការគ្រប់គ្រង និងរដ្ឋបាល។

(ឌ) «ការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ» សំដៅដល់ការដឹកជញ្ជូនតាមផ្លូវអាកាសដែលឆ្លងកាត់ដែនអាកាសនៅលើដែនដីនៃរដ្ឋលើសពីមួយ។

(ឍ) «ប្រតិបត្តិការដែលមានតម្លៃខ្ពស់» សំដៅដល់ការផ្គត់ផ្គង់ទំនិញនិងសេវាកម្មដែលមានតាមលំដាប់បែបនេះ ធ្វើឱ្យប៉ះពាល់ដល់កាលានុវត្តភាពយុត្តិធម៌និងស្មើភាពរបស់ក្រុមហ៊ុនអាកាសចរណ៍នៃរដ្ឋភាគី ក្នុងការប្រកួតប្រជែង។

(ណ) «សេវាកម្មក្រៅកាលវិភាគហោះហើរ» សំដៅដល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសដែលមិនមែនជាសេវាកម្មតាមកាលវិភាគហោះហើរ។

(ត) «ភាគី» សំដៅដល់សហភាពនិងបណ្តារដ្ឋសមាជិកសហភាពអឺរ៉ុបជាផ្នែកមួយ ឬរដ្ឋសមាជិកអាស៊ានជាផ្នែកមួយផ្សេងទៀត។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(ថ) «រដ្ឋភាគី» សំដៅដល់៖

(i) សហភាពនិងបណ្ដារដ្ឋសមាជិកសហភាពអឺរ៉ុប និង

(ii) បណ្ដារដ្ឋសមាជិកអាស៊ាន។

(ទ) «កន្លែងប្រកបអាជីវកម្មជាគោលដើម» សំដៅដល់ការិយាល័យកណ្ដាលឬការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុនអាកាសចរណ៍នៅក្នុងដែនដីនៃភាគីមួយ ដែលមានមុខងារផ្នែកហិរញ្ញវត្ថុនិងការគ្រប់គ្រងប្រតិបត្តិការចម្បង រួមទាំងបន្ដការគ្រប់គ្រងលទ្ធភាពហោះហើររបស់ក្រុមហ៊ុនអាកាសចរណ៍ដែលបានអនុវត្ត។

(ធ) «សេវាកម្មតាមកាលវិភាគហោះហើរ» សំដៅដល់ជើងហោះហើរមួយចំនួនដែលមានលក្ខណៈដូចខាងក្រោម៖

(i) ឆ្លងកាត់ដែនអាកាសពីលើដែនដីនៃរដ្ឋច្រើនជាងមួយ។

(ii) ត្រូវបានអនុវត្តដោយអាកាសយានសម្រាប់ការដឹកជញ្ជូនអ្នកដំណើរ អីវ៉ាន់ បញ្ញើប្រៃសណីយ៍ និង/ឬទំនិញសម្រាប់ជាថ្នូរនឹងលាភការឬការជួល ក្នុងលក្ខណៈដែលជើងហោះហើរនីមួយៗត្រូវបានបើកឱ្យសាធារណជនបានប្រើប្រាស់។

(iii) ត្រូវបានប្រតិបត្តិការដើម្បីបម្រើចរាចរណ៍រវាងចំណុចហោះហើរដូចគ្នាពីរឬច្រើន ដោយ៖

(ក) ស្របតាមតារាងកាលវិភាគដែលបានបោះពុម្ពផ្សព្វផ្សាយ ឬ

(ខ) ជើងហោះហើរជាប្រចាំឬញឹកញាប់ ដែលជើងហោះហើរនេះបង្កើតចំនួនជាប្រព័ន្ធអាចទទួលស្គាល់បាន។

(ន) «ការបម្រើសេវាកម្មដោយផ្ទាល់ខ្លួន» សំដៅដល់ស្ថានភាពដែលក្រុមហ៊ុនអាកាសចរណ៍ផ្ដល់សេវាកម្មដឹកជញ្ជូនដោយផ្ទាល់មួយឬច្រើនប្រភេទ សម្រាប់ផ្ទាល់ខ្លួននៃសេវាកម្មលើផ្ទៃដី ហើយមិនបានចុះកិច្ចសន្យាជាមួយភាគីទីបីសម្រាប់ការផ្ដល់សេវាកម្មបែបនេះ។ ចំពោះគោលបំណងនៃការកំណត់នេះ ក្រុមហ៊ុនអាកាសចរណ៍ក្នុងចំណោមពួកគេ មិនត្រូវចាត់ទុកថា ជាភាគីទីបី នៅពេល៖

(i) ក្រុមហ៊ុនមួយកាន់កាប់ភាគច្រើននៅក្នុងក្រុមហ៊ុនមួយផ្សេងទៀត ឬ

(ii) ក្រុមហ៊ុនមួយមានមតិភាគច្រើននៅក្នុងក្រុមហ៊ុននីមួយៗ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

(ប) «ការរំខានយ៉ាងធ្ងន់ធ្ងរចំពោះសេដ្ឋកិច្ចនៃភាគីមួយ» ត្រូវសំដៅដល់វិបត្តិបណ្ដោះអាសន្ននិងវិបត្តិគួរឱ្យកត់សម្គាល់ ដែលប៉ះពាល់ដល់សេដ្ឋកិច្ចទាំងមូលនៃរដ្ឋសមាជិកអាស៊ានមួយ ឬនៃរដ្ឋសមាជិកសហភាពអឺរ៉ុបមួយ ដែលមិនមែនជាតំបន់ឬវិស័យសេដ្ឋកិច្ចជាក់លាក់មួយ។

(ផ) «សហគ្រាសគ្រប់គ្រងដោយរដ្ឋ» សំដៅដល់សហគ្រាសទាំងឡាយណាដែលពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្ម ដែល៖

(i) ភាគីមួយកាន់កាប់ច្រើនជាង៥០%(ហាសិបភាគរយ)នៃមូលធនចុះបញ្ជីរបស់សហគ្រាស ឬការជ្រើសតាំងជាមួយនឹងភាគហ៊ុនដែលចេញដោយសហគ្រាស ឬ

(ii) ភាគីមួយអនុវត្តឬមានលទ្ធភាពអនុវត្តដែលមានសិទ្ធិសម្រេចដោយផ្ទាល់ឬដោយប្រយោល លើកត្តាហិរញ្ញវត្ថុរបស់ខ្លួនជាចម្បង ឬបទបញ្ជា ឬការអនុវត្តលើការបំពេញមុខងាររបស់ខ្លួន ឬមធ្យោបាយផ្សេងទៀតដែលពាក់ព័ន្ធ ដើម្បីបង្កើតសិទ្ធិសម្រេចដ៏សំខាន់លើសហគ្រាស។ សិទ្ធិសម្រេចដ៏សំខាន់លើផ្នែកនៃភាគីមួយ ត្រូវសន្មតថា នៅពេលដែលភាគីមួយអាចតែងតាំងសមាជិកលើសពីពាក់កណ្ដាលនៃផ្នែករដ្ឋបាល ផ្នែកគ្រប់គ្រង ឬស្ថាប័នផ្នែកត្រួតពិនិត្យរបស់សហគ្រាសដោយផ្ទាល់ឬដោយប្រយោល។

(ព) «ឈប់សំចតមិនធ្វើពាណិជ្ជកម្ម» សំដៅដល់ការចុះចតសម្រាប់គោលបំណងណាមួយក្រៅពីការទទួលយកឬការដាក់ចុះនូវអ្នកដំណើរ អីវ៉ាន់ ទំនិញ និង/ឬបញ្ញើប្រៃសណីយ៍ក្នុងការដឹកជញ្ជូនតាមផ្លូវអាកាស។

(ភ) «ឧបត្ថម្ភធន» សំដៅដល់វិភាគទានហិរញ្ញវត្ថុណាមួយដែលផ្ដល់ឱ្យដោយរដ្ឋាភិបាលឬស្ថាប័នសាធារណៈណាមួយ រួមមាន៖

(i) ការផ្ទេរមូលនិធិដោយផ្ទាល់ ដូចជាជំនួយ ប្រាក់កម្ចីឬការផ្ដល់ជាសាច់ប្រាក់ លទ្ធភាពនៃការផ្ទេរប្រាក់ដោយផ្ទាល់ ការទទួលយកបំណុលដូចជាការធានាប្រាក់កម្ចី ការផ្ដល់ដើមទុនភាពជាម្ចាស់កម្មសិទ្ធិ ការការពារទប់ទល់នឹងការក្ស័យធន ឬការធានារ៉ាប់រងជាដើម។

(ii) ការបោះបង់ឬមិនប្រមូលចំណូលដែលដល់ពេលកំណត់។

(iii) ការផ្ដល់ទំនិញឬសេវាកម្មផ្សេងទៀតក្រៅពីហេដ្ឋារចនាសម្ព័ន្ធទូទៅ ឬការទិញទំនិញ ឬសេវាកម្មនានា ឬ

(iv) ការទូទាត់តាមយន្តការផ្ដល់មូលនិធិ ឬការប្រគល់សិទ្ធិ ឬការណែនាំដល់ស្ថាប័នឯកជនដើម្បីអនុវត្តមុខងារមួយឬច្រើន ដូចមានចែងក្នុងកថាខណ្ឌទី១ ចំណុច(ភ)(i), (ii)



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

និង(iii)នៃមាត្រានេះ ដែលជាធម្មតាត្រូវបានប្រគល់ឱ្យរដ្ឋាភិបាលឬស្ថាប័នសាធារណៈផ្សេងទៀត ហើយការអនុវត្តជាក់ស្តែងក៏មិនខុសពីការអនុវត្តជាធម្មតាដែលអនុវត្តដោយរដ្ឋាភិបាល។

កម្រិតកំណត់ចំពោះអង្គភាព ឬឧស្សាហកម្ម ឬក្រុមអង្គភាព ឬឧស្សាហកម្មនានា ក្នុងរង្វង់ដែនសមត្ថកិច្ចនៃអាជ្ញាធរផ្តល់សិទ្ធិ និងផ្តល់អត្ថប្រយោជន៍ដល់ក្រុមហ៊ុនអាកាសចរណ៍នានា។ គ្មានអត្ថប្រយោជន៍ណាមួយដែលបានចាត់ទុកថា ត្រូវបានផ្តល់ដោយការធ្វើអន្តរាគមន៍ផ្នែកហិរញ្ញវត្ថុដែលធ្វើឡើងដោយរដ្ឋាភិបាលឬស្ថាប័នសាធារណៈផ្សេងទៀត ប្រសិនបើប្រតិបត្តិករទីផ្សារឯកជនត្រូវបានជំរុញដោយការរំពឹងទុកនៃការរកប្រាក់ចំណេញក្នុងស្ថានភាពដូចគ្នានឹងស្ថាប័នសាធារណៈ ដែលស្ថិតនៅក្នុងមន្ទិលសង្ស័យនេះ នឹងត្រូវបានធ្វើអន្តរាគមន៍ផ្នែកហិរញ្ញវត្ថុដូចគ្នា។

(ម) «តម្លៃសេវាកម្ម» សំដៅដល់តម្លៃសំបុត្រធ្វើដំណើរ អត្រា ឬការយកតម្លៃដឹកជញ្ជូនអ្នកដំណើរ អីវ៉ាន់ និង/ឬទំនិញ(មិនរួមបញ្ចូលបញ្ញើប្រៃសណីយ៍)ក្នុងការដឹកជញ្ជូនតាមផ្លូវអាកាស(រួមទាំងមធ្យោបាយដឹកជញ្ជូនផ្សេងទៀតក្នុងការតភ្ជាប់ជាមួយ) ដែលយកតម្លៃដោយក្រុមហ៊ុនអាកាសចរណ៍ ដែលរាប់បញ្ចូលទាំងភ្នាក់ងាររបស់ខ្លួន និងលក្ខខណ្ឌគ្រប់គ្រងភាពអាចរកបាននៃតម្លៃសំបុត្រធ្វើដំណើរ អត្រា ឬការយកតម្លៃបែបនេះ។

(យ) «ដែនដី» សំដៅដល់សម្រាប់បណ្តារដ្ឋសមាជិកអាស៊ាន ដែនដីគោក ផ្ទៃទឹក ដែនកោះ ផ្ទៃសមុទ្របាតសមុទ្រ និងក្រោមបាតសមុទ្រ និងលំហអាកាសពីលើ និងសម្រាប់សហភាព ដែនដីគោក ផ្ទៃទឹក និងផ្ទៃសមុទ្រ ដែលស្ថិតក្រោមសន្ធិសញ្ញាសហភាពអឺរ៉ុប និងក្រោមលក្ខខណ្ឌដែលមានចែងក្នុងសន្ធិសញ្ញាទាំងអស់នោះ ក៏ដូចជាបាតសមុទ្រនិងក្រោមបាតសមុទ្រ និងលំហអាកាសពីលើ និង

(កក) «ការយកថ្លៃលើអ្នកប្រើប្រាស់» សំដៅដល់ការយកថ្លៃលើក្រុមហ៊ុនអាកាសចរណ៍ សម្រាប់ការផ្តល់អាកាសយានដ្ឋាន ការនាំផ្លូវអាកាស ឬបរិក្ខារសន្តិសុខអាកាសចរណ៍ ឬសេវាកម្មផ្សេងៗ រួមទាំងសេវាកម្មនិងគ្រឿងបរិក្ខារដែលពាក់ព័ន្ធ ឬការយកថ្លៃទាក់ទងនឹងសំឡេង និងរួមទាំងការយកថ្លៃដើម្បីឆ្លើយតបទៅនឹងបញ្ហាគុណភាពខ្យល់ នៅឬជុំវិញអាកាសយានដ្ឋាន។ ដើម្បីជៀសវាងការសង្ស័យ និយមន័យនេះ មិនរួមបញ្ចូលគម្រោងដើម្បីដោះស្រាយបញ្ហាអាកាសធាតុ ដូចជាការបំភាយឧស្ម័នពីអាកាសចរណ៍អន្តរជាតិទេ។

## មាត្រា៣
## ការផ្តល់សិទ្ធិ
## ភាគវិភាគផ្លូវហោះហើរ

១. រដ្ឋសមាជិកអាស៊ានមួយ ត្រូវអនុញ្ញាតឱ្យក្រុមហ៊ុនអាកាសចរណ៍របស់សហភាពធ្វើប្រតិបត្តិការលើផ្លូវហោះហើរ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ចំណុចហោះហើរណាមួយនៅក្នុងសហភាព - ចំណុចហោះហើរកណ្តាលណាមួយ - ចំណុចហោះហើរណាមួយនៅក្នុងរដ្ឋសមាជិកអាស៊ាន - ចំណុចហោះហើរឯនាយណាមួយ។

សម្រាប់គោលបំណងនៃផ្លូវហោះហើរដែលបានកំណត់ខាងលើ ចំណុចហោះហើរកណ្តាលនិងចំណុចហោះហើរឯនាយ ត្រូវរួមបញ្ចូលចំណុចហោះហើរមួយឬច្រើននៅក្នុងបណ្តារដ្ឋសមាជិកអាស៊ានផ្សេងទៀត។

២- សហភាពនិងបណ្តារដ្ឋសមាជិករបស់ខ្លួន ត្រូវអនុញ្ញាតឱ្យក្រុមហ៊ុនអាកាសចរណ៍នៃរដ្ឋសមាជិកអាស៊ានមួយធ្វើប្រតិបត្តិការលើផ្លូវហោះហើរ ដូចខាងក្រោម៖

ចំណុចហោះហើរណាមួយនៅក្នុងរដ្ឋសមាជិកអាស៊ាន - ចំណុចហោះហើរកណ្តាលណាមួយ - ចំណុចហោះហើរណាមួយនៅក្នុងសហភាព - ចំណុចហោះហើរឯនាយណាមួយ។

សម្រាប់គោលបំណងនៃផ្លូវហោះហើរដែលបានកំណត់ខាងលើ ចំណុចហោះហើរនៅក្នុងសហភាព ត្រូវរួមបញ្ចូលចំណុចហោះហើរមួយឬច្រើននៅក្នុងបណ្តារដ្ឋសមាជិកសហភាពអឺរ៉ុបណាមួយ។

## សិទ្ធិចរាចរណ៍

៣- រដ្ឋភាគីត្រូវផ្តល់សិទ្ធិដល់គ្នាទៅវិញទៅមកសម្រាប់ការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិដោយក្រុមហ៊ុនអាកាសចរណ៍រៀងៗខ្លួននូវសិទ្ធិ ដូចខាងក្រោម៖

(ក) សិទ្ធិហោះហើរឆ្លងកាត់ពីលើដែនដីរបស់ភាគីមួយដោយគ្មានការចុះចត។

(ខ) សិទ្ធិឈប់សំចតក្នុងគោលបំណងមិនធ្វើពាណិជ្ជកម្មនៅក្នុងដែនដីនៃភាគីមួយដែលផ្តល់សិទ្ធិ។

(គ) សិទ្ធិហោះហើរសម្រាប់ក្រុមហ៊ុនអាកាសចរណ៍នៃរដ្ឋសមាជិកអាស៊ានមួយ ដើម្បីអនុវត្តការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិតាមកាលវិភាគនិងក្រៅកាលវិភាគហោះហើរនូវអ្នកដំណើរ ទំនិញ និងសេវាកម្មរួមបញ្ចូលគ្នា រវាងចំណុចហោះហើរណាមួយនៅក្នុងរដ្ឋសមាជិកអាស៊ាននោះនិងចំណុចហោះហើរណាមួយនៅក្នុងសហភាព( សិទ្ធិហោះហើរទីបីនិងទីបួន )។

(ឃ) សិទ្ធិហោះហើរសម្រាប់ក្រុមហ៊ុនអាកាសចរណ៍របស់សហភាព ដើម្បីអនុវត្តការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិតាមកាលវិភាគនិងក្រៅកាលវិភាគហោះហើរសម្រាប់អ្នកដំណើរ ទំនិញ និងសេវាកម្មរួមបញ្ចូលគ្នា រវាងចំណុចហោះហើរណាមួយនៅក្នុងសហភាពនិងចំណុចហោះហើរណាមួយនៅក្នុងបណ្តារដ្ឋសមាជិកអាស៊ាន( សិទ្ធិហោះហើរទីបីនិងទីបួន )។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

(ង) សិទ្ធិហោះហើរសម្រាប់ក្រុមហ៊ុនអាកាសចរណ៍នៃរដ្ឋសមាជិកអាស៊ានមួយ ដើម្បីអនុវត្តការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិតាមកាលវិភាគនិងក្រៅកាលវិភាគហោះហើរនូវអ្នកដំណើរ ទំនិញ និងសេវាកម្មរួមបញ្ចូលគ្នា រវាងចំណុចហោះហើរណាមួយនៅក្នុងរដ្ឋសមាជិកសហភាពអឺរ៉ុបមួយនិងចំណុចហោះហើរណាមួយនៅក្នុងរដ្ឋសមាជិកសហភាពអឺរ៉ុបផ្សេងទៀត ឬចំណុចហោះហើរណាមួយនៅក្នុងប្រទេសទីបី ជាផ្នែកនៃសេវាកម្មដែលមានប្រភពដើមឬទិសដៅនៅក្នុងរដ្ឋសមាជិកអាស៊ាននោះ(សិទ្ធិហោះហើរទីប្រាំ) ជាកម្មវត្ថុកថាខណ្ឌទី៤នៃមាត្រានេះ។

(ច) សិទ្ធិហោះហើរសម្រាប់ក្រុមហ៊ុនអាកាសចរណ៍របស់សហភាព ដើម្បីអនុវត្តការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិតាមកាលវិភាគនិងក្រៅកាលវិភាគហោះហើរនូវអ្នកដំណើរ ទំនិញ និងសេវាកម្មរួមបញ្ចូលគ្នា រវាងចំណុចហោះហើរណាមួយនៅក្នុងរដ្ឋសមាជិកអាស៊ានមួយ និងចំណុចហោះហើរណាមួយនៅក្នុងរដ្ឋសមាជិកអាស៊ានមួយផ្សេងទៀត ឬចំណុចហោះហើរណាមួយនៅក្នុងប្រទេសទីបី ជាផ្នែកនៃសេវាកម្មដែលមានប្រភពដើមឬទិសដៅនៅក្នុងសហភាព(សិទ្ធិហោះហើរទីប្រាំ) ជាកម្មវត្ថុកថាខណ្ឌទី៥នៃមាត្រានេះ និង

(ឆ) សិទ្ធិហោះហើរផ្សេងទៀតដែលបានបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងនេះ។

៤- ទាក់ទងនឹងអ្នកដំណើរនិងសេវាកម្មរួមបញ្ចូលគ្នា សិទ្ធិហោះហើរដែលមានចែងក្នុងកថាខណ្ឌទី៣ ចំណុច(ង) នៃមាត្រានេះ ត្រូវអនុវត្តចំពោះរដ្ឋសមាជិកអាស៊ាននីមួយៗតាមលក្ខខណ្ឌ មានដូចខាងក្រោម៖

(ក) ជើងហោះហើរអតិបរមាចំនួន៧(ប្រាំពីរ)ជើងប្រចាំសប្តាហ៍ ជាមួយនឹងការចេញដំណើរឬការមកដល់នៅក្នុងរដ្ឋសមាជិកសហភាពអឺរ៉ុបនីមួយៗ អាចត្រូវបានធ្វើប្រតិបត្តិការភ្លាមៗក្នុងទិសដៅនីមួយៗ នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន។

(ខ) ជើងហោះហើរអតិបរមាបន្ថែមចំនួន៧(ប្រាំពីរ)ជើងប្រចាំសប្តាហ៍ ជាមួយនឹងការចេញដំណើរឬការមកដល់នៅក្នុងរដ្ឋសមាជិកសហភាពអឺរ៉ុបនីមួយៗ អាចត្រូវបានធ្វើប្រតិបត្តិការក្នុងទិសដៅនីមួយៗបន្ទាប់ពី២(ពីរ)ឆ្នាំ និង

(គ) ជើងហោះហើរដែលបានធ្វើប្រតិបត្តិការអនុលោមតាមកថាខណ្ឌទី៤ ចំណុច(ខ)នៃមាត្រានេះ មិនអាចប្រើផ្លូវហោះហើររវាងរដ្ឋសមាជិកសហភាពអឺរ៉ុបមួយនិងប្រទេសទីបី ដែលកំពុងត្រូវបានប្រើដោយក្រុមហ៊ុនអាកាសចរណ៍របស់សហភាពរួចហើយ។ ចំពោះគោលបំណងនៃកថាខណ្ឌនេះ ផ្លូវហោះហើរមួយនឹងត្រូវបានចាត់ទុកថា ត្រូវបានប្រើដោយក្រុមហ៊ុនអាកាសចរណ៍មួយរបស់



សហភាព ប្រសិនបើក្រុមហ៊ុនអាកាសចរណ៍នោះធ្វើប្រតិបត្តិការលើផ្លូវហោះហើរនោះ តាមសេវាកម្មកាលវិភាគហោះហើរជាមួយនឹងអាកាសយានរបស់ខ្លួន ជាមួយនឹងអាកាសយានដែលបានជួលដោយមានឬគ្មានអាកាសយានិក ឬក្នុងករណីធ្វើសេវាកម្មជាបន្តដោយសំដៅដល់កិច្ចសហការជើងហោះហើរ។

៥- ទាក់ទងនឹងអ្នកដំណើរនិងសេវាកម្មរួមបញ្ចូលគ្នា សិទ្ធិហោះហើរដែលមានចែងក្នុងកថាខណ្ឌទី៣ ចំណុច(ច) នៃមាត្រានេះ ត្រូវអនុវត្តចំពោះរដ្ឋសមាជិកសហភាពអឺរ៉ុបនីមួយៗតាមលក្ខខណ្ឌ មានដូចខាងក្រោមៈ

(ក) ជើងហោះហើរអតិបរមាចំនួន៧(ប្រាំពីរ)ជើងប្រចាំសប្តាហ៍ ជាមួយនឹងការចេញដំណើរឬការមកដល់នៅក្នុងរដ្ឋសមាជិកអាស៊ាននីមួយៗ អាចត្រូវបានធ្វើប្រតិបត្តិការភ្លាមៗក្នុងទិសដៅនីមួយៗ នៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន។

(ខ) ជើងហោះហើរអតិបរមាបន្ថែមចំនួន៧(ប្រាំពីរ)ជើងប្រចាំសប្តាហ៍ ជាមួយនឹងការចេញដំណើរឬការមកដល់នៅក្នុងរដ្ឋសមាជិកអាស៊ាននីមួយៗ អាចត្រូវបានធ្វើប្រតិបត្តិការក្នុងទិសដៅនីមួយៗ បន្ទាប់ពី២(ពីរ)ឆ្នាំ និង

(គ) ជើងហោះហើរដែលធ្វើប្រតិបត្តិការអនុលោមតាមកថាខណ្ឌទី៥ ចំណុច(ខ)នៃមាត្រានេះ មិនអាចប្រើផ្លូវហោះហើរ រវាងរដ្ឋសមាជិកអាស៊ានមួយនិងប្រទេសទីបី ដែលកំពុងត្រូវបានប្រើដោយក្រុមហ៊ុនអាកាសចរណ៍មួយរបស់រដ្ឋសមាជិកអាស៊ាននោះរួចហើយ។ ចំពោះគោលបំណងនៃកថាខណ្ឌនេះ ផ្លូវហោះហើរមួយនឹងត្រូវចាត់ទុកថា ត្រូវបានប្រើដោយក្រុមហ៊ុនអាកាសចរណ៍មួយរបស់រដ្ឋសមាជិកអាស៊ានមួយ ប្រសិនបើក្រុមហ៊ុនអាកាសចរណ៍នោះ ធ្វើប្រតិបត្តិការលើផ្លូវហោះហើរនោះ តាមសេវាកម្មកាលវិភាគហោះហើរជាមួយនឹងអាកាសយានរបស់ខ្លួន ជាមួយនឹងអាកាសយានដែលបានជួលដោយមានឬគ្មានអាកាសយានិក ឬក្នុងករណីធ្វើសេវាកម្មជាបន្តដោយសំដៅដល់កិច្ចសហការជើងហោះហើរ។

## ភាពបត់បែននៃប្រតិបត្តិការ

៦- ក្រុមហ៊ុនអាកាសចរណ៍របស់ភាគីនីមួយៗអាចនៅលើជើងហោះហើរណាមួយឬទាំងអស់ និងតាមជម្រើសរបស់ខ្លួនលើផ្លូវហោះហើរដែលបានបញ្ជាក់ក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រានេះៈ

(ក) ធ្វើប្រតិបត្តិការជើងហោះហើរក្នុងទិសដៅណាមួយឬទិសដៅទាំងពីរ។

(ខ) រួមបញ្ចូលគ្នានូវលេខជើងហោះហើរផ្សេងៗគ្នាក្នុងប្រតិបត្តិការអាកាសយានតែមួយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(គ) ប្រើចំណុចហោះហើរកណ្តាល និងចំណុចហោះហើរឯនាយ និងចំណុចហោះហើរនានានៅក្នុងដែនដីនៃរដ្ឋភាគីក្នុងការរួមបញ្ចូលគ្នាណាមួយ និងតាមលំដាប់ណាមួយស្របតាមបទប្បញ្ញត្តិកថាខណ្ឌទី៣នៃមាត្រានេះ។

(ឃ) លុបចោលការឈប់សំចតនៅចំណុចហោះហើរណាមួយឬចំណុចហោះហើរនានា។

(ង) ផ្ទេរចរាចរណ៍ពីអាកាសយានរបស់ខ្លួនទៅអាកាសយានផ្សេងទៀតរបស់ខ្លួននៅចំណុចហោះហើរណាមួយ(ការផ្លាស់ប្តូរដែលអាចវាស់វែងបាន)។

(ច) ធ្វើចរាចរណ៍ឈប់សំចតនៅចំណុចហោះហើរណាមួយ មិនថានៅក្នុងឬនៅក្រៅដែនដីនៃរដ្ឋភាគី។

(ឆ) ធ្វើចរាចរណ៍បន្តដំណើរឆ្លងកាត់ដែនដីនៃភាគីមួយផ្សេងទៀត។

(ជ) រួមបញ្ចូលគ្នានូវការធ្វើចរាចរណ៍នៅលើអាកាសយានតែមួយ ដោយមិនគិតពីទីកន្លែងដែលការធ្វើចរាចរណ៍នោះមានប្រភពមកពីទីកន្លែងណាឡើយ និង

(ឈ) ប្រើច្រើនជាងមួយចំណុចហោះហើរនៅក្នុងរដ្ឋសមាជិកសហភាពអឺរ៉ុបដូចគ្នាឬរដ្ឋសមាជិកអាស៊ានលើសេវាកម្មដូចគ្នា(សិទ្ធិហោះហើរកូជ័រមីណល)។

៧- ភាពបត់បែននៃប្រតិបត្តិការដែលមានចែងក្នុងកថាខណ្ឌទី៦នៃមាត្រានេះ អាចត្រូវបានអនុវត្តដោយគ្មានការកំណត់ទិសដៅឬភូមិសាស្ត្រ លុះត្រាតែៈ

(ក) សេវាកម្មក្រុមហ៊ុនអាកាសចរណ៍នានារបស់រដ្ឋសមាជិកអាស៊ានមួយ ប្រើចំណុចហោះហើរមួយនៅក្នុងរដ្ឋសមាជិកអាស៊ាននោះ និង

(ខ) សេវាកម្មក្រុមហ៊ុនអាកាសចរណ៍នានារបស់សហភាព ប្រើចំណុចហោះហើរមួយនៅក្នុងសហភាព។

៨- ភាគីនីមួយៗ ត្រូវអនុញ្ញាតឱ្យក្រុមហ៊ុនអាកាសចរណ៍នីមួយៗកំណត់ចំនួនជើងហោះហើរនិងចំណុះដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ ដែលខ្លួនផ្តល់ជូនដោយផ្អែកលើការពិចារណាផ្នែកពាណិជ្ជកម្ម។ ដោយអនុលោមតាមសិទ្ធិហោះហើរនេះ គ្មានភាគីណាមួយត្រូវកំណត់ជាឯកតោភាគីនូវបរិមាណនៃចរាចរណ៍ ចំនួនជើងហោះហើរ ឬភាពប្រក្រតីនៃសេវាកម្ម ផ្លូវហោះហើរ ប្រភពដើមនិងទិសដៅនៃចរាចរណ៍ ឬប្រភេទអាកាសយានមួយ ឬប្រភេទផ្សេងទៀតដែលធ្វើប្រតិបត្តិការដោយក្រុមហ៊ុនអាកាសចរណ៍របស់ភាគីមួយផ្សេងទៀត លើកលែងតែគយបច្ចេកទេស ប្រតិបត្តិការ សុវត្ថិភាពការគ្រប់គ្រងចរាចរណ៍ផ្លូវអាកាស ហេតុផលការពារបរិស្ថានឬការពារសុខភាព[illegible]អើងឬលើកលែងតែមានចែងក្នុងកិច្ចព្រមព្រៀងនេះ។



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៩- គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានចាត់ទុកថា ផ្ដល់សិទ្ធិហោះហើរណាមួយឡើយ ដូចខាងក្រោម៖

(ក) ទាក់ទងនឹងរដ្ឋសមាជិកអាស៊ាន សិទ្ធិហោះហើរនៃក្រុមហ៊ុនអាកាសចរណ៍របស់ខ្លួនក្នុងការទទួលយកនៅក្នុងរដ្ឋសមាជិកសហភាពអឺរ៉ុបណាមួយនូវអ្នកដំណើរ អីវ៉ាន់ ទំនិញ និង/ឬបញ្ញើប្រៃសណីយ៍ដែលបានដឹកជញ្ជូនសម្រាប់ជាថ្នូរនឹងលាភការឬការជួល និងកំណត់ទិសដៅសម្រាប់ចំណុចហោះហើរមួយផ្សេងទៀតនៅក្នុងរដ្ឋសមាជិកសហភាពអឺរ៉ុបដូចគ្នានោះ និង

(ខ) ទាក់ទងនឹងសហភាព សិទ្ធិហោះហើរនៃក្រុមហ៊ុនអាកាសចរណ៍របស់ខ្លួនក្នុងការទទួលយកនៅក្នុងរដ្ឋសមាជិកអាស៊ានណាមួយនូវអ្នកដំណើរ អីវ៉ាន់ ទំនិញ និង/ឬបញ្ញើប្រៃសណីយ៍ដែលបានដឹកជញ្ជូនសម្រាប់ជាថ្នូរនឹងលាភការឬការជួល និងកំណត់ទិសដៅសម្រាប់ចំណុចហោះហើរមួយផ្សេងទៀតនៅក្នុងរដ្ឋសមាជិកអាស៊ានដូចគ្នានោះ។

## មាត្រា៤
## ការអនុញ្ញាតប្រតិបត្តិការនិងការអនុញ្ញាតបច្ចេកទេស

១- នៅពេលបានទទួលពាក្យស្នើសុំសម្រាប់ការអនុញ្ញាតប្រតិបត្តិការពីក្រុមហ៊ុនអាកាសចរណ៍មួយនៃភាគីមួយផ្សេងទៀត ភាគីមួយត្រូវផ្ដល់ការអនុញ្ញាតប្រតិបត្តិការសមស្របនិងការអនុញ្ញាតបច្ចេកទេសដោយមានការពន្យារពេលអប្បបរមានៃនីតិវិធី ដោយផ្ដល់លក្ខខណ្ឌ ដូចខាងក្រោម៖

(ក) ក្នុងករណីក្រុមហ៊ុនអាកាសចរណ៍មួយរបស់រដ្ឋសមាជិកអាស៊ានមួយ៖

(i) ក្រុមហ៊ុនអាកាសចរណ៍មានកន្លែងប្រកបអាជីវកម្មជាគោលដើមរបស់ខ្លួននៅក្នុងរដ្ឋសមាជិកអាស៊ាននោះ ហើយមានអាជ្ញាបណ្ណធ្វើប្រតិបត្តិការដែលមានសុពលភាពស្របតាមច្បាប់នៃរដ្ឋសមាជិកអាស៊ានដូចគ្នានោះ។

(ii) ការគ្រប់គ្រងនិយ័តកម្មប្រកបដោយប្រសិទ្ធភាពនៃក្រុមហ៊ុនអាកាសចរណ៍ បានអនុវត្តនិងបានប្រកាន់ខ្ជាប់ដោយរដ្ឋសមាជិកអាស៊ាននោះ ដែលបានចេញវិញ្ញាបនបត្រប្រតិបត្តិករដឹកជញ្ជូនតាមផ្លូវអាកាសរបស់ខ្លួន ហើយអាជ្ញាធរមានសមត្ថកិច្ចបានកំណត់យ៉ាងច្បាស់ និង

(iii) ក្រុមហ៊ុនអាកាសចរណ៍ជាម្ចាស់កម្មសិទ្ធិដោយផ្ទាល់ឬតាមរយៈកម្មសិទ្ធិភាគច្រើន ហើយបានគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាពដោយរដ្ឋសមាជិកអាស៊ាននោះ ជាពលរដ្ឋរបស់ខ្លួន ឬទាំងពីរ។

(ខ) ក្នុងករណីក្រុមហ៊ុនអាកាសចរណ៍មួយរបស់សហភាព៖

(i) ក្រុមហ៊ុនអាកាសចរណ៍ត្រូវបានបង្កើតឡើងនៅលើដែនដីនៃសហភាព ហើយមានអាជ្ញាបណ្ណធ្វើប្រតិបត្តិការត្រឹមត្រូវស្របតាមច្បាប់របស់សហភាព។

(ii) ការគ្រប់គ្រងនិយ័តកម្មប្រកបដោយប្រសិទ្ធភាពនៃក្រុមហ៊ុនអាកាសចរណ៍ បានអនុវត្ត និងបានប្រកាន់ខ្ជាប់ដោយរដ្ឋសមាជិកសហភាពអឺរ៉ុបដែលទទួលខុសត្រូវក្នុងការចេញវិញ្ញាបនបត្រប្រតិបត្តិករដឹកជញ្ជូនតាមផ្លូវអាកាសរបស់ខ្លួន ហើយអាជ្ញាធរមានសមត្ថកិច្ចបានកំណត់យ៉ាងច្បាស់ និង

(iii) ក្រុមហ៊ុនអាកាសចរណ៍ជាម្ចាស់កម្មសិទ្ធិដោយផ្ទាល់ឬតាមរយៈកម្មសិទ្ធិភាគច្រើន ហើយបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដោយរដ្ឋសមាជិកសហភាពអឺរ៉ុបមួយឬច្រើន ដោយរដ្ឋភាគីផ្សេងទៀតនៃកិច្ចព្រមព្រៀងតំបន់សេដ្ឋកិច្ចអឺរ៉ុប ដោយប្រទេសស្វីស ដោយពលរដ្ឋនៃរដ្ឋទាំងនោះឬដោយការរួមបញ្ចូលគ្នា។

(គ) មាត្រា១៥និងមាត្រា១៦ កំពុងត្រូវបានអនុលោមតាម និង

(ឃ) ក្រុមហ៊ុនអាកាសចរណ៍បំពេញតាមលក្ខខណ្ឌដែលបានបញ្ញត្តិជាធម្មតាក្រោមច្បាប់និងបទប្បញ្ញត្តិនានា ដើម្បីស្នើសុំធ្វើប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ ដោយភាគីមួយពិចារណាលើការស្នើសុំនោះ។

២- ចំពោះគោលបំណងនៃមាត្រានេះនិងមាត្រា៥ កស្តុតាងនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃក្រុមហ៊ុនអាកាសចរណ៍មួយ រួមមានដូចខាងក្រោម៖

(ក) ក្រុមហ៊ុនអាកាសចរណ៍ជាប់ពាក់ព័ន្ធប្រើប្រាស់អាជ្ញាបណ្ណធ្វើប្រតិបត្តិការដែលមានសុពលភាព ឬលិខិតអនុញ្ញាតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីពាក់ព័ន្ធ និងត្រូវបំពេញតាមលក្ខណវិនិច្ឆ័យរបស់ភាគីដែលចេញអាជ្ញាបណ្ណធ្វើប្រតិបត្តិការ ឬលិខិតអនុញ្ញាតសម្រាប់ធ្វើប្រតិបត្តិការសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ និង

(ខ) ភាគីនោះមាននិងរក្សាកម្មវិធីត្រួតពិនិត្យសន្តិសុខនិងសុវត្ថិភាពសម្រាប់ក្រុមហ៊ុនអាកាសចរណ៍នោះ ដោយអនុលោមតាមស្តង់ដាអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ។

៣- នៅពេលផ្តល់ការអនុញ្ញាតធ្វើប្រតិបត្តិការនិងការអនុញ្ញាតបច្ចេកទេស ភាគីមួយត្រូវផ្តល់ជូនក្រុមហ៊ុនអាកាសចរណ៍ទាំងអស់នៃភាគីមួយផ្សេងទៀតដោយមិនរើសអើង។

៤- នៅពេលទទួលបានពាក្យស្នើសុំសម្រាប់ការអនុញ្ញាតធ្វើប្រតិបត្តិការពីក្រុមហ៊ុនអាកាសចរណ៍មួយរបស់ភាគីមួយផ្សេងទៀត ភាគីមួយត្រូវទទួលស្គាល់ភាពត្រឹមត្រូវនិង/ឬការកំណត់សញ្ជាតិដែលធ្វើឡើងដោយភាគីផ្សេងទៀតទាក់ទងនឹងក្រុមហ៊ុនអាកាសចរណ៍នោះ ដូចជា ប្រសិនបើការកំណត់នោះត្រូវបានធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចផ្ទាល់របស់ខ្លួន ហើយមិនត្រូវសាកសួរបន្ថែមលើបញ្ហាទាំងនោះឡើយ លើកលែងតែមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៥។ ដើម្បីជៀសវាងការសង្ស័យ កថាខណ្ឌនេះមិនគ្របដណ្តប់លើការទទួលស្គាល់នៃការកំណត់ដែលធ្វើឡើងទាក់ទងនឹងវិញ្ញាបនបត្រសុវត្ថិភាពឬអាជ្ញាបណ្ណនានា ការរៀបចំផ្នែកសន្តិសុខ ឬការធានារ៉ាប់រង។

## មាត្រា៥
## ការបដិសេធ ការដកហូត ការផ្អាកបណ្តោះអាសន្ន ឬការកម្រិត ការអនុញ្ញាតប្រតិបត្តិការ ឬការអនុញ្ញាតបច្ចេកទេស

១- ភាគីមួយអាចបដិសេធ ដកហូត ផ្អាកបណ្តោះអាសន្ន ដាក់លក្ខខណ្ឌលើ ឬកម្រិតការអនុញ្ញាតប្រតិបត្តិការ ឬការអនុញ្ញាតបច្ចេកទេសរបស់ក្រុមហ៊ុនអាកាសចរណ៍មួយរបស់ភាគីមួយផ្សេងទៀត ឬបើមិនដូច្នោះទេ បដិសេធ ផ្អាកបណ្តោះអាសន្ន ដាក់លក្ខខណ្ឌលើ ឬកម្រិតច្បាប់ប្រតិបត្តិការរបស់ក្រុមហ៊ុនអាកាសចរណ៍មួយរបស់ភាគីផ្សេងទៀត ដែល៖

(ក) ក្នុងករណីក្រុមហ៊ុនអាកាសចរណ៍មួយរបស់រដ្ឋសមាជិកអាស៊ានមួយ៖

(i) ក្រុមហ៊ុនអាកាសចរណ៍មិនមានកន្លែងប្រកបអាជីវកម្មជាគោលដើមរបស់ខ្លួននៅក្នុងរដ្ឋសមាជិកអាស៊ានមួយ ឬមិនមានអាជ្ញាបណ្ណធ្វើប្រតិបត្តិការត្រឹមត្រូវស្របតាមច្បាប់នៃរដ្ឋសមាជិកអាស៊ានដូចគ្នានោះ ឬ

(ii) ការគ្រប់គ្រងនិយ័តកម្មប្រកបដោយប្រសិទ្ធភាពនៃក្រុមហ៊ុនអាកាសចរណ៍មិនបានអនុវត្ត ឬមិនបានប្រកាន់ខ្ជាប់ដោយរដ្ឋសមាជិកអាស៊ានដែលបានចេញវិញ្ញាបនបត្រប្រតិបត្តិករដឹកជញ្ជូនតាមផ្លូវអាកាសរបស់ខ្លួន ឬអាជ្ញាធរមានសមត្ថកិច្ចមិនបានកំណត់អត្តសញ្ញាណច្បាស់លាស់ ឬ

(iii) ក្រុមហ៊ុនអាកាសចរណ៍មិនមែនជាម្ចាស់កម្មសិទ្ធិដោយផ្ទាល់ ឬតាមរយៈម្ចាស់កម្មសិទ្ធិភាគច្រើន ឬមិនបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដោយរដ្ឋសមាជិកអាស៊ាននោះនូវពលរដ្ឋរបស់ខ្លួនឬទាំងពីរ។

(ខ) ក្នុងករណីក្រុមហ៊ុនអាកាសចរណ៍មួយរបស់សហភាពៈ

(i) ក្រុមហ៊ុនអាកាសចរណ៍មិនត្រូវបានបង្កើតឡើងនៅលើដែនដីនៃសហភាព ឬមិនមានអាជ្ញាបណ្ណធ្វើប្រតិបត្តិការត្រឹមត្រូវស្របតាមច្បាប់សហភាព ឬ

(ii) ការគ្រប់គ្រងនិយ័តកម្មប្រកបដោយប្រសិទ្ធភាពនៃក្រុមហ៊ុនអាកាសចរណ៍មិនបានអនុវត្ត ឬមិនបានប្រកាន់ខ្ជាប់ដោយរដ្ឋសមាជិកសហភាពអឺរ៉ុបដែលទទួលខុសត្រូវក្នុងការចេញវិញ្ញាបនបត្រប្រតិបត្តិករដឹកជញ្ជូនតាមផ្លូវអាកាសរបស់ខ្លួន ឬអាជ្ញាធរមានសមត្ថកិច្ចមិនបានកំណត់អត្តសញ្ញាណច្បាស់លាស់ ឬ

(iii) ក្រុមហ៊ុនអាកាសចរណ៍មិនមែនជាម្ចាស់កម្មសិទ្ធិដោយផ្ទាល់ ឬតាមរយៈម្ចាស់កម្មសិទ្ធិភាគច្រើន ឬមិនបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដោយរដ្ឋសមាជិកសហភាពអឺរ៉ុបមួយឬច្រើន ដោយរដ្ឋភាគីផ្សេងទៀតនៃកិច្ចព្រមព្រៀងតំបន់សេដ្ឋកិច្ចអឺរ៉ុប ដោយប្រទេសស្វ៊ីស ដោយពលរដ្ឋនៃរដ្ឋទាំងនោះ ឬដោយការរួមបញ្ចូលគ្នា ឬ

(គ) ក្រុមហ៊ុនអាកាសចរណ៍មិនគោរពតាមច្បាប់និងបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា៧។

២- នៅពេលភាគីមួយមានមូលហេតុសមហេតុផលដោយជឿជាក់ថា ក្រុមហ៊ុនអាកាសចរណ៍មួយរបស់ភាគីមួយផ្សេងទៀតស្ថិតក្នុងស្ថានភាពណាមួយ ដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ភាគីនោះ អាចស្នើសុំការពិគ្រោះយោបល់ជាមួយភាគីផ្សេងទៀតបាន។

៣- ការពិគ្រោះយោបល់បែបនេះត្រូវចាប់ផ្ដើមឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងមិនយូរជាង៣០(សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានសំណើសម្រាប់ការពិគ្រោះយោបល់។ ការខកខានក្នុងការសម្រេចបាននូវកិច្ចព្រមព្រៀងដែលពេញចិត្តក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ ឬរយៈពេលដែលបានព្រមព្រៀងគ្នាចាប់ពីថ្ងៃចាប់ផ្ដើមនៃការពិគ្រោះយោបល់នេះ ឬការខកខានក្នុងការអនុវត្តការកែតម្រូវដែលបានព្រមព្រៀងនោះ នឹងក្លាយជាហេតុផលសម្រាប់ភាគីដែលបានស្នើសុំការពិគ្រោះយោបល់ដើម្បីចាត់វិធានការក្នុងការបដិសេធ ដកហូត ផ្អាកបណ្ដោះអាសន្ន ដាក់លក្ខខណ្ឌលើ ឬកម្រិតការអនុញ្ញាតប្រតិបត្តិការ ឬការអនុញ្ញាតបច្ចេកទេសរបស់ក្រុមហ៊ុនអាកាសចរណ៍ដែលពាក់ព័ន្ធ ឬបើមិនដូច្នេះទេ ការបដិសេធ ផ្អាកបណ្ដោះអាសន្ន ដាក់លក្ខខណ្ឌលើ ឬកម្រិតការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនអាកាសចរណ៍ពាក់ព័ន្ធ ដើម្បីធានាបាននូវការអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៤ និងមាត្រា៧។

៤- ទោះបីជាមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រានេះក៏ដោយ ក្នុងករណីដែលយោងតាមកថាខណ្ឌទី១ ចំណុច (ក) នៃមាត្រានេះ ភាគីមួយអាចចាត់វិធានការភ្លាមៗឬបន្ទាន់ នៅពេលមានតម្រូវការក្នុងគ្រាអាសន្ន

ឬដើម្បីទប់ស្កាត់ការមិនអនុលោមតាមច្បាប់តទៅទៀត។ ដើម្បីជៀសវាងការសង្ស័យ ការមិនអនុលោមតាមច្បាប់តទៅទៀត តម្រូវឱ្យមានការសាកសួរចំពោះការមិនអនុលោមតាមច្បាប់ ដែលបានលើកឡើងរវាងអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគីពាក់ព័ន្ធ។

៥- មាត្រានេះមិនកម្រិតសិទ្ធិរបស់ភាគីណាមួយក្នុងការបដិសេធ ដកហូត ផ្អាកបណ្តោះអាសន្ន ដាក់លក្ខខណ្ឌលើ ឬកម្រិតការអនុញ្ញាតប្រតិបត្តិការ ឬការអនុញ្ញាតបច្ចេកទេសរបស់ក្រុមហ៊ុនអាកាសចរណ៍មួយឬក្រុមហ៊ុនអាកាសចរណ៍ច្រើនរបស់ភាគីមួយផ្សេងទៀត ឬបើមិនដូច្នោះទេ ការបដិសេធ ផ្អាកបណ្តោះអាសន្ន ដាក់លក្ខខណ្ឌលើ ឬកម្រិតការធ្វើប្រតិបត្តិការនៃក្រុមហ៊ុនអាកាសចរណ៍មួយឬក្រុមហ៊ុនអាកាសចរណ៍ច្រើនរបស់ភាគីមួយផ្សេងទៀត ត្រូវស្របតាមបទប្បញ្ញត្តិនៃមាត្រា៨ មាត្រា១៥ មាត្រា១៦ ឬមាត្រា២៥។

## មាត្រា៦
## សេរីភាវូបនីយកម្មនៃភាពជាម្ចាស់កម្មសិទ្ធិ និងការគ្រប់គ្រង

រដ្ឋភាគីទទួលស្គាល់តាមរយៈការរីកចម្រើននៃសេរីភាវូបនីយកម្មនៃភាពជាម្ចាស់កម្មសិទ្ធិ និងការគ្រប់គ្រងលើក្រុមហ៊ុនអាកាសចរណ៍រៀងៗខ្លួន។ រដ្ឋភាគីអាចស្វែងយល់នៅក្នុងគណៈកម្មាធិការចម្រុះដែលមានចែងក្នុងមាត្រា២៣ នៅឱកាសសមស្រប ការធ្វើបដិការសេរីភាវូបនីយកម្មនៃភាពជាម្ចាស់កម្មសិទ្ធិ និងការគ្រប់គ្រងក្រុមហ៊ុនអាកាសចរណ៍។ បន្ទាប់មក គណៈកម្មាធិការចម្រុះអាចស្នើសុំធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ ដោយអនុលោមតាមកថាខណ្ឌទី៤ ចំណុច(ច)នៃមាត្រា២៣និងមាត្រា២៨។

## មាត្រា៧
## ការអនុលោមតាមច្បាប់និងបទប្បញ្ញត្តិនានា

១- ខណៈពេលនៃការចូល ការស្ថិតនៅក្នុង ឬការចាកចេញពីដែនដីនៃភាគីមួយផ្សេងទៀត ច្បាប់និងបទប្បញ្ញត្តិនានាទាក់ទងនឹងការអនុញ្ញាតឱ្យចូល ការធ្វើប្រតិបត្តិការនៅក្នុង ឬការចេញដំណើរពីដែនដីរបស់ខ្លួននៃអាកាសយានដែលបានចូលរួមក្នុងការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ ត្រូវអនុលោមតាមដោយក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីមួយ។

២- ខណៈពេលនៃការចូល ការស្ថិតនៅក្នុង ឬការចាកចេញពីដែនដីនៃភាគីមួយផ្សេងទៀត ច្បាប់និងបទប្បញ្ញត្តិនានារបស់ខ្លួនទាក់ទងនឹងការអនុញ្ញាតឱ្យចូល ការធ្វើប្រតិបត្តិការនៅក្នុង ឬការចេញដំណើរពីដែនដីរបស់ខ្លួននៃអ្នកដំណើរ ក្រុមអាកាសយានិក អីវ៉ាន់ ទំនិញ និង/ឬបញ្ញើប្រៃសណីយ៍នៅលើអាកាសយាន(រួមទាំងបទប្បញ្ញត្តិនានាទាក់ទងនឹងការចូល ការជម្រះបញ្ជី អន្តោប្រវេសន៍ លិខិតឆ្លងដែន គយ និងចត្តាឡីស័ក ឬក្នុងករណីបញ្ញើប្រៃសណីយ៍ បទប្បញ្ញត្តិប្រៃសណីយ៍) ត្រូវអនុលោមតាមឬក្នុងនាមអ្នកដំណើរ ក្រុមអាកាសយានិក អីវ៉ាន់ ទំនិញ និងបញ្ញើប្រៃសណីយ៍របស់ក្រុមហ៊ុនអាកាសចរណ៍នានានៃភាគីមួយ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៣- ភាគីនីមួយៗត្រូវអនុញ្ញាតឱ្យក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីមួយផ្សេងទៀត ចាត់វិធានការដើម្បីធានាថា មានតែបុគ្គលមានឯកសារធ្វើដំណើរដែលបានតម្រូវប៉ុណ្ណោះ សម្រាប់ការចូលឬការឆ្លងកាត់តាមដែនដីនៃភាគីផ្សេងទៀត ដែលត្រូវអនុញ្ញាតឱ្យដឹកជញ្ជូននៅក្នុងដែនដីរបស់ខ្លួន។

## មាត្រា៨
## ការប្រកួតប្រជែងដោយស្មើភាព

១- រដ្ឋភាគីព្រមព្រៀងគ្នាថា ជាគោលបំណងរួមរបស់ខ្លួន ដើម្បីឱ្យមានបរិយាកាសស្មើភាពនិងប្រកួតប្រជែងដែលក្នុងនោះក្រុមហ៊ុនអាកាសចរណ៍នានារបស់រដ្ឋភាគីទទួលបានកាលានុវត្តភាពដោយស្មើភាពនិងសមភាពដើម្បីប្រកួតប្រជែងក្នុងការផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស។

២- ដើម្បីសម្រេចបាននូវគោលបំណងដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ រដ្ឋភាគីត្រូវ៖

(ក) ទទួលយកឬប្រកាន់ខ្ជាប់ច្បាប់ប្រកួតប្រជែង។

(ខ) បង្កើតឬប្រកាន់ខ្ជាប់នូវអាជ្ញាធរប្រកួតប្រជែងមួយដែលអាចដំណើរការបានដោយឯករាជ្យ មានអំណាចនិងធនធានចាំបាច់គ្រប់គ្រាន់ ដែលត្រូវអនុវត្តច្បាប់ប្រកួតប្រជែងរបស់ភាគីមួយប្រកបដោយប្រសិទ្ធភាព។ សេចក្តីសម្រេចរបស់អាជ្ញាធរប្រកួតប្រជែង នឹងត្រូវប្តឹងទៅឧទ្ធរណ៍ និងពិនិត្យឡើងវិញដោយតុលាការឬសាលាក្តីនៃភាគីនោះ។

(គ) លុបបំបាត់នៅក្នុងយុត្តាធិការរៀងៗខ្លួនរបស់រដ្ឋភាគីនូវគ្រប់ទម្រង់នៃការរើសអើងឬការអនុវត្តមិនស្មើភាព ដែលជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់កាលានុវត្តភាពស្មើភាពនិងសមភាពរបស់ក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីមួយផ្សេងទៀត ក្នុងការប្រកួតប្រជែង សម្រាប់ការផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស។ ដើម្បីជៀសវាងការសង្ស័យ គ្មានបទប្បញ្ញត្តិណាមួយចែងក្នុងកថាខណ្ឌទី២ ចំណុច(គ)នៃមាត្រានេះ ត្រូវរួមបញ្ចូលទាំងការអនុវត្តដែលមានចែងក្នុងកថាខណ្ឌទី១ ចំណុច(ធ)នៃមាត្រា២ និង

(ឃ) មិនផ្តល់ឬប្រកាន់ខ្ជាប់ការឧបត្ថម្ភធនដល់ក្រុមហ៊ុនអាកាសចរណ៍ណាមួយ ប្រសិនបើការឧបត្ថម្ភធនទាំងនេះនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កាលានុវត្តភាពស្មើភាពនិងសមភាពរបស់ក្រុមហ៊ុនអាកាសចរណ៍របស់ភាគីមួយផ្សេងទៀត ក្នុងការប្រកួតប្រជែង សម្រាប់ការផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស។

៣- ទោះបីជាមានចែងក្នុងកថាខណ្ឌទី២ ចំណុច(ឃ)នៃមាត្រានេះក៏ដោយ ចំណុចខាងក្រោមអាចត្រូវបានផ្តល់ឱ្យ៖

(ក) ការគាំទ្រដល់ក្រុមហ៊ុនអាកាសចរណ៍នានាដែលក្ស័យធនឬជួបវិបត្តិ លុះត្រាតែ៖

(i) ការគាំទ្រនេះ គឺមានលក្ខខណ្ឌលើផែនការរៀបចំរចនាសម្ព័ន្ធឡើងវិញដែលអាចជឿទុកចិត្តបាន ដោយផ្អែកលើការសន្មតជាក់ស្តែងក្នុងគោលបំណងធានាឱ្យមានការត្រឡប់មកវិញនៃក្រុមហ៊ុនអាកាសចរណ៍ដែលមានវិបត្តិក្នុងរយៈពេលដ៏សមរម្យមួយ ចំពោះលទ្ធភាពជោគជ័យយូរអង្វែង និង

(ii) ក្រុមហ៊ុនអាកាសចរណ៍ដែលពាក់ព័ន្ធវិនិយោគិនឬម្ចាស់ភាគហ៊ុនធំរបស់ខ្លួនបានរួមចំណែកយ៉ាងសំខាន់ ចំពោះការចំណាយលើការរៀបចំរចនាសម្ព័ន្ធឡើងវិញ។

(ខ) ជំនួយសាច់ប្រាក់បណ្តោះអាសន្នដល់ក្រុមហ៊ុនអាកាសចរណ៍ដែលមានវិបត្តិក្នុងទម្រង់ជាប្រាក់កម្ចី ឬការធានាប្រាក់កម្ចីមានកម្រិតកំណត់ចំពោះចំនួនដែលត្រូវការដើម្បីរក្សាក្រុមហ៊ុនអាកាសចរណ៍ដែលពាក់ព័ន្ធក្នុងអាជីវកម្មសម្រាប់ពេលវេលាចាំបាច់ ក្នុងការរៀបចំរចនាសម្ព័ន្ធឡើងវិញ ឬផែនការទូទាត់។

(គ) លុះត្រាតែការឧបត្ថម្ភធនត្រូវបានកម្រិតកំណត់ត្រឹមចំនួនអប្បបរមាដែលត្រូវការ ដើម្បីសម្រេចបាននូវគោលបំណងរបស់ខ្លួន ហើយថា ផលប៉ះពាល់លើការផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋភាគីត្រូវបានរក្សាទុកជាអប្បបរមា៖

(i) ការឧបត្ថម្ភធនដើម្បីកែលម្អនូវការខូចខាតដែលបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ ឬការកើតឡើងជាយថាហេតុ។

(ii) ការឧបត្ថម្ភធនដើម្បីដោះស្រាយការរំខានយ៉ាងធ្ងន់ធ្ងរផ្នែកសេដ្ឋកិច្ចនៃរដ្ឋភាគីមួយក្នុងចំណោមបណ្តារដ្ឋភាគីទាំងអស់។

(iii) ការឧបត្ថម្ភធនដល់ក្រុមហ៊ុនអាកាសចរណ៍នានាដែលបានប្រគល់ឱ្យនូវប្រតិបត្តិការនៃកាតព្វកិច្ចសេវាកម្មសាធារណៈចាំបាច់ ដែលបានកំណត់យ៉ាងច្បាស់ ដើម្បីបំពេញតម្រូវការដឹកជញ្ជូនសំខាន់ៗរបស់ប្រជាជន ដែលមិនអាចបំពេញបានដោយកម្លាំងទីផ្សារតែម្នាក់ឯង លុះត្រាតែការឧបត្ថម្ភធនទាំងនេះត្រូវបានកម្រិតកំណត់ចំពោះប្រាក់កម្រៃសមរម្យសម្រាប់ការផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសពាក់ព័ន្ធ និង

(iv) ការឧបត្ថម្ភធនដល់ក្រុមហ៊ុនអាកាសចរណ៍ទាំងអស់ និងមិនត្រូវបានកំណត់តាមផ្លូវច្បាប់ ហើយជាក់ស្តែងត្រូវបានកំណត់ចំពោះក្រុមហ៊ុនអាកាសចរណ៍មួយចំនួន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៤- រដ្ឋភាគីត្រូវធានាថា ក្រុមហ៊ុនអាកាសចរណ៍នីមួយៗរបស់ខ្លួន ដែលធ្វើសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងនេះ បោះពុម្ពផ្សព្វផ្សាយឬរៀបចំ និងផ្តល់តាមការស្នើសុំរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងភ្ជាប់មកជាមួយរបាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយឯករាជ្យនិងស្របតាមគណនេយ្យដែលទទួលស្គាល់ជាអន្តរជាតិនិងស្តង់ដានៃការបង្ហាញហិរញ្ញវត្ថុសាជីវកម្ម ដូចជាស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ។ ក្នុងករណីណាក៏ដោយ ការឧបត្ថម្ភធនត្រូវកំណត់ដោយឡែកពីគ្នានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៥- ភាគីនីមួយៗត្រូវធានាថា ការដោះដូរទំនិញដោយផ្អែកលើលក្ខខណ្ឌពាណិជ្ជកម្មស្មើនឹងលក្ខខណ្ឌដែលធ្វើឡើងក្នុងការដោះដូរទំនិញជាធម្មតារវាងក្រុមហ៊ុនអាកាសចរណ៍នានារបស់ខ្លួននិងអ្នកផ្គត់ផ្គង់ទំនិញនិងសេវាកម្មដែលជាសហគ្រាសគ្រប់គ្រងដោយរដ្ឋ(ក្នុងទម្រង់បែបណាក៏ដោយ)នៃភាគីនោះសម្រាប់តែការដឹកជញ្ជូនតាមផ្លូវអាកាស។

៦- ភាគីនីមួយៗត្រូវផ្តល់ឱ្យភាគីផ្សេងទៀត ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ តាមសំណើរបស់ភាគីមួយផ្សេងទៀត ឬរយៈពេលដែលបានព្រមព្រៀងគ្នាជាមួយនឹងព័ត៌មានពាក់ព័ន្ធ ដែលអាចត្រូវបានស្នើសុំដោយសមហេតុផលដើម្បីធានាថាបទប្បញ្ញត្តិនៃមាត្រានេះកំពុងត្រូវបានអនុវត្ត។ ការស្នើសុំនេះអាចរួមបញ្ចូលព័ត៌មានបន្ថែមទាក់ទងនឹងការឧបត្ថម្ភធននិងចំណុចផ្សេងទៀតដែលបានបញ្ជាក់ក្នុងកថាខណ្ឌទី៤និងកថាខណ្ឌទី៥នៃមាត្រានេះ។ ព័ត៌មានបែបនេះត្រូវរក្សាការសម្ងាត់ដោយភាគីទទួលព័ត៌មាន ប្រសិនបើមានការស្នើសុំ។

៧- ប្រសិនបើរដ្ឋភាគីមួយឬច្រើន(តទៅនេះហៅកាត់ជារួម ថា «ភាគីផ្តួចផ្តើម» សម្រាប់គោលបំណងនៃមាត្រានេះ) ពិនិត្យថា កាលានុវត្តភាពប្រកួតប្រជែងដោយយុត្តិធម៌និងស្មើភាពនៃក្រុមហ៊ុនអាកាសចរណ៍របស់ខ្លួនត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដោយៈ

(ក) ការរើសអើងឬការអនុវត្តអយុត្តិធម៌ ត្រូវបានហាមឃាត់ក្នុងកថាខណ្ឌទី២ ចំណុច(គ)នៃមាត្រានេះ។

(ខ) ការឧបត្ថម្ភធនដែលត្រូវបានហាមឃាត់ក្នុងកថាខណ្ឌទី២ ចំណុច(ឃ)នៃមាត្រានេះ ក្រៅពីអ្វីដែលមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រានេះ ឬ

(គ) ការខកខានក្នុងការផ្តល់ព័ត៌មានដែលបានស្នើសុំក្នុងកថាខណ្ឌទី៦នៃមាត្រានេះ។

អាចបន្តអនុលោមតាមកថាខណ្ឌទី៨ដល់កថាខណ្ឌទី១០នៃមាត្រានេះ។

៨- ភាគីផ្តួចផ្តើមត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរសម្រាប់ការពិគ្រោះយោបល់ទៅកាន់ភាគីឬរដ្ឋភាគីដែលពាក់ព័ន្ធ(តទៅនេះហៅកាត់ជារួម ថា «ភាគីឆ្លើយតប» សម្រាប់គោលបំណងនៃមាត្រានេះ)។ ការពិគ្រោះយោបល់ត្រូវចាប់ផ្តើមក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើ លើកលែងតែមានការព្រមព្រៀងពីរដ្ឋភាគីទាំងពីរ។



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៩- ប្រសិនបើភាគីផ្ដួចផ្ដើមនិងភាគីឆ្លើយតបមិនបានព្រមព្រៀងគ្នាលើបញ្ហានេះ ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើសុំសម្រាប់ការពិគ្រោះយោបល់ ភាគីផ្ដួចផ្ដើមអាចចាត់វិធានការជំទាស់នឹងក្រុមហ៊ុនអាកាសចរណ៍ទាំងអស់ឬមួយចំនួនរបស់ភាគីឆ្លើយតបដែលបានចូលរួមក្នុងការប្រព្រឹត្តនៃការប្រកួតប្រជែងឬដែលបានទទួលផលប្រយោជន៍ពីការរើសអើង ការអនុវត្តមិនស្មើភាព ឬការឧបត្ថម្ភធនដែលស្ថិតក្នុងមន្ទិលសង្ស័យនេះ។

១០- វិធានការដែលបានធ្វើឡើងដោយអនុលោមតាមកថាខណ្ឌទី៩នៃមាត្រានេះ ត្រូវមានភាពសមស្រប សមាមាត្រ និងរឹតត្បិតក្នុងវិសាលភាពរបស់ខ្លួននិងរយៈពេលដែលចាំបាច់យ៉ាងតឹងរ៉ឹង ដើម្បីកាត់បន្ថយការខូតខាតដល់ក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីផ្ដួចផ្ដើម និងដកចេញអត្ថប្រយោជន៍ហួសហេតុដែលទទួលបានដោយក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីឆ្លើយតប។

១១- ក្នុងករណីដែលបញ្ហាទាក់ទងនឹងមាត្រានេះ សំដៅដល់នីតិវិធីដោះស្រាយវិវាទដែលមានចែងក្នុងមាត្រា២៥៖

(ក) ទោះបីជាមានចែងក្នុងកថាខណ្ឌទី២និងកថាខណ្ឌទី៣នៃមាត្រា២៥ក៏ដោយ វិវាទអាចត្រូវបានបញ្ជូនទៅបុគ្គលឬស្ថាប័នណាមួយភ្លាមៗ ដើម្បីធ្វើការសម្រេចឬបញ្ជូនទៅមជ្ឈត្តកម្ម និង

(ខ) ការកំណត់ពេលវេលាដែលមានចែងក្នុងកថាខណ្ឌទី១០ កថាខណ្ឌទី១១ និងកថាខណ្ឌទី១២នៃមាត្រា២៥ ត្រូវបានកាត់បន្ថយនៅត្រឹមពាក់កណ្ដាល។

១២- គ្មានបទប្បញ្ញត្តិណាមួយចែងក្នុងកិច្ចព្រមព្រៀងនេះដែលអាចប៉ះពាល់ កម្រិតច្បាប់ ឬធ្វើឱ្យអន្តរាយដល់សិទ្ធិឬអំណាចរបស់អាជ្ញាធរប្រកួតប្រជែងនៃរដ្ឋភាគី ឬរបស់តុលាការ ឬសាលាក្ដី ដែលពិនិត្យលើសេចក្ដីសម្រេចរបស់អាជ្ញាធរទាំងនោះឡើយ។ រាល់សកម្មភាពដែលធ្វើឡើងអនុលោមតាមកថាខណ្ឌទី៩នៃមាត្រានេះ ដោយភាគីផ្ដួចផ្ដើម នឹងមិនមានការលម្អៀងចំពោះសកម្មភាពនិងវិធានការនានាដែលអាចធ្វើទៅបានដោយអាជ្ញាធរនិងតុលាការ ឬសាលាក្ដីពាក់ព័ន្ធ រួមទាំងភាគីផ្ដួចផ្ដើម។ រាល់សកម្មភាពនិងវិធានការរបស់អាជ្ញាធរប្រកួតប្រជែងនៃរដ្ឋភាគី និងតុលាការ ឬសាលាក្ដីដែលពិនិត្យលើសេចក្ដីសម្រេចរបស់អាជ្ញាធរទាំងនោះ នឹងត្រូវដកចេញពីយន្តការដោះស្រាយវិវាទដែលមានចែងក្នុងមាត្រា២៥។

## មាត្រា៩
## ការធ្វើអាជីវកម្ម

១- រដ្ឋភាគីព្រមព្រៀងគ្នាថា ឧបសគ្គក្នុងការធ្វើអាជីវកម្មដោយក្រុមហ៊ុនអាកាសចរណ៍នានារបស់ខ្លួនជួបប្រទះ [illegible]យោជន៍សម្រេចបានដោយកិច្ចព្រមព្រៀងនេះ។ រដ្ឋភាគីព្រមព្រៀងគ្នាសហការក្នុងការលុបបំបាត់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

នូវឧបសគ្គ ដែលឧបសគ្គបែបនេះអាចរារាំងដល់ប្រតិបត្តិការផ្នែកពាណិជ្ជកម្ម បង្កើតការបង្ខូចទ្រង់ទ្រាយដល់ការប្រកួតប្រជែង ឬប៉ះពាល់ដល់កាលានុវត្តភាពសមភាពក្នុងការប្រកួតប្រជែង។

២- គណៈកម្មាធិការចម្រុះត្រូវត្រួតពិនិត្យវឌ្ឍនភាពដែលបានធ្វើឡើងក្នុងការដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវឧបសគ្គក្នុងការធ្វើអាជីវកម្មដែលជួបប្រទះដោយក្រុមហ៊ុនអាកាសចរណ៍នានារបស់រដ្ឋភាគី។

## មាត្រា១០
## ប្រតិបត្តិការផ្នែកពាណិជ្ជកម្ម

១- រដ្ឋភាគីផ្តល់សិទ្ធិដល់គ្នាទៅវិញទៅមកដែលមានចែងក្នុងកថាខណ្ឌទី២ដល់កថាខណ្ឌទី១៧នៃមាត្រានេះ។ ក្រុមហ៊ុនអាកាសចរណ៍នានារបស់រដ្ឋភាគីមិនត្រូវតម្រូវឱ្យហាមឃាត់ដៃគូក្នុងស្រុកសម្រាប់គោលបំណងនៃមាត្រានេះទេ។

### តំណាងក្រុមហ៊ុនអាកាសចរណ៍

២- ក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីនីមួយៗ ត្រូវបានអនុញ្ញាតឱ្យបង្កើតការិយាល័យនិងគ្រឿងបរិក្ខារនានាដោយសេរីនៅលើដែនដីនៃភាគីមួយផ្សេងទៀតតាមការចាំបាច់ ដើម្បីផ្តល់សេវាកម្មនៅក្រោមកិច្ចព្រមព្រៀងនេះតាមលទ្ធភាពដែលអាចអនុវត្តបាននិងដោយគ្មានការរើសអើង។

៣- ដោយមិនមានការលម្អៀងចំពោះបទប្បញ្ញត្តិសុវត្ថិភាពនិងសន្តិសុខ ដែលគ្រឿងបរិក្ខារទាំងនេះមានទីតាំងនៅក្នុងអាកាសយានដ្ឋាន គ្រឿងបរិក្ខារអាចកម្រិតកំណត់ទៅតាមទំហំទីតាំងដែលទំនេរ។

៤- ក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីនីមួយៗ ត្រូវបានអនុញ្ញាតដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនានារបស់ភាគីមួយផ្សេងទៀតទាក់ទងនឹងការចូល ការស្នាក់នៅ និងការបំពេញការងារ ដើម្បីនាំយកចូលនិងរក្សាទុកនៅក្នុងដែនដីនៃភាគីផ្សេងទៀត នូវអ្នកគ្រប់គ្រង ផ្នែកលក់ ផ្នែកបច្ចេកទេស ផ្នែកប្រតិបត្តិការ និងបុគ្គលិកឯកទេសផ្សេងទៀតដែលតម្រូវឱ្យគាំទ្របម្រើដល់ការដឹកជញ្ជូនតាមផ្លូវអាកាស។ រដ្ឋភាគីត្រូវដំណើរការឱ្យបានឆាប់នូវការផ្តល់សិទ្ធិការងារតាមតម្រូវការសម្រាប់បុគ្គលិកដែលបម្រើការងារនៅក្នុងការិយាល័យដូចមានចែងក្នុងកថាខណ្ឌនេះ រួមទាំងអ្នកដែលកំពុងបំពេញភារកិច្ចបណ្តោះអាសន្នមួយចំនួនដែលស្ថិតនៅក្រោមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ការបម្រើសេវាកម្មលើផ្ទៃដី

៥- (ក)ដោយមិនមានការលម្អៀងចំពោះកថាខណ្ឌទី៥ ចំណុច(ខ)នៃមាត្រានេះ ក្រុមហ៊ុនអាកាសចរណ៍នៃភាគីនីមួយៗ ទាក់ទងនឹងការបម្រើសេវាកម្មលើផ្ទៃដីនៅក្នុងដែនដីនៃភាគីមួយផ្សេងទៀត ត្រូវបានអនុញ្ញាតឱ្យ៖



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

(i) អនុវត្តការធ្វើសេវាកម្មលើផ្ទៃដីផ្ទាល់ខ្លួន(ការបម្រើសេវាកម្មដោយខ្លួនឯង) ឬ

(ii) ជ្រើសរើសក្នុងចំណោមអ្នកផ្គត់ផ្គង់ប្រកួតប្រជែង ដែលអ្នកផ្គត់ផ្គង់ទាំងនោះកំពុងផ្តល់ការធ្វើសេវាកម្មលើផ្ទៃដីទាំងស្រុងឬមួយផ្នែក ស្របតាមច្បាប់និងបទប្បញ្ញត្តិរបស់ភាគីពាក់ព័ន្ធ។

(ខ) កថាខណ្ឌទី៥ ចំណុច(ក)នៃមាត្រានេះ ត្រូវគិតអំពីសុវត្ថិភាព សន្តិសុខ និងឧបសគ្គខាងរាងកាយ ឬប្រតិបត្តិការ។ ភាគីពាក់ព័ន្ធត្រូវធានាថា សេវាកម្មទាំងអស់នោះមានទាំងលើមូលដ្ឋានស្មើភាព និងគ្រប់គ្រាន់សម្រាប់ក្រុមហ៊ុនអាកាសចរណ៍ទាំងអស់ ហើយដែលតម្លៃសេវាកម្មទាំងនោះ ត្រូវបានកំណត់ស្របតាមលក្ខណវិនិច្ឆ័យដែលពាក់ព័ន្ធ មិនលម្អៀង មានតម្លាភាព និងមិនមានការរើសអើង នៅពេលដែលការគិតពិចារណាទាំងនោះ កម្រិត ទប់ស្កាត់ ឬរាំងការបម្រើសេវាកម្មដោយខ្លួនឯង និងមិនមានការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពរវាងអ្នកផ្គត់ផ្គង់ដែលផ្តល់សេវាកម្មលើផ្ទៃដី ។

## ការបែងចែកស្លតនៅអាកាសយានដ្ឋាន

៦- ភាគីនីមួយៗត្រូវធានាថា បទប្បញ្ញត្តិ គោលការណ៍ណែនាំ និងនីតិវិធីរបស់ខ្លួនសម្រាប់ការបែងចែកស្លតនៅអាកាសយានដ្ឋាននានានៅក្នុងដែនដីរបស់ខ្លួន ត្រូវបានអនុវត្តប្រកបដោយតម្លាភាព ប្រសិទ្ធភាព មិនមានការរើសអើង និងបានទាន់ពេលវេលា។

## ផែនការប្រតិបត្តិការ កម្មវិធី និងកាលវិភាគហោះហើរ

៧- ការជូនដំណឹងអំពីផែនការប្រតិបត្តិការ កម្មវិធី ឬកាលវិភាគហោះហើរសម្រាប់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសដែលប្រតិបត្តិការក្រោមកិច្ចព្រមព្រៀងនេះ អាចត្រូវបានតម្រូវដោយភាគីមួយ ដើម្បីផ្តល់ឱ្យអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនសម្រាប់គោលបំណងជាព័ត៌មានតែប៉ុណ្ណោះ។ ប្រសិនបើភាគីមួយមានតម្រូវការនៃការជូនដំណឹងបែបនេះ ភាគីនោះត្រូវកាត់បន្ថយបន្ទុករដ្ឋបាលដែលទាក់ទងនឹងតម្រូវការនិងនីតិវិធីនានានៃការជូនដំណឹងរបស់ខ្លួន ដែលជាបន្ទុកចំណាយរបស់អន្តរការីដឹកជញ្ជូនតាមផ្លូវអាកាសនិងក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីមួយផ្សេងទៀត។

## ការលក់ ការចំណាយក្នុងស្រុក និងការផ្ទេរប្រាក់

៨- ក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីនីមួយៗ ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការលក់នៃការដឹកជញ្ជូនតាមផ្លូវអាកាសនិងសេវាកម្មនានាដែលពាក់ព័ន្ធ ទាំងរបស់ខ្លួននិងក្រុមហ៊ុនអាកាសចរណ៍ណាមួយផ្សេងទៀតនៅ



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

48

ក្នុងដែនដីនៃភាគីមួយផ្សេងទៀត។ ក្រុមហ៊ុនអាកាសចរណ៍មានឆន្ទានុសិទ្ធិក្នុងការធ្វើដោយផ្ទាល់ និង/ឬតាមរយៈភ្នាក់ងារលក់នានារបស់ខ្លួន អន្តរការីនានាផ្សេងទៀតដែលត្រូវបានតែងតាំងដោយក្រុមហ៊ុនអាកាសចរណ៍ ឬតាមរយៈអ៊ីនធឺណិត ឬបណ្តាញផ្សេងទៀតដែលមាន។ ការលក់និងការទិញការដឹកជញ្ជូននោះនិងសេវាកម្មពាក់ព័ន្ធ ត្រូវអនុញ្ញាតជារូបិយបណ្ណនៃដែនដីសម្រាប់ការលក់ ឬការទិញ ឬជារូបិយបណ្ណដែលអាចប្តូរបានដោយសេរី។

៩- ក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីនីមួយៗ ត្រូវបានអនុញ្ញាតឱ្យចំណាយសម្រាប់ការចំណាយក្នុងស្រុក រួមទាំងការទិញប្រេងឥន្ធនៈនៅក្នុងដែនដីនៃភាគីមួយផ្សេងទៀត ជារូបិយបណ្ណក្នុងស្រុក ឬតាមឆន្ទានុសិទ្ធិរបស់ខ្លួនជារូបិយបណ្ណដែលអាចប្តូរបានដោយសេរីតាមអត្រាទីផ្សារនៃការប្តូររូបិយបណ្ណ។

១០- (ក) ក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីនីមួយៗ ត្រូវបានអនុញ្ញាតតាមការចង់បានដើម្បីប្តូរប្រាក់ចំណូលក្នុងស្រុកទៅជារូបិយបណ្ណដែលអាចប្តូរបានដោយសេរី និងបញ្ជូនប្រាក់ចំណូលនេះនៅពេលណាក៏បាន តាមមធ្យោបាយណាមួយពីដែនដីនៃភាគីមួយផ្សេងទៀតទៅកាន់ប្រទេសដែលខ្លួនជ្រើសរើស។ ការប្តូរនិងការផ្ទេរប្រាក់ត្រូវអនុញ្ញាតភ្លាមៗ ដោយមិនមានការរឹតត្បិត ឬការបង់ពន្ធលើតម្លៃទីផ្សារនៃអត្រាប្តូរប្រាក់ ដែលអាចអនុវត្តចំពោះធុរកិច្ចបច្ចុប្បន្ននិងការផ្ទេរប្រាក់នៅកាលបរិច្ឆេទក្រុមហ៊ុនអាកាសចរណ៍ធ្វើការស្នើសុំដំបូងសម្រាប់ការផ្ទេរប្រាក់ ហើយមិនត្រូវគិតថ្លៃអ្វីឡើយ លើកលែងតែការផ្ទេរប្រាក់ដែលធ្វើឡើងជាធម្មតាដោយធនាគារសម្រាប់អនុវត្តការប្តូរនិងការផ្ទេរប្រាក់បែបនេះ។

(ខ) នៅក្នុងករណីពិសេស ចលនាទុននិងការទូទាត់ រួមទាំងការផ្ទេរ មូលហេតុ ឬការគំរាមកំហែងបង្កការលំបាកធ្ងន់ធ្ងរដល់ប្រតិបត្តិការសេដ្ឋកិច្ចរបស់ភាគីមួយ ភាគីនោះអាចចាត់វិធានការដែលរឹតត្បិតសិទ្ធិដូចមានចែងក្នុងកថាខណ្ឌទី១០ ចំណុច(ក)នៃមាត្រានេះ ដរាបណាវិធានការនេះជាបណ្ដោះអាសន្ននិងចាំបាច់បំផុតដើម្បីដោះស្រាយបញ្ហាលំបាកនេះ។ វិធានការទាំងនេះនឹងមិនបង្កើតជាមធ្យោបាយនៃការរើសអើងតាមអំពើចិត្តឬអយុត្តិធម៌ចំពោះក្រុមហ៊ុនអាកាសចរណ៍របស់ភាគីផ្សេងទៀតទេ បើប្រៀបធៀបទៅនឹងក្រុមហ៊ុនអាកាសចរណ៍នានារបស់ប្រទេសណាមួយផ្សេងទៀត។

## កិច្ចព្រមព្រៀងសហប្រតិបត្តិការធ្វើទីផ្សារ

១១- ក្នុងប្រតិបត្តិការឬការគ្រប់គ្រងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីនីមួយៗ ត្រូវអនុញ្ញាតឱ្យមានកិច្ចព្រមព្រៀងសហប្រតិបត្តិការធ្វើទីផ្សារ ដូចជាការរក្សាទុកកៅអី ឬកិច្ចព្រមព្រៀងសហការជើងហោះហើរ ដោយៈ

(ក) ក្រុមហ៊ុនអាកាសចរណ៍ណាមួយឬច្រើននៃរដ្ឋភាគី។

(ខ) ក្រុមហ៊ុនអាកាសចរណ៍ណាមួយឬច្រើននៃប្រទេសទីបី និង

(គ) អ្នកផ្តល់សេវាកម្មដឹកជញ្ជូនលើផ្ទៃដី(ផ្លូវគោកឬផ្លូវទឹក)នៃប្រទេសណាមួយ។

ដរាបណា (i)ក្រុមហ៊ុនដឹកជញ្ជូនធ្វើប្រតិបត្តិការមានសិទ្ធិចរាចរណ៍សមស្រប (ii)ក្រុមហ៊ុនដឹកជញ្ជូនធ្វើទីផ្សារមានសិទ្ធិលើផ្លូវហោះហើរជាមូលដ្ឋានសមស្រប និង(iii)កិច្ចព្រមព្រៀងត្រូវនឹងលក្ខខណ្ឌដែលជាធម្មតាអនុវត្តចំពោះតែកិច្ចព្រមព្រៀងនេះ។

១២- ក្នុងប្រតិបត្តិការឬការគ្រប់គ្រងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងនេះ ស្របតាមមាត្រា(ក) ក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីនីមួយៗ ត្រូវអនុញ្ញាតឱ្យមានកិច្ចព្រមព្រៀងសហប្រតិបត្តិការធ្វើទីផ្សារ ដូចជាការរក្សាចំនួនកៅអី ឬកិច្ចព្រមព្រៀងសហការជើងហោះហើរជាមួយក្រុមហ៊ុនអាកាសចរណ៍មួយដែលកំពុងធ្វើប្រតិបត្តិការជើងហោះហើរក្នុងស្រុក លុះត្រាតែៈ

(ក) ជើងហោះហើរក្នុងស្រុក គឺជាផ្នែកមួយនៃការធ្វើដំណើរជាអន្តរជាតិ និង

(ខ) កិច្ចព្រមព្រៀងត្រូវនឹងលក្ខខណ្ឌដែលជាធម្មតាអនុវត្តចំពោះតែកិច្ចព្រមព្រៀងនេះ។

ចំពោះគោលបំណងនៃកថាខណ្ឌនេះ ជើងហោះហើរក្នុងស្រុក មានន័យថាជាផ្លូវហោះហើរមួយនៅក្នុងដែនដីនៃរដ្ឋសមាជិកសហភាពអឺរ៉ុប នៅពេលដែលក្រុមហ៊ុនអាកាសចរណ៍ធ្វើប្រតិបត្តិការហោះហើរក្នុងស្រុក ដោយក្រុមហ៊ុនដឹកជញ្ជូនរបស់សហភាព និងជាផ្លូវហោះហើរមួយនៅក្នុងដែនដីនៃរដ្ឋសមាជិកអាស៊ាន នៅពេលដែលក្រុមហ៊ុនអាកាសចរណ៍ធ្វើប្រតិបត្តិការហោះហើរក្នុងស្រុក ដោយក្រុមហ៊ុនដឹកជញ្ជូនរបស់រដ្ឋសមាជិកអាស៊ានមួយ។

១៣- ទាក់ទងនឹងការលក់ការដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាសដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងសហប្រតិបត្តិការធ្វើទីផ្សារ អ្នកទិញត្រូវបានជូនដំណឹងនៅកន្លែងលក់ ឬក្នុងករណីណាមួយនៅពេលចុះឈ្មោះ ឬមុនពេលចូលក្នុងអាកាសយាន ដែលមិនតម្រូវឱ្យមានការចុះឈ្មោះសម្រាប់ជើងហោះហើរតភ្ជាប់ ដែលអ្នកផ្តល់សេវាកម្មដឹកជញ្ជូននឹងប្រតិបត្តិការលើកំណាក់ផ្លូវហោះហើរនីមួយៗនៃសេវាកម្ម។

## សេវាកម្មដឹកជញ្ជូនអន្តរមធ្យោបាយ

១៤- ទាក់ទងនឹងការដឹកជញ្ជូនអ្នកដំណើរ អ្នកផ្តល់សេវាកម្មដឹកជញ្ជូនលើផ្ទៃដីមិនត្រូវស្ថិតនៅក្រោមច្បាប់និងបទប្បញ្ញត្តិដែលគ្រប់គ្រងការដឹកជញ្ជូនតាមផ្លូវអាកាស ដោយផ្អែកលើមូលដ្ឋានតែមួយគត់ដែលការដឹកជញ្ជូនលើផ្ទៃដីខាងលើត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនអាកាសចរណ៍មួយក្រោមឈ្មោះរបស់ខ្លួន។

១៥- ទោះបីជាមានចែងក្នុងបទប្បញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះក៏ដោយ ក្រុមហ៊ុនអាកាសចរណ៍និងអ្នកផ្តល់សេវាកម្មដឹកជញ្ជូននានាដោយប្រយោលនៃការដឹកជញ្ជូនទំនិញរបស់ភាគីនីមួយៗ ត្រូវបានអនុញ្ញាត ដោយគ្មានការរឹតត្បិតឱ្យធ្វើការតភ្ជាប់នឹងការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ ការដឹកជញ្ជូនលើផ្ទៃដីណាមួយសម្រាប់ទំនិញឆ្ពោះទៅកាន់ឬមកពីចំណុចហោះហើរណាមួយនៅក្នុងដែនដីនៃរដ្ឋភាគីឬនៅក្នុងប្រទេសទីបី រួមទាំងការដឹកជញ្ជូនឆ្ពោះទៅនិងមកពីគ្រប់អាកាសយានដ្ឋានជាមួយនឹងការសម្របសម្រួលគយ និង(ប្រសិនបើអាចអនុវត្តបាន)សិទ្ធិដឹកជញ្ជូនទំនិញជាចំណាងនៅក្រោមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ទំនិញទាំងនោះ មិនថាធ្វើដំណើរតាមផ្លូវគោកឬតាមផ្លូវអាកាសទេ ត្រូវតែឆ្លងកាត់ដំណើរការត្រួតពិនិត្យនិងការសម្របសម្រួលរបស់គយនៅអាកាសយានដ្ឋាន។ ក្រុមហ៊ុនអាកាសចរណ៍មួយអាចជ្រើសរើសដើម្បីធ្វើការដឹកជញ្ជូនលើផ្ទៃដីរបស់ខ្លួនផ្ទាល់ ឬតាមរយៈកិច្ចព្រមព្រៀងជាមួយអ្នកផ្តល់សេវាកម្មដឹកជញ្ជូនលើផ្ទៃដីផ្សេងទៀត រួមទាំងការដឹកជញ្ជូនលើផ្ទៃដីដែលធ្វើប្រតិបត្តិការដោយក្រុមហ៊ុនអាកាសចរណ៍ផ្សេងទៀត និងអ្នកផ្តល់សេវាកម្មដឹកជញ្ជូនទំនិញតាមផ្លូវអាកាសដោយប្រយោល។ សេវាកម្មដឹកជញ្ជូនទំនិញអន្តរមធ្យោបាយបែបនេះ អាចត្រូវបានផ្តល់ជូនក្នុងកញ្ចប់តែមួយ តាមរយៈតម្លៃសម្រាប់ការដឹកជញ្ជូនតាមផ្លូវអាកាសនិងការដឹកជញ្ជូនលើផ្ទៃដីរួមបញ្ចូលគ្នា ដរាបណាក្រុមហ៊ុនដឹកជញ្ជូនមិនយល់ខុសពីការពិតទាក់ទងនឹងការដឹកជញ្ជូនបែបនេះ។

## ការជួលអាកាសយាន

១៦- ក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីនីមួយៗ ត្រូវបានអនុញ្ញាតឱ្យផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងនេះ ដោយ៖

(ក) ការប្រើប្រាស់អាកាសយានដែលបានជួលដោយគ្មានក្រុមអាកាសយានិកពីអ្នកជួលឱ្យណាមួយ។

(ខ) ការប្រើប្រាស់អាកាសយានដែលបានជួលជាមួយក្រុមអាកាសយានិកពីក្រុមហ៊ុនអាកាសចរណ៍ផ្សេងទៀតនៃភាគីដូចគ្នា ជាមួយនឹងក្រុមហ៊ុនអាកាសចរណ៍សុំជួល ឬ

(គ) ការប្រើប្រាស់អាកាសយានដែលបានជួលជាមួយក្រុមអាកាសយានិកពីក្រុមហ៊ុនអាកាសចរណ៍នានារបស់ប្រទេសមួយ ក្រៅពីក្រុមហ៊ុនអាកាសចរណ៍អ្នកសុំជួល ដរាបណាការជួលអាកាសយាន



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

គឺត្រឹមត្រូវផ្អែកលើតម្រូវការពិសេស តម្រូវការចំណុះដឹកជញ្ជូនតាមរដូវកាល ឬការលំបាកក្នុងការប្រតិបត្តិការរបស់អ្នកសុំជួល ហើយការជួលអាកាសយានមិនលើសពីរយៈពេលដែលចាំបាច់បំផុត ដើម្បីបំពេញតម្រូវការទាំងនោះឬជម្នះការលំបាកទាំងនោះ។

១៧- រដ្ឋភាគីពាក់ព័ន្ធអាចតម្រូវឱ្យមានកិច្ចព្រមព្រៀងជួលអាកាសយានដែលបានយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ក្នុងគោលបំណងផ្ទៀងផ្ទាត់ការអនុលោមតាមលក្ខខណ្ឌដែលមានចែងក្នុងកថាខណ្ឌទី១៦ ហើយជាមួយនឹងលក្ខខណ្ឌសុវត្ថិភាពនិងសន្តិសុខដែលអាចអនុវត្តបាន។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលដែលភាគីមួយតម្រូវឱ្យមានការយល់ព្រមបែបនេះ ភាគីនោះត្រូវខិតខំពន្លឿននីតិវិធីអនុម័តនិងកាត់បន្ថយបន្ទុករដ្ឋបាលលើក្រុមហ៊ុនអាកាសចរណ៍ដែលពាក់ព័ន្ធ។ ដើម្បីជៀសវាងការសង្ស័យបទប្បញ្ញត្តិនៃកថាខណ្ឌនេះនិងកថាខណ្ឌទី១៦ គឺមិនមានការរើសអើងចំពោះច្បាប់និងបទប្បញ្ញត្តិនានារបស់ភាគីណាមួយទាក់ទងនឹងការជួលអាកាសយានដោយក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីនោះ។

## មាត្រា១១
## ពន្ធគយនិងពន្ធផ្សេងៗ

១- នៅពេលមកដល់ដែនដីនៃភាគីមួយផ្សេងទៀត អាកាសយានដែលប្រតិបត្តិការក្នុងការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិដោយក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីមួយ ឧបករណ៍ប្រើប្រាស់ជាប្រចាំរបស់ខ្លួនរួមមានប្រេងឥន្ធនៈ ប្រេងរំអិល ការផ្គត់ផ្គង់សម្ភារៈប្រើប្រាស់បច្ចេកទេសសេវាកម្មលើផ្ទៃដី គ្រឿងបន្លាស់(រួមទាំងគ្រឿងម៉ាស៊ីន) គ្រឿងឧបភោគបរិភោគ(រួមទាំងទំនិញ ដូចជាអាហារ ភេសជ្ជៈនិងស្រា ថ្នាំជក់និងផលិតផលផ្សេងទៀតដែលបម្រុងទុកសម្រាប់លក់ឬប្រើប្រាស់ដោយអ្នកដំណើរក្នុងបរិមាណមានកំណត់កំឡុងពេលហោះហើរ) និងវត្ថុផ្សេងទៀតដែលមានបំណងសម្រាប់ឬប្រើប្រាស់តែមួយគត់ពាក់ព័ន្ធនឹងប្រតិបត្តិការ ឬសេវាកម្មអាកាសយានដែលចូលរួមក្នុងការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ ត្រូវផ្អែកលើបដិការឱ្យបានពេញលេញតាមដែលអាចធ្វើទៅបាន ក្រោមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករៀងៗខ្លួនរបស់រដ្ឋភាគី ដរាបណាឧបករណ៍និងគ្រឿងផ្គត់ផ្គង់ទាំងនោះស្ថិតនៅលើអាកាសយាន នឹងត្រូវបានលើកលែងពីការរឹតបន្តឹងលើការនាំចូល ពន្ធលើអចលនទ្រព្យ និងពន្ធលើទ្រព្យបុគ្គល ពន្ធគយ ពន្ធអាករ ថ្លៃអធិការកិច្ច ពន្ធលើតម្លៃបន្ថែម ឬពន្ធប្រយោលស្រដៀងគ្នាផ្សេងទៀត និងថ្លៃសេវាកម្មស្រដៀងគ្នា និងការគិតថ្លៃដែលមានដូចជា៖

(ក) កំណត់ដោយអាជ្ញាធរពាក់ព័ន្ធនៃភាគីផ្សេងទៀតនោះ និង

(ខ) មិនផ្អែកលើថ្លៃសេវាកម្មដែលបានផ្តល់។

ដើម្បីជៀសវាងការសង្ស័យ អាកាសយាននិងទំនិញផ្សេងទៀតដែលមានចែងនៅក្នុងកថាខណ្ឌនេះនឹងត្រូវចាត់ទុកថាជាទ្រព្យដែលអាចចល័តបាន ហើយគ្មានបទប្បញ្ញត្តិណាមួយនៅក្នុងមាត្រានេះ ត្រូវប៉ះពាល់ដល់សុពលភាពនិងការអនុវត្តមាត្រា២៤នៃអនុសញ្ញាក្រុងឈីកាហ្គោឡើយ។



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

២- ខាងក្រោមនេះក៏ត្រូវលើកលែងពីពន្ធអាករ ការប្រមូលពន្ធ ពន្ធគយ កម្រៃសេវាកម្ម និងការយកថ្លៃសេវាកម្ម ដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ តាមលទ្ធភាពដែលអាចធ្វើទៅបានក្រោមច្បាប់និងបទប្បញ្ញត្តិក្នុងស្រុករៀងៗខ្លួនរបស់រដ្ឋភាគី និងឈរលើមូលដ្ឋាននៃបដិការ លើកលែងតែការយកថ្លៃសេវាកម្មដោយផ្អែកលើថ្លៃសេវាកម្ម ដែលបានផ្តល់៖

(ក) គ្រឿងឧបភោគបរិភោគដែលត្រូវបាននាំយកទៅឬបានផ្គត់ផ្គង់នៅក្នុងដែនដីនៃភាគីមួយផ្សេងទៀត ហើយបានផ្ទុកនៅលើអាកាសយានក្នុងកម្រិតកំណត់សមហេតុផល សម្រាប់ប្រើប្រាស់នៅលើអាកាសយានរបស់ក្រុមហ៊ុនអាកាសចរណ៍មួយរបស់ភាគីមួយ ដែលចូលរួមក្នុងការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ ទោះបីជាគ្រឿងឧបភោគបរិភោគទាំងនោះត្រូវប្រើប្រាស់នៅលើផ្នែកមួយនៃការធ្វើដំណើរដែលបានអនុវត្តនៅលើដែនដីនេះក៏ដោយ។

(ខ) គ្រឿងបរិក្ខារសេវាកម្មលើផ្ទៃដីនិងគ្រឿងបន្លាស់(រួមទាំងគ្រឿងម៉ាស៊ីន)ដែលត្រូវបាននាំយកទៅក្នុងដែនដីនៃភាគីមួយផ្សេងទៀតសម្រាប់សេវាកម្ម ថែទាំ ឬជួសជុលអាកាសយានរបស់ក្រុមហ៊ុនអាកាសចរណ៍មួយរបស់ភាគីមួយដែលប្រើប្រាស់ក្នុងការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ ទោះបីជាឧបករណ៍និងគ្រឿងបន្លាស់ទាំងនោះត្រូវបានប្រើប្រាស់ក្នុងផ្នែកមួយនៃការធ្វើដំណើរដែលបានអនុវត្តនៅលើដែនដីនេះក៏ដោយ។

(គ) ប្រេងឥន្ធនៈ ប្រេងរំអិល និងការផ្គត់ផ្គង់សម្ភារៈប្រើប្រាស់បច្ចេកទេសដែលអាចប្រើប្រាស់បានត្រូវបាននាំយកឬផ្គត់ផ្គង់នៅក្នុងដែនដីនៃភាគីមួយផ្សេងទៀតសម្រាប់ប្រើប្រាស់ក្នុងអាកាសយានរបស់ក្រុមហ៊ុនអាកាសចរណ៍របស់ភាគីមួយដែលចូលរួមក្នុងការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ ទោះបីជាការផ្គត់ផ្គង់ទាំងនេះត្រូវប្រើប្រាស់ជាផ្នែកមួយនៃការធ្វើដំណើរដែលបានអនុវត្តនៅលើដែនដីនេះក៏ដោយ និង

(ឃ) ឯកសារដែលបានបោះពុម្ព ដូចដែលមានចែងដោយច្បាប់គយនៃភាគីមួយផ្សេងទៀត ដែលត្រូវបានណែនាំឱ្យប្រើឬផ្គត់ផ្គង់នៅក្នុងដែនដីនៃភាគីមួយផ្សេងទៀត ហើយត្រូវបានផ្ទុកនៅលើអាកាសយានសម្រាប់ប្រើប្រាស់លើអាកាសយានហោះហើរក្រៅប្រទេសរបស់ក្រុមហ៊ុនអាកាសចរណ៍របស់ភាគីមួយ ដែលចូលរួមក្នុងការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ សូម្បីតែនៅពេលដែលឯកសារដែលបានបោះពុម្ពនេះ ត្រូវប្រើប្រាស់ក្នុងផ្នែកមួយនៃការធ្វើដំណើរដែលអនុវត្តនៅលើដែនដីនោះ។

៣- ទាក់ទងនឹងការលើកលែងនានាដែលមានចែងក្នុងមាត្រានេះ រដ្ឋភាគីត្រូវផ្តល់ឱ្យក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីមួយផ្សេងទៀតនូវប្រព្រឹត្តិកម្មអនុគ្រោះដូចគ្នា ឬប្រសើរជាងក្រុមហ៊ុនអាកាសចរណ៍នានារបស់ខ្លួនផ្សេងទៀត ឬក្រុមហ៊ុនអាកាសចរណ៍នានារបស់ប្រទេសទីបីណាមួយ។



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៤- គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវរារាំងភាគីមួយពីការយកពន្ធ ការប្រមូលពន្ធ ពន្ធគយ កម្រៃសេវាកម្ម ឬការយកថ្លៃនានាលើប្រេងឥន្ទនៈដែលផ្គត់ផ្គង់ក្នុងដែនដីរបស់ខ្លួន ដោយឈរលើមូលដ្ឋានមិនរើសអើង សម្រាប់ការប្រើប្រាស់ក្នុងអាកាសយានរបស់ក្រុមហ៊ុនអាកាសចរណ៍មួយរបស់ភាគីមួយផ្សេងទៀត ដែលធ្វើប្រតិបត្តិការរវាងពីរចំណុចនៅក្នុងដែនដីរបស់ខ្លួន។

៥- គ្រឿងបរិក្ខារដឹកជញ្ជូនតាមផ្លូវអាកាសធម្មតា ក៏ដូចជាសម្ភារៈ គ្រឿងផ្គត់ផ្គង់ និងគ្រឿងបន្លាស់នានាដែលមានចែងក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រានេះ ជាធម្មតាត្រូវបានរក្សាទុកនៅលើអាកាសយានដែលបានធ្វើប្រតិបត្តិការដោយក្រុមហ៊ុនអាកាសចរណ៍មួយរបស់ភាគីមួយ អាចត្រូវបានដាក់ចុះនៅលើដែនដីនៃភាគីមួយផ្សេងទៀត លុះត្រាតែមានការយល់ព្រមពីអាជ្ញាធរគយនៃភាគីផ្សេងទៀតនោះ ហើយអាចតម្រូវឱ្យរក្សាទុកនៅក្រោមការត្រួតពិនិត្យឬការគ្រប់គ្រងរបស់អាជ្ញាធរខាងលើ រហូតដល់ពេលដែលត្រូវនាំចេញត្រឡប់ទៅវិញ ឬបើមិនដូច្នោះទេ ត្រូវចាត់ចែងដោយអនុលោមតាមបទប្បញ្ញត្តិគយ។

៦- ការលើកលែងដែលផ្តល់ដោយមាត្រានេះក៏មានផងដែរ នៅពេលដែលក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីមួយបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនអាកាសចរណ៍មួយផ្សេងទៀត ដែលទទួលបានការលើកលែងដូចគ្នាពីភាគីមួយផ្សេងទៀតសម្រាប់ការខ្ចីឬការផ្ទេរនៅក្នុងដែនដីនៃភាគីផ្សេងទៀតនោះនូវវត្ថុដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រានេះ។

៧- គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវរារាំងភាគីមួយពីការយកពន្ធ ការប្រមូលពន្ធ ពន្ធគយ កម្រៃសេវាកម្ម ឬការយកថ្លៃនានាលើទំនិញដែលបានលក់ ក្រៅពីការប្រើប្រាស់នៅលើអាកាសយានដល់អ្នកដំណើរក្នុងកំឡុងពេលធ្វើសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសលើដំណាក់ផ្លូវហោះហើរមួយរវាងពីរចំណុចនៅក្នុងវង្វង់ដែនដីរបស់ខ្លួន ដែលការទទួលយកឬការដាក់ចុះពីអាកាសយានត្រូវបានអនុញ្ញាត។

៨- អីវ៉ាន់និងទំនិញដែលដឹកជញ្ជូនដោយផ្ទាល់ឆ្លងកាត់ដែនដីនៃភាគីមួយ ត្រូវបានលើកលែងពីពន្ធអាករ ពន្ធគយ កម្រៃសេវាកម្ម និងការយកថ្លៃនានាស្រដៀងគ្នាផ្សេងៗទៀតដែលមិនផ្អែកលើថ្លៃសេវាកម្មដែលបានផ្តល់ឱ្យ។

៩- គ្រឿងបរិក្ខារនិងសម្ភារៈផ្គត់ផ្គង់ដែលមានចែងក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រានេះ អាចត្រូវបានតម្រូវឱ្យរក្សាទុកនៅក្រោមការត្រួតពិនិត្យឬការគ្រប់គ្រងរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនានា។

១០- បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងរៀងៗខ្លួនដែលនៅជាធរមានរវាងបណ្តារដ្ឋសមាជិកអាស៊ាននិងបណ្តារដ្ឋសមាជិកសហភាពអឺរ៉ុប សម្រាប់ការជៀសវាងការយកពន្ធត្រួតគ្នាលើប្រាក់ចំណូលនិងលើទុន មិនប៉ះពាល់ដល់កិច្ចព្រមព្រៀងនេះទេ។

## មាត្រា១២
## ការយកថ្លៃលើអ្នកប្រើប្រាស់

១- ភាគីនីមួយៗត្រូវធានាថា ការយកថ្លៃនានាលើអ្នកប្រើប្រាស់ណាមួយ ដែលកំណត់ដោយអាជ្ញាធរទទួលបន្ទុកមានសមត្ថកិច្ចឬស្ថាប័ននានារបស់ខ្លួន លើក្រុមហ៊ុនអាកាសចរណ៍របស់ភាគីមួយផ្សេងទៀតសម្រាប់ការប្រើប្រាស់ការនាំផ្លូវអាកាសនិងការគ្រប់គ្រងចរាចរណ៍ផ្លូវអាកាស គឺទាក់ទងនឹងការចំណាយ និងមិនមានការរើសអើង ហើយស្ថិតក្នុងលក្ខខណ្ឌអនុគ្រោះដូចគ្នា ជាងលក្ខខណ្ឌអនុគ្រោះប្រសើរបំផុតដល់ក្រុមហ៊ុនអាកាសចរណ៍ផ្សេងទៀត ក្នុងកាលៈទេសៈណាមួយ នៅពេលការយកថ្លៃនានាត្រូវបានអនុវត្ត។

២- លើកលែងតែការយកថ្លៃនានាដែលបានកំណត់ទាក់ទងនឹងសេវាកម្មដែលមានចែងក្នុងកថាខណ្ឌទី៥នៃមាត្រា១០ ភាគីនីមួយៗត្រូវធានាថា ការយកថ្លៃនានាលើអ្នកប្រើប្រាស់ណាមួយដែលកំណត់ដោយអាជ្ញាធរទទួលបន្ទុកមានសមត្ថកិច្ចឬស្ថាប័ននានារបស់ខ្លួន លើក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីមួយផ្សេងទៀតសម្រាប់ការប្រើប្រាស់អាកាសយានដ្ឋាន សន្តិសុខអាកាសចរណ៍ និងគ្រឿងបរិក្ខារ និងសេវាកម្មពាក់ព័ន្ធនានា មិនត្រូវមានការរើសអើងដោយអយុត្តិធម៌ទេ ហើយត្រូវបែងចែកដោយសមធម៌ក្នុងចំណោមប្រភេទនៃអ្នកប្រើប្រាស់។ ការយកថ្លៃទាំងអស់នេះមិនត្រូវឱ្យលើសពីការចំណាយពេញលេញ ដែលអាជ្ញាធរទទួលបន្ទុកមានសមត្ថកិច្ច ឬស្ថាប័ននានាកំណត់តម្លៃ ក្នុងការផ្ដល់គ្រឿងបរិក្ខារអាកាសយានដ្ឋាននិងសន្តិសុខអាកាសចរណ៍ និងសេវាកម្មនានា នៅអាកាសយានដ្ឋាននោះឬអាកាសយានដ្ឋានទាំងអស់នោះ ដែលអនុវត្តប្រព័ន្ធទទួលបន្ទុករួមនោះ។ ទោះបីជាយ៉ាងនេះក្តី ការយកថ្លៃទាំងអស់នេះអាចរួមបញ្ចូលទាំងផលចំណេញសមស្របពីទ្រព្យសកម្មបន្ទាប់ពីការរំលស់។ គ្រឿងបរិក្ខារនិងសេវាកម្មនានាដែលយកថ្លៃលើអ្នកប្រើប្រាស់ ត្រូវបានផ្តល់ជូនដោយផ្អែកលើមូលដ្ឋានប្រសិទ្ធភាពនិងមានលក្ខណៈសេដ្ឋកិច្ច។ ស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ការយកថ្លៃទាំងអស់នេះត្រូវបានដាក់កំណត់លើក្រុមហ៊ុនអាកាសចរណ៍នានារបស់ភាគីមួយផ្សេងទៀត ក្នុងលក្ខខណ្ឌអនុគ្រោះដូចគ្នា ជាងលក្ខខណ្ឌអនុគ្រោះប្រសើរបំផុតដែលមានចំពោះក្រុមហ៊ុនអាកាសចរណ៍ផ្សេងទៀត ក្នុងកាលៈទេសៈណាមួយ នៅពេលការយកថ្លៃនានាត្រូវបានអនុវត្ត។

៣- ភាគីនីមួយៗត្រូវតម្រូវឱ្យអាជ្ញាធរទទួលបន្ទុកមានសមត្ថកិច្ចឬស្ថាប័ននានារបស់ខ្លួន ពិគ្រោះយោបល់ជាមួយក្រុមហ៊ុនអាកាសចរណ៍នានាដែលប្រើប្រាស់សេវាកម្មនិងគ្រឿងបរិក្ខារនានា ហើយធ្វើការផ្លាស់ប្តូរជាមួយខ្លួននូវព័ត៌មានទាំងនោះតាមការចាំបាច់ ដើម្បីអនុញ្ញាតឱ្យមានការវាយតម្លៃត្រឹមត្រូវអំពីហេតុផលនៃការយកថ្លៃនានាស្របតាមគោលការណ៍ដែលបានកំណត់ក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រានេះ។ ភាគីនីមួយៗត្រូវធានាថា អាជ្ញាធរទទួលបន្ទុកមានសមត្ថកិច្ចឬស្ថាប័ននានារបស់ខ្លួន ផ្តល់ដល់ក្រុមហ៊ុនអាកាសចរណ៍នានានូវសេចក្តីជូនដំណឹងសមហេតុផលនៃសំណើណាមួយសម្រាប់ការផ្លាស់ប្តូរការយកថ្លៃនានាលើអ្នកប្រើប្រាស់ ដើម្បីអាចឱ្យ [illegible]ៈនិងផ្តល់មតិយោបល់ផ្សេងៗ មុនពេលការផ្លាស់ប្តូរណាមួយត្រូវបានធ្វើឡើង។

## មាត្រា១៣
## តម្លៃសេវាកម្ម

១- រដ្ឋភាគីត្រូវអនុញ្ញាតឱ្យកំណត់តម្លៃសេវាកម្មដែលបានបង្កើតឡើងដោយសេរីរបស់ក្រុមហ៊ុនអាកាសចរណ៍នៃរដ្ឋភាគី។

២- ដោយផ្អែកលើមូលដ្ឋានមិនរើសអើង ភាគីណាមួយអាចតម្រូវឱ្យធ្វើការជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនអំពីតម្លៃសេវាកម្មដែលបានផ្តល់សម្រាប់សេវាកម្មដែលមានប្រភពចេញមកពីដែនដីរបស់ខ្លួនដោយក្រុមហ៊ុនអាកាសចរណ៍របស់រដ្ឋភាគីណាមួយ ដោយផ្អែកលើមូលដ្ឋានជាធម្មតានិងសម្រាប់គោលបំណងជាព័ត៌មានតែប៉ុណ្ណោះ។ ការជូនដំណឹងនេះ ធ្វើឡើងដោយក្រុមហ៊ុនអាកាសចរណ៍នានាដែលអាចតម្រូវឱ្យបង្កើតឡើងបន្ទាប់ពីការផ្តល់តម្លៃសេវាកម្មដំបូង។

## មាត្រា១៤
## ស្ថិតិដឹកជញ្ជូន

១- រដ្ឋភាគីនីមួយៗត្រូវផ្តល់ឱ្យរដ្ឋភាគីផ្សេងទៀតនូវស្ថិតិដែលទាក់ទងនឹងការដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងនេះ តាមតម្រូវការដោយសមហេតុផល ស្របតាមច្បាប់និងបទប្បញ្ញត្តិនានារៀងៗខ្លួននៃរដ្ឋភាគី និងផ្អែកលើមូលដ្ឋានមិនរើសអើង។

២- រដ្ឋភាគីព្រមព្រៀងគ្នា ដើម្បីសហការសម្របសម្រួលការផ្លាស់ប្តូរព័ត៌មានស្ថិតិដឹកជញ្ជូនតាមផ្លូវអាកាសរវាងរដ្ឋភាគីក្នុងគោលបំណងត្រួតពិនិត្យការអភិវឌ្ឍនៃការដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងនេះ។

## មាត្រា១៥
## សុវត្ថិភាពអាកាសចរណ៍

១- រដ្ឋភាគីបញ្ជាក់សាជាថ្មីអំពីសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការជិតស្និទ្ធក្នុងផ្នែកសុវត្ថិភាពអាកាសចរណ៍។ នៅក្នុងបរិបទនោះ រដ្ឋភាគីព្រមព្រៀងគ្នាចូលរួមក្នុងកិច្ចសហប្រតិបត្តិការបន្ថែមទៀតនៅពេលវេលាដែលសមស្រប ជាពិសេសការសម្របសម្រួលនៃការផ្លាស់ប្តូរព័ត៌មានសុវត្ថិភាព ការចូលរួមដែលអាចកើតមានក្នុងសកម្មភាពត្រួតពិនិត្យគ្នាទៅវិញទៅមក ឬការធ្វើសកម្មភាពត្រួតពិនិត្យរួម ក៏ដូចជាការអភិវឌ្ឍគម្រោងនិងគំនិតផ្តួចផ្តើមរួម រួមទាំងប្រទេសដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀងនេះ។

២- វិញ្ញាបនបត្របញ្ជាក់លទ្ធភាពហោះហើរ វិញ្ញាបនបត្របញ្ជាក់សមត្ថភាព និងអាជ្ញាបណ្ណដែលចេញ ឬផ្តល់សុពលភាពដោយភាគីមួយហើយនៅតែជាធរមាន ត្រូវបានទទួលស្គាល់ថាមានសុពលភាពដោយភាគីមួយផ្សេង



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ទៀតនិងអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនសម្រាប់គោលបំណងធ្វើប្រតិបត្តិការសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងនេះ ដរាបណាវិញ្ញាបនបត្រទាំងអស់នោះ ឬអាជ្ញាបណ្ណត្រូវបានចេញឬផ្តល់សុពលភាពដោយស្របតាមនិងអនុលោមតាមជាអប្បបរមាពាក់ព័ន្ធនឹងស្តង់ដាអន្តរជាតិ ដែលបានបង្កើតឡើងក្រោមអនុសញ្ញាក្រុងឈីកាហ្គោ។

៣- ភាគីនីមួយៗអាចស្នើសុំពិគ្រោះយោបល់បានគ្រប់ពេលវេលាអំពីស្តង់ដាសុវត្ថិភាពដែលប្រកាន់ខ្ជាប់និងគ្រប់គ្រងដោយភាគីមួយផ្សេងទៀតលើផ្នែកដែលទាក់ទងនឹងគ្រឿងបរិក្ខារអាកាសចរណ៍ ក្រុមអាកាសយានិកអាកាសយាន និងប្រតិបត្តិការរបស់អាកាសយាន។ ការពិគ្រោះយោបល់នេះ ត្រូវប្រព្រឹត្តទៅក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើ។

៤- បន្ទាប់ពីការពិគ្រោះយោបល់ដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រានេះ ប្រសិនបើភាគីស្នើសុំយល់ឃើញថា ភាគីផ្សេងទៀតមិនប្រកាន់ខ្ជាប់និងមិនគ្រប់គ្រងស្តង់ដាសុវត្ថិភាពប្រកបដោយប្រសិទ្ធភាពលើផ្នែកដែលមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រានេះ ដែលយ៉ាងហោចណាស់ស្មើនឹងស្តង់ដាអប្បបរមាដែលត្រូវបានបង្កើតឡើងស្របតាមអនុសញ្ញាក្រុងឈីកាហ្គោ នោះភាគីផ្សេងទៀតនឹងត្រូវបានជូនដំណឹងអំពីការរកឃើញនេះនិងដំណាក់កាលដែលត្រូវបានចាត់ទុកថាចាំបាច់ដើម្បីអនុលោមតាមស្តង់ដាអប្បបរមាទាំងនេះ។ ការខកខានរបស់ភាគីម្ខាងទៀតក្នុងការចាត់វិធានការកែតម្រូវសមស្របក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ចាប់ពីកាលបរិច្ឆេទទទួលសេចក្តីជូនដំណឹងនោះ ឬរយៈពេលដែលបានព្រមព្រៀងគ្នានឹងក្លាយជាមូលដ្ឋានសម្រាប់ភាគីស្នើសុំដូចមានចែងក្នុងកថាខណ្ឌទី៣នៃមាត្រានេះ ក្នុងការបដិសេធ ដកហូត ព្យួរ ដាក់លក្ខខណ្ឌនានា ឬដាក់កម្រិតការអនុញ្ញាតធ្វើប្រតិបត្តិការ ឬការអនុញ្ញាតផ្នែកបច្ចេកទេសរបស់ក្រុមហ៊ុនអាកាសចរណ៍មួយដែលស្ថិតក្រោមការត្រួតពិនិត្យសុវត្ថិភាពនៃភាគីផ្សេងទៀត ឬដើម្បីបដិសេធ ដកហូត ព្យួរ ដាក់លក្ខខណ្ឌនានា ឬដាក់កម្រិតធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនអាកាសចរណ៍មួយ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យសុវត្ថិភាពនៃភាគីម្ខាងទៀតនោះ។

៥- អាកាសយានណាមួយដែលបានធ្វើប្រតិបត្តិការដោយឬក្នុងនាមក្រុមហ៊ុនអាកាសចរណ៍របស់ភាគីមួយខណៈពេលស្ថិតនៅក្នុងដែនដីនៃភាគីមួយផ្សេងទៀត អាចជាកម្មវត្ថុនៃការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៅលើផ្ទៃដីដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីផ្សេងទៀតនោះ ដើម្បីផ្ទៀងផ្ទាត់សុពលភាពនៃឯកសារពាក់ព័ន្ធរបស់អាកាសយាននិងសមាជិកអាកាសយានិករបស់ខ្លួន និងស្ថានភាពជាក់ស្តែងនៃអាកាសយាននិងឧបករណ៍របស់អាកាសយាន ដរាបណាការត្រួតពិនិត្យនេះមិនបណ្តាលឱ្យមានការពន្យារពេលមិនសមហេតុផលក្នុងការធ្វើប្រតិបត្តិការរបស់អាកាសយាននោះទេ។

៦- បន្ទាប់ពីបានអនុវត្តការត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៅលើផ្ទៃដី ប្រសិនបើភាគីមួយរកឃើញថាអាកាសយានឬប្រតិបត្តិការរបស់អាកាសយានមិនស្របតាមស្តង់ដាអប្បបរមាដែលបានបង្កើតឡើងស្របតាមអនុសញ្ញាក្រុងឈីកាហ្គោ ឬថា មានការខ្វះខាតការថែទាំនិងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃស្តង់ដាសុវត្ថិភាពដែលបានបង្កើតឡើងស្របតាមអនុសញ្ញាក្រុងឈីកាហ្គោ ឬប្រសិនបើ ត្រូវបានបដិសេធក្នុងការចូល

ទៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៅលើផ្ទៃដី ភាគីនោះត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីផ្សេងទៀតដែលទទួលខុសត្រូវចំពោះការត្រួតពិនិត្យសុវត្ថិភាពរបស់ក្រុមហ៊ុនអាកាសចរណ៍ដែលកំពុងធ្វើប្រតិបត្តិការអាកាសយាននៃការរកឃើញនេះ និងដំណាក់កាលដែលត្រូវបានចាត់ទុកថាចាំបាច់ដើម្បីអនុលោមតាមស្តង់ដាអប្បបរមាទាំងនេះ។ ការខកខានក្នុងការចាត់វិធានការកែតម្រូវសមស្របក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលការជូនដំណឹងនោះឬរយៈពេលដែលបានព្រមព្រៀងគ្នា នឹងក្លាយជាមូលដ្ឋានសម្រាប់ភាគីទីមួយក្នុងការបដិសេធ ដកហូត ព្យួរ ដាក់លក្ខខណ្ឌនានា ឬដាក់កម្រិតការអនុញ្ញាតធ្វើប្រតិបត្តិការ ឬការអនុញ្ញាតផ្នែកបច្ចេកទេសរបស់ក្រុមហ៊ុនអាកាសចរណ៍ដែលកំពុងធ្វើប្រតិបត្តិការអាកាសយាន ឬដើម្បីបដិសេធ ដកហូត ព្យួរ ដាក់លក្ខខណ្ឌនានា ឬដាក់កម្រិតការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនអាកាសចរណ៍ដែលកំពុងធ្វើប្រតិបត្តិការអាកាសយាន។

៧- ភាគីនីមួយៗត្រូវមានសិទ្ធិធ្វើចំណាត់ការជាបន្ទាន់ រួមទាំងសិទ្ធិដកហូត ព្យួរ ឬដាក់កម្រិតការអនុញ្ញាតធ្វើប្រតិបត្តិការ ឬការអនុញ្ញាតផ្នែកបច្ចេកទេសរបស់ក្រុមហ៊ុនអាកាសចរណ៍របស់ភាគីមួយផ្សេងទៀត ឬដើម្បីព្យួរ ឬដាក់កម្រិតការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនអាកាសចរណ៍របស់ភាគីមួយផ្សេងទៀត ប្រសិនបើយល់ឃើញថាសកម្មភាពនេះចាំបាច់ដោយសារតែមានការគំរាមកំហែងភ្លាមៗចំពោះសុវត្ថិភាពអាកាសចរណ៍។ ភាគីដែលចាត់វិធានការនេះ ត្រូវជូនដំណឹងជាបន្ទាន់ដល់ភាគីផ្សេងទៀត និងផ្តល់ហេតុផលនានាសម្រាប់ចំណាត់ការរបស់ខ្លួន។

៨- ចំណាត់ការណាមួយរបស់ភាគីមួយស្របតាមកថាខណ្ឌទី៤ កថាខណ្ឌទី៦ ឬកថាខណ្ឌទី៧នៃមាត្រានេះ ត្រូវបានបញ្ឈប់នៅពេលមូលដ្ឋានសម្រាប់ការធ្វើចំណាត់ការនោះ លែងមាន។

## មាត្រា១៦
## សន្តិសុខអាកាសចរណ៍

១- រដ្ឋភាគីបញ្ជាក់ឡើងវិញនូវកាតព្វកិច្ចរបស់ខ្លួន ចំពោះគ្នាទៅវិញទៅមកក្នុងការផ្តល់សន្តិសុខអាកាសចរណ៍ស៊ីវិលប្រឆាំងនឹងទង្វើនៃការជ្រៀតជ្រែកដោយខុសច្បាប់ និងជាពិសេសកាតព្វកិច្ចនានារបស់ខ្លួនក្រោមអនុសញ្ញាក្រុងឈីកាហ្គោ អនុសញ្ញាស្តីពីបទល្មើស និងសកម្មភាពមួយចំនួនទៀតបានប្រព្រឹត្តលើអាកាសយាន ដែលបានចុះហត្ថលេខានៅទីក្រុងតូក្យូ នាថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៦៣ អនុសញ្ញាសម្រាប់ការបង្រ្កាបការរឹបអូសអាកាសយានដោយខុសច្បាប់ ដែលបានចុះហត្ថលេខានៅក្រុងឡាអេ នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧០ អនុសញ្ញាសម្រាប់ការបង្រ្កាបអំពើខុសច្បាប់ប្រឆាំងនឹងសុវត្ថិភាពអាកាសចរណ៍ស៊ីវិល ដែលបានចុះហត្ថលេខានៅក្រុងម៉ុងរ៉េអាល់ នាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧១ ពិធីសារសម្រាប់ការបង្រ្កាបអំពើហិង្សាខុសច្បាប់នៅអាកាសយានដ្ឋានដែលបម្រើឱ្យអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដែលបានចុះហត្ថលេខានៅក្រុងម៉ុងរ៉េអាល់ នាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៨៨ និងអនុសញ្ញាស្តីពី

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ការសម្គាល់គ្រឿងផ្ទុះប្លាស្ទិក សម្រាប់គោលបំណងនៃការស៊ើបអង្កេត ដែលបានធ្វើឡើងនៅក្រុងម៉ុងរ៉េអាល់ នាថ្ងៃទី១ ខែមីនា ឆ្នាំ១៩៩១ ដរាបណារដ្ឋភាគី គឺជាភាគីនៃអនុសញ្ញាទាំងអស់នេះ ក៏ដូចជាអនុសញ្ញានិងពិធីសារផ្សេងទៀតទាំងអស់ ដែលទាក់ទងនឹងសន្តិសុខអាកាសចរណ៍ស៊ីវិលដែលរដ្ឋភាគី គឺជាភាគី។

២- រដ្ឋភាគីត្រូវផ្តល់តាមការស្នើសុំជំនួយចាំបាច់ទាំងអស់ដល់គ្នាទៅវិញទៅមក ដើម្បីទប់ស្កាត់ការគំរាមកំហែងណាមួយចំពោះសន្តិសុខអាកាសចរណ៍ស៊ីវិល រួមទាំងការទប់ស្កាត់អំពើរឹបអូសដោយខុសច្បាប់នៃអាកាសយានស៊ីវិល និងអំពើខុសច្បាប់ផ្សេងទៀតប្រឆាំងនឹងសុវត្ថិភាពនៃអាកាសយាននោះ អ្នកដំណើរនិងក្រុមអាកាសយានិក អាកាសយានដ្ឋាននិងគ្រឿងបរិក្ខារនាំផ្លូវអាកាស និងការគំរាមកំហែងផ្សេងទៀតណាមួយចំពោះសន្តិសុខអាកាសចរណ៍ស៊ីវិល។

៣- ក្នុងការធ្វើទំនាក់ទំនងគ្នាទៅវិញទៅមក រដ្ឋភាគីត្រូវអនុលោមតាមស្តង់ដាសន្តិសុខអាកាសចរណ៍ដែលបានបង្កើតឡើងដោយអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ។ រដ្ឋភាគីត្រូវតម្រូវឱ្យប្រតិបត្តិករអាកាសយាននៃទីតាំងចុះបញ្ជីរបស់ខ្លួន ប្រតិបត្តិករអាកាសយានដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើមឬនិវេសនដ្ឋានអចិន្ត្រៃយ៍នៅក្នុងដែនដីរបស់ខ្លួន និងប្រតិបត្តិករអាកាសយានដ្ឋាននៅក្នុងដែនដីរបស់ខ្លួន ត្រូវអនុវត្តស្របតាមស្តង់ដាសន្តិសុខអាកាសចរណ៍នោះ។

៤- ភាគីនីមួយៗត្រូវធានាថា វិធានការប្រកបដោយប្រសិទ្ធភាព ត្រូវបានធ្វើឡើងនៅក្នុងដែនដីរបស់ខ្លួន ដើម្បីការពារអាកាសចរណ៍ស៊ីវិលប្រឆាំងនឹងការជ្រៀតជ្រែកដោយខុសច្បាប់ រួមទាំងការត្រួតពិនិត្យអ្នកដំណើរនិងអីវ៉ាន់ក្នុងអាកាសយាន ការត្រួតពិនិត្យអីវ៉ាន់ ការត្រួតពិនិត្យសន្តិសុខសម្រាប់មនុស្សក្រៅពីអ្នកដំណើរ(រួមទាំងក្រុមអាកាសយានិក) និងសម្ភារៈយកតាមខ្លួន ត្រួតពិនិត្យសន្តិសុខសម្រាប់ទំនិញ បញ្ញើប្រៃសណីយ៍ សម្ភារៈប្រើប្រាស់ក្នុងពេលហោះហើរនិងនៅក្នុងអាកាសយានដ្ឋាន និងមានសិទ្ធិចូលទៅកាន់តំបន់ហាមឃាត់និងតំបន់រឹតបន្តឹងសន្តិសុខ។ វិធានការបែបនេះត្រូវកែសម្រួលដើម្បីឆ្លើយតបនឹងការកើនឡើងនៃការគំរាមកំហែងដល់សន្តិសុខអាកាសចរណ៍ស៊ីវិល។ ភាគីនីមួយៗព្រមព្រៀងគ្នាថា បទប្បញ្ញត្តិសន្តិសុខដែលបានតម្រូវដោយភាគីមួយផ្សេងទៀតទាក់ទងនឹងការចូល ការធ្វើប្រតិបត្តិការនៅក្នុង ឬការចាកចេញពីដែនដីរបស់ខ្លួននៃអាកាសយាន ត្រូវបានអង្កេត។

៥- ដោយគិតគូរនិងគោរពអធិបតេយ្យភាពគ្នាទៅវិញទៅមក ភាគីមួយអាចអនុម័តវិធានការសន្តិសុខសម្រាប់ការចូលទៅក្នុងដែនដីរបស់ខ្លួន ក៏ដូចជាវិធានការសង្គ្រោះបន្ទាន់ ដើម្បីឆ្លើយតបទៅនឹងការគំរាមកំហែងសន្តិសុខជាក់លាក់ ដែលគួរតែត្រូវបានទាក់ទងទៅភាគីឬរដ្ឋភាគីពាក់ព័ន្ធជាបន្ទាន់ដោយមិនមានការពន្យារពេល។ ភាគីនីមួយៗត្រូវត្រួតពិនិត្យជាវិជ្ជមានចំពោះសំណើណាមួយពីភាគីមួយផ្សេងទៀតសម្រាប់វិធានការសន្តិសុខ

ពិសេសដែលសមហេតុផល ហើយភាគីផ្សេងទៀតត្រូវគិតគូរអំពីវិធានការសន្តិសុខដែលបានអនុវត្តរួចហើយដោយរដ្ឋភាគីទីមួយ និងការបង្ហាញណាមួយដែលភាគីទីមួយអាចផ្តល់ជូន។ លើកលែងតែករណីដែលមិនអាចធ្វើទៅបានក្នុងគ្រាមានអាសន្ន ភាគីនីមួយៗត្រូវជូនដំណឹងដល់ភាគីឬរដ្ឋភាគីពាក់ព័ន្ធជាមុនអំពីវិធានការសន្តិសុខពិសេសណាមួយដែលខ្លួនមានបំណងណែនាំ អាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើផ្នែកហិរញ្ញវត្ថុ ឬប្រតិបត្តិការសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ។ ភាគីណាមួយអាចស្នើសុំកិច្ចប្រជុំគណៈកម្មាធិការចម្រុះ ដើម្បីពិភាក្សាអំពីវិធានការសន្តិសុខដូចមានចែងក្នុងមាត្រា២៣។

៦- ទោះបីជាយ៉ាងណាក៏ដោយ ភាគីនីមួយៗទទួលស្គាល់ថា គ្មានបទប្បញ្ញត្តិណាមួយនៅក្នុងមាត្រានេះកម្រិតលទ្ធភាពនៃភាគីមួយផ្សេងទៀតក្នុងការបដិសេធការចូលទៅក្នុងដែនដីរបស់ខ្លួន ចំពោះការហោះហើរ ឬជើងហោះហើរណាមួយដែលខ្លួនយល់ថា បង្កការគំរាមកំហែងដល់សន្តិសុខរបស់ខ្លួន។

៧- ដោយមិនមានការលម្អៀងចំពោះតម្រូវការក្នុងការចាត់វិធានការជាបន្ទាន់ដើម្បីការពារសន្តិសុខអាកាសចរណ៍ រដ្ឋភាគីអះអាងថា នៅពេលត្រួតពិនិត្យលើវិធានការសន្តិសុខ ភាគីមួយត្រូវវាយតម្លៃផលប៉ះពាល់ដែលអាចកើតមានដល់ការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ ហើយប្រសិនបើមានការរឹតបន្តឹងដោយច្បាប់ ត្រូវយកកត្តាទាំងនោះមកពិនិត្យនៅពេលដែលកំណត់នូវវិធានការចាំបាច់និងសមស្របដើម្បីដោះស្រាយបញ្ហាសន្តិសុខពាក់ព័ន្ធទាំងនោះ។

៨- នៅពេលដែលការរឹបអូសអាកាសយានស៊ីវិលដោយខុសច្បាប់(ឬការគំរាមកំហែង) ឬអំពើខុសច្បាប់ផ្សេងទៀតប្រឆាំងនឹងសុវត្ថិភាពអាកាសយាន អ្នកដំណើរ ក្រុមអាកាសយានិក អាកាសយានដ្ឋាន ឬគ្រឿងបរិក្ខារនាំផ្លូវអាកាសកើតឡើង រដ្ឋភាគីត្រូវជួយគ្នាទៅវិញទៅមកដោយការសម្របសម្រួលទំនាក់ទំនង និងវិធានការសមស្របផ្សេងទៀតដែលមានគោលបំណងបញ្ចប់ឧបទ្ទវហេតុឬការគំរាមកំហែងនេះយ៉ាងឆាប់រហ័ស និងដោយសុវត្ថិភាព។

៩- ភាគីនីមួយៗត្រូវចាត់វិធានការគ្រប់បែបយ៉ាងដែលខ្លួនរកឃើញថា អាចអនុវត្តបានដើម្បីធានាថា អាកាសយានដែលទទួលរងនូវការរឹបអូសដោយខុសច្បាប់ ឬសកម្មភាពនៃការជ្រៀតជ្រែកដោយខុសច្បាប់ដែលកើតមាននៅលើផ្ទៃដីនៅក្នុងដែនដីរបស់ខ្លួន ត្រូវបានឃាត់ខ្លួននៅលើផ្ទៃដី ដរាបណាការចាកចេញរបស់អាកាសយានត្រូវមានកាតព្វកិច្ចធានាការពារជីវិតមនុស្សជាចម្បង។ ក្នុងករណីដែលអាចអនុវត្តទៅបាន វិធានការនេះ ត្រូវធ្វើឡើងដោយផ្អែកលើការពិគ្រោះយោបល់គ្នាទៅវិញទៅមកជាមួយភាគីឬរដ្ឋភាគីពាក់ព័ន្ធនានា។

១០- នៅពេលដែលភាគីណាមួយមានមូលដ្ឋានសមស្របដោយជឿជាក់ថា ភាគីផ្សេងទៀតមិនបានអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រានេះ ភាគីទីមួយអាចស្នើសុំពិគ្រោះយោបល់ជាបន្ទាន់ជាមួយភាគីផ្សេងទៀត។ ការពិគ្រោះយោបល់នេះ ត្រូវចាប់ផ្តើមក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើនោះ។ [illegible]ឈានដល់កិច្ចព្រមព្រៀងដែលពេញចិត្តក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ឬរយៈពេលដែលបាន

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ព្រមព្រៀងគ្នាចាប់ពីកាលបរិច្ឆេទចាប់ផ្តើមនៃការពិគ្រោះយោបល់នេះ នឹងក្លាយជាមូលដ្ឋានសម្រាប់ភាគីដែលបានស្នើសុំការពិគ្រោះយោបល់ដើម្បីចាត់វិធានការក្នុងការបដិសេធ ដកហូត ព្យួរ ដាក់លក្ខខណ្ឌនានា ឬដាក់កម្រិតការអនុញ្ញាតធ្វើប្រតិបត្តិការ ឬការអនុញ្ញាតផ្នែកបច្ចេកទេសរបស់ក្រុមហ៊ុនអាកាសចរណ៍របស់ភាគីផ្សេងទៀត ដើម្បីធានាការអនុលោមតាមបទប្បញ្ញត្តិនៃមាត្រានេះ។ នៅពេលមានតម្រូវការក្នុងគ្រាអាសន្ន ឬដើម្បីការពារការមិនអនុលោមតាមមាត្រានេះ ភាគីទីមួយអាចចាត់វិធានការបណ្តោះអាសន្នដើម្បីបដិសេធ ដកហូត ព្យួរ ដាក់លក្ខខណ្ឌនានា ឬដាក់កម្រិតការអនុញ្ញាតធ្វើប្រតិបត្តិការ ឬការអនុញ្ញាតផ្នែកបច្ចេកទេសរបស់ក្រុមហ៊ុនអាកាសចរណ៍របស់ភាគីផ្សេងទៀតនោះ ដើម្បីធានាបាននូវការអនុលោមតាមបទប្បញ្ញត្តិនៃមាត្រានេះ។

១១- រាល់វិធានការដែលបានធ្វើឡើងដោយអនុលោមតាមកថាខណ្ឌទី១០នៃមាត្រានេះដោយភាគីទីមួយដែលចែងក្នុងកថាខណ្ឌនោះ ត្រូវបញ្ឈប់នៅពេលអនុលោមតាមមាត្រានេះដោយភាគីផ្សេងទៀតដែលពាក់ព័ន្ធ។

## មាត្រា១៧
## ការគ្រប់គ្រងចរាចរណ៍ផ្លូវអាកាស

១- រដ្ឋភាគីព្រមព្រៀងគ្នាសហការលើបញ្ហាទាក់ទងនឹងសេវាកម្មនាំផ្លូវអាកាស រួមទាំងការត្រួតពិនិត្យសុវត្ថិភាពរបស់ខ្លួន។ ភាគីនីមួយៗព្រមព្រៀងគ្នាក្នុងការដោះស្រាយបញ្ហាគោលនយោបាយណាមួយដែលទាក់ទងនឹងការអនុវត្តនៃការគ្រប់គ្រងចរាចរណ៍ផ្លូវអាកាស ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃការហោះហើររួម កាត់បន្ថយការចំណាយ កាត់បន្ថយផលប៉ះពាល់បរិស្ថាន និងការលើកកម្ពស់សុវត្ថិភាពនិងសមត្ថភាពនៃលំហូរចរាចរណ៍ផ្លូវអាកាសរវាងប្រព័ន្ធគ្រប់គ្រងចរាចរណ៍ផ្លូវអាកាសដែលមានស្រាប់របស់រដ្ឋភាគី។

២- រដ្ឋភាគីព្រមព្រៀងគ្នាក្នុងការជំរុញដល់អាជ្ញាធរមានសមត្ថកិច្ចនិងអ្នកផ្តល់សេវាកម្មនាំផ្លូវអាកាសឱ្យសហការក្នុងការជានាឱ្យមានប្រតិបត្តិការរួមគ្នារវាងប្រព័ន្ធគ្រប់គ្រងចរាចរណ៍ផ្លូវអាកាសនានារបស់រដ្ឋភាគី និងស្វែងរកសមាហរណកម្មបន្ថែមទៀតនៃប្រព័ន្ធនានារបស់រដ្ឋភាគី ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថានអាកាសចរណ៍ និងចែករំលែកព័ត៌មាននៅពេលវេលាដែលសមស្រប។

៣- រដ្ឋភាគីព្រមព្រៀងគ្នាក្នុងការជំរុញកិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវាកម្មនាំផ្លូវអាកាសរបស់ខ្លួនដើម្បីផ្លាស់ប្តូរទិន្នន័យហោះហើរ និងសម្របសម្រួលលំហូរចរាចរណ៍ ដើម្បីបង្កើនប្រសិទ្ធភាពនៃការហោះហើរក្នុងគោលបំណងដើម្បីសម្រេចបាននូវភាពប្រសើរនៃការព្យាករ ភាពទៀងទាត់នៃពេលវេលា និងការបន្តសេវាកម្មសម្រាប់ចរាចរណ៍ផ្លូវអាកាស។

៤- រដ្ឋភាគីព្រមព្រៀងគ្នាសហការលើកម្មវិធីទំនើបកម្មនៃការគ្រប់គ្រងចរាចរណ៍ផ្លូវអាកាសរបស់ខ្លួន រួមទាំងសក[illegible]និងការដាក់ពង្រាយការងារ និងជំរុញឱ្យមានការចូលរួមក្នុងសកម្មភាពដែលមានសុពលភាពនិងការ[illegible]ៗ។

## មាត្រា១៨
## បរិស្ថាន

១- រដ្ឋភាគីគាំទ្រសេចក្តីត្រូវការនៃការការពារបរិស្ថានតាមរយៈការជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៃអាកាសចរណ៍។ រដ្ឋភាគីមានបំណងធ្វើការងាររួមគ្នាដើម្បីកំណត់បញ្ហាទាក់ទងនឹងផលប៉ះពាល់អាកាសចរណ៍អន្តរជាតិស្តីពីបរិស្ថាន។

២- រដ្ឋភាគីទទួលស្គាល់សារៈសំខាន់នៃការធ្វើការងាររួមគ្នានិងជាមួយសហគមន៍សកលលោក ដើម្បីពិនិត្យនិងកាត់បន្ថយផលប៉ះពាល់អាកាសចរណ៍ស្តីពីបរិស្ថាន។

៣- រដ្ឋភាគីបញ្ជាក់ជាថ្មីអំពីសារៈសំខាន់នៃការដោះស្រាយការប្រែប្រួលអាកាសធាតុ ហើយដើម្បីសម្រេចបាននូវគោលបំណងនេះ រដ្ឋភាគីព្រមព្រៀងសហការគ្នាក្នុងការដោះស្រាយការបំភាយឧស្ម័នផ្ទះកញ្ចក់(តទៅនេះហៅកាត់ថា «ជីអេចជី-GHG») ការបំភាយឧស្ម័នដែលទាក់ទងនឹងអាកាសចរណ៍ ទាំងក្នុងស្រុកនិងអន្តរជាតិ។

៤- រដ្ឋភាគីព្រមព្រៀងគ្នាផ្លាស់ប្តូរព័ត៌មាន និងមានការពិភាក្សាជាទៀងទាត់ក្នុងចំណោមអ្នកជំនាញនានាដើម្បីបង្កើនកិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយផលប៉ះពាល់បរិស្ថាននៃអាកាសចរណ៍អន្តរជាតិ រួមទាំងផ្នែកមួយចំនួន ដូចជាការស្រាវជ្រាវនិងការអភិវឌ្ឍ ប្រេងឥន្ធនៈអាកាសចរណ៍ប្រកបដោយចីរភាព បញ្ហាទាក់ទងនឹងសំឡេងរំខាន និងវិធានការផ្សេងទៀតដែលសំដៅដោះស្រាយការបំភាយឧស្ម័នផ្ទះកញ្ចក់(ជីអេចជី-GHG) ដោយគិតគូរពីសិទ្ធិនិងកាតព្វកិច្ចបរិស្ថានពហុភាគីរបស់ខ្លួន។

៥- រដ្ឋភាគីទទួលស្គាល់ពីសេចក្តីត្រូវការក្នុងការចាត់វិធានការសមស្របដើម្បីការពារឬដោះស្រាយផលប៉ះពាល់បរិស្ថាននៃការដឹកជញ្ជូនតាមផ្លូវអាកាស ដរាបណាវិធានការនេះ គឺអនុលោមទាំងស្រុងជាមួយនឹងសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិ។

## មាត្រា១៩
## ការទទួលខុសត្រូវរបស់ក្រុមហ៊ុនអាកាសចរណ៍

រដ្ឋភាគីដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាក្រុងម៉ុងរ៉េអាល់ បញ្ជាក់ឡើងវិញនូវកាតព្វកិច្ចរបស់ខ្លួនក្រោមអនុសញ្ញាក្រុងម៉ុងរ៉េអាល់។ រដ្ឋភាគីដែលមិនទាន់បានផ្តល់សច្ចាប័នលើអនុសញ្ញាក្រុងម៉ុងរ៉េអាល់ ត្រូវផ្តល់សច្ចាប័ន ឲ្យបានឆាប់បំផុតដែលអាចធ្វើទៅបាន ហើយត្រូវជូនដំណឹងដល់គណៈកម្មាធិការចម្រុះ តាមការគួរ។



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា២០
## ការការពារអ្នកប្រើប្រាស់

រដ្ឋភាគីព្រមព្រៀងគ្នាសហការដើម្បីការពារអត្ថប្រយោជន៍របស់អ្នកប្រើប្រាស់ក្នុងការដឹកជញ្ជូនតាមផ្លូវអាកាស។ គោលបំណងនៃកិច្ចសហប្រតិបត្តិការនេះ គឺដើម្បីសម្រេចបាននូវកម្រិតខ្ពស់នៃការការពារអ្នកប្រើប្រាស់ ដោយគិតអំពីអត្ថប្រយោជន៍នៃប្រតិបត្តិករ និងលក្ខណៈផ្សេងគ្នារបស់រដ្ឋភាគីពាក់ព័ន្ធទាំងអស់។ ដើម្បីសម្រេចបាននូវគោលបំណងនេះ រដ្ឋភាគីត្រូវពិគ្រោះយោបល់គ្នាទៅវិញទៅមកនៅក្នុងគណៈកម្មាធិការចម្រុះលើបញ្ហាអត្ថប្រយោជន៍របស់អ្នកប្រើប្រាស់ រួមទាំងវិធានការដែលបានគ្រោងទុក ក្នុងគោលបំណងដើម្បីសម្រេចបាននូវភាពចុះសម្រុងនឹងគ្នាកាន់តែប្រសើរឡើង រវាងរបបរៀងៗខ្លួនរបស់រដ្ឋភាគីតាមលទ្ធភាពដែលអាចធ្វើទៅបាន។

## មាត្រា២១
## ប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ

១- អ្នកលក់ប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS) ដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងដែនដីនៃភាគីមួយត្រូវបានអនុញ្ញាតឱ្យនាំយកមក រក្សាទុក និងធ្វើប្រតិបត្តិការដោយសេរីនៃប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS)របស់ខ្លួនដល់ភ្នាក់ងារទេសចរណ៍ឬក្រុមហ៊ុនទេសចរណ៍នានា ដែលមានកន្លែងប្រកបអាជីវកម្មជាគោលដើមនៅក្នុងដែនដីនៃភាគីមួយផ្សេងទៀត ដែលចែកចាយផលិតផលទាក់ទងនឹងការធ្វើដំណើរ ដរាបណាប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS) អនុលោមតាមលក្ខខណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធណាមួយនៃភាគីផ្សេងទៀតនោះ។

២- រដ្ឋភាគីត្រូវទុកជាមោឃភាពនូវលក្ខខណ្ឌមានស្រាប់ដែលអាចរឹតបន្តឹងការចូលប្រើប្រាស់ដោយសេរីនៃប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS)របស់ភាគីមួយ ទៅកាន់ទីផ្សាររបស់ភាគីមួយផ្សេងទៀត ឬបើមិនដូច្នេះទេ ត្រូវដាក់កម្រិតការប្រកួតប្រជែងរវាងអ្នកលក់ប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS)នានា។ រដ្ឋភាគីត្រូវបដិសេធក្នុងការទទួលយកនូវលក្ខខណ្ឌបែបនេះនៅពេលអនាគត។

៣- នៅក្នុងដែនដីរបស់ខ្លួន គ្មានភាគីណាមួយត្រូវកំណត់យកឬអនុញ្ញាតឱ្យយកលើអ្នកលក់ប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS)តាមលក្ខខណ្ឌនៃភាគីមួយផ្សេងទៀត ទាក់ទងនឹងការដាក់បង្ហាញប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS)ដែលខុសពីការយកលើអ្នកលក់ប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS)របស់ខ្លួន ឬប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS)ណាមួយផ្សេងទៀតដែលកំពុងធ្វើប្រតិបត្តិការនៅលើទីផ្សាររបស់ខ្លួន។ គ្មានភាគីណាមួយត្រូវរារាំងការបញ្ចប់កិច្ចព្រមព្រៀងរវាងអ្នកលក់ប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS) អ្នកផ្តល់សេវាកម្មរបស់ខ្លួន និងអតិថិជនរបស់ខ្លួន ដែលជួយសម្រួលដល់ការដាក់បង្ហាញព័ត៌មានការធ្វើដំណើរទូលំទូលាយ និងមិនលម្អៀងដល់អ្នកប្រើប្រាស់ ឬការបំពេញលក្ខខណ្ឌបទប្បញ្ញត្តិក្នុង[illegible]អព្យាក្រឹត។

៤- ម្ចាស់និងប្រតិបត្តិករប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS)នានានៃភាគីមួយ ដែលស្ថិតក្រោមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិពាក់ព័ន្ធភាគីមួយផ្សេងទៀត ត្រូវមានកាលានុវត្តភាពដូចគ្នាជាម្ចាស់ឬធ្វើប្រតិបត្តិការប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS)នៅក្នុងដែនដីនៃភាគីផ្សេងទៀតនោះ ដូចជាម្ចាស់និងប្រតិបត្តិករនានានៃប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS)ផ្សេងទៀតដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងទីផ្សារនៃភាគីផ្សេងទៀតដែរ។

៥- នៅពេលដែលប្រព័ន្ធកក់ទុកតាមកុំព្យូទ័រ( ស៊ីអរអេស-CRS)ស្ថិតក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (នៅក្រោមកថាខណ្ឌទី១នៃមាត្រា៥ចំណុចទី១ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម)ដែលត្រូវបានចុះហត្ថលេខា ឬនៅក្នុងការចរចារវាងសហភាពនិងរដ្ឋសមាជិកអាស៊ានមួយ កថាខណ្ឌទី១ដល់កថាខណ្ឌទី៤ នៃមាត្រានេះ មិនត្រូវអនុវត្តចំពោះរដ្ឋសមាជិកអាស៊ាននោះទេ។

## មាត្រា២២
## និរន្តរភាពសង្គម

១- រដ្ឋភាគីទទួលស្គាល់ពីសារៈសំខាន់នៃការពិចារណាពីផលប៉ះពាល់នៃកិច្ចព្រមព្រៀងនេះស្តីពីកម្លាំងពលកម្ម ការងារ និងលក្ខខណ្ឌការងារ។ រដ្ឋភាគីព្រមព្រៀងគ្នាសហការលើបញ្ហាកម្លាំងពលកម្មក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះ រួមទាំងទាក់ទងនឹងផលប៉ះពាល់លើការងារ សិទ្ធិជាមូលដ្ឋាននៅកន្លែងធ្វើការងារ លក្ខខណ្ឌការងារ ការការពារសង្គម និងកិច្ចសន្ទនាសង្គម។

២- រដ្ឋភាគីទទួលស្គាល់សិទ្ធិនៃភាគីនីមួយៗក្នុងការបង្កើតកម្រិតនៃការការពារកម្លាំងពលកម្មក្នុងស្រុកផ្ទាល់របស់ខ្លួន តាមដែលខ្លួនយល់ឃើញថាសមស្រប និងដើម្បីអនុម័តឬកែប្រែស្របតាមច្បាប់និងគោលនយោបាយពាក់ព័ន្ធរបស់ខ្លួន ស្របតាមគោលការណ៍នៃស្តង់ដាទទួលស្គាល់ជាអន្តរជាតិនៅក្នុងអនុសញ្ញាអន្តរជាតិដែលខ្លួនជាភាគី។ រដ្ឋភាគីត្រូវធានាថា សិទ្ធិនិងគោលការណ៍ដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិនានារៀងៗខ្លួន មិនត្រូវបានប៉ះពាល់ទេ ប៉ុន្តែត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។

៣- ភាគីនីមួយៗត្រូវបន្តធ្វើឱ្យប្រសើរឡើងនូវច្បាប់និងគោលនយោបាយនានារបស់ខ្លួន ហើយត្រូវខិតខំប្រឹងប្រែងផ្តល់និងលើកទឹកចិត្តដល់កម្រិតខ្ពស់នៃការការពារកម្លាំងពលកម្មក្នុងវិស័យអាកាសចរណ៍។ រដ្ឋភាគីទទួលស្គាល់ថាការរំលោភលើគោលការណ៍ជាមូលដ្ឋាននិងសិទ្ធិនៅកន្លែងធ្វើការងារមិនអាចត្រូវបានអនុវត្តឬប្រើជាឧត្តមភាពប្រៀបធៀបស្របច្បាប់នោះទេ ហើយស្តង់ដាកម្លាំងពលកម្មមិនគួរត្រូវបានប្រើប្រាស់សម្រាប់គោលបំណងគាំពារ

៤- រដ្ឋភាគីបញ្ជាក់សាជាថ្មីក្នុងការប្ដេជ្ញាចិត្តរបស់ខ្លួន ដោយអនុលោមតាមកាតព្វកិច្ចរបស់ខ្លួន ដែលកើតចេញពីសមាជិកភាពរបស់ខ្លួននៅក្នុងអង្គការពលកម្មអន្តរជាតិ(តទៅនេះហៅកាត់ថា «អាយអិលអូ-ILO») និងសេចក្ដីប្រកាសរបស់អង្គការពលកម្មអន្តរជាតិ(អាយអិលអូ-ILO) ស្ដីពីគោលការណ៍ជាមូលដ្ឋាននិងសិទ្ធិនៅកន្លែងធ្វើការងារ និងការតាមដានរបស់ខ្លួនដែលបានអនុម័តនៅក្រុងហ្សឺណែវ នាថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៩៨ ដើម្បីអនុវត្ត ផ្សព្វផ្សាយ និងទទួលស្គាល់សេចក្ដីប្រកាសនោះ។

៥- រដ្ឋភាគីត្រូវលើកកម្ពស់គោលបំណងដែលមាននៅក្នុងរបៀបវារៈការងារសមរម្យរបស់អង្គការពលកម្មអន្តរជាតិ(អាយអិលអូ-ILO) និងសេចក្ដីប្រកាសរបស់អង្គការពលកម្មអន្តរជាតិ(អាយអិលអូ-ILO)ស្ដីពីយុត្តិធម៌សង្គមសម្រាប់សកលភាវូបនីយកម្មដោយយុត្តិធម៌ ដែលបានអនុម័តនៅក្រុងហ្សឺណែវ នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨។

៦- ភាគីនីមួយៗត្រូវខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពដើម្បីផ្ដល់សច្ចាប័នលើអនុសញ្ញាអាយអិលអូ-ILO ជាមូលដ្ឋាន ដែលខ្លួនមិនទាន់បានផ្ដល់សច្ចាប័ននៅឡើយ ។ រដ្ឋភាគីក៏នឹងពិនិត្យពិចារណាផងដែរអំពីការផ្ដល់សច្ចាប័ននិងការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃអនុសញ្ញាអង្គការពលកម្មអន្តរជាតិ(អាយអិលអូ-ILO) និងស្តង់ដាអន្តរជាតិនានាក្នុងវិស័យកម្លាំងពលកម្មនិងសង្គម ដោយយកចិត្តទុកដាក់ពីស្ថានភាពក្នុងស្រុកដែលពាក់ព័ន្ធនឹងវិស័យអាកាសចរណ៍ស៊ីវិល។

៧- ភាគីណាមួយអាចស្នើសុំប្រជុំគណៈកម្មាធិការចម្រុះ ដើម្បីដោះស្រាយបញ្ហាកម្លាំងពលកម្មនិងផ្លាស់ប្ដូរព័ត៌មានពាក់ព័ន្ធ ដែលខ្លួនកំណត់ថាមានសារៈសំខាន់។

## មាត្រា២៣
## គណៈកម្មាធិការចម្រុះ

១- គណៈកម្មាធិការចម្រុះមួយដែលមានតំណាងនៃរដ្ឋភាគី ត្រូវទទួលខុសត្រូវក្នុងការត្រួតពិនិត្យការគ្រប់គ្រងនៃកិច្ចព្រមព្រៀងនេះនិងធានាការអនុវត្តបានត្រឹមត្រូវរបស់ខ្លួន។

២- គណៈកម្មាធិការចម្រុះ ត្រូវបង្កើតនិងអនុម័តវិធាននៃនីតិវិធីរបស់ខ្លួន។

៣- គណៈកម្មាធិការចម្រុះ ត្រូវជួបប្រជុំតាមការចាំបាច់និងយ៉ាងហោចណាស់ជួបប្រជុំម្ដងក្នុងមួយឆ្នាំ។ ភាគីណាមួយអាចស្នើសុំការកោះប្រជុំគណៈកម្មាធិការចម្រុះនៅពេលណាក៏បាន។ ការជួបប្រជុំនេះ ត្រូវចាប់ផ្ដើមនៅកាលបរិច្ឆេទដំបូងបំផុតដែលអាចធ្វើទៅបាន និងមិនយូរជាង២(ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើដែលមានការគាំទ្រនិងការយល់ព្រមពីរដ្ឋភាគី។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៤- សម្រាប់គោលបំណងការអនុវត្តត្រឹមត្រូវនៃកិច្ចព្រមព្រៀងនេះ គណៈកម្មាធិការចម្រុះ ត្រូវ៖

(ក) ផ្លាស់ប្តូរព័ត៌មាន រួមទាំងការផ្លាស់ប្តូរច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយនានារបស់រដ្ឋភាគីរៀងៗខ្លួន ដែលអាចប៉ះពាល់ដល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក៏ដូចជាព័ត៌មានស្ថិតិក្នុងគោលបំណងត្រួតពិនិត្យការអភិវឌ្ឍសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសក្រោមកិច្ចព្រមព្រៀងនេះ។

(ខ) ផ្តល់អនុសាសន៍និងធ្វើការសម្រេចចិត្ត ដែលបានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀងនេះ។

(គ) អភិវឌ្ឍកិច្ចសហប្រតិបត្តិការ រួមទាំងលើបញ្ហាបទប្បញ្ញត្តិ។

(ឃ) ធ្វើការពិគ្រោះយោបល់លើបញ្ហាណាមួយដែលទាក់ទងនឹងការអនុវត្តឬការបកស្រាយនៃកិច្ចព្រមព្រៀងនេះ។

(ង) រៀបចំការពិគ្រោះយោបល់នៅពេលដែលសមស្របលើបញ្ហាការដឹកជញ្ជូនតាមផ្លូវអាកាសដែលជាប់ទាក់ទងជាមួយអង្គការអន្តរជាតិ មានទំនាក់ទំនងជាមួយប្រទេសទីបី ក្នុងការរៀបចំកិច្ចព្រមព្រៀងឬកិច្ចព្រមព្រៀងពហុភាគីនានា រួមទាំងថាតើ ត្រូវអនុម័តវិធីសាស្ត្ររួមដែរឬទេ។

(ច) ពិនិត្យពិចារណាលើផ្នែកដែលមានសក្តានុពលសម្រាប់ការអភិវឌ្ឍបន្ថែមទៀតនៃកិច្ចព្រមព្រៀងនេះ រួមទាំងអនុសាសន៍នៃការធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះ និង

(ឆ) សម្រេចលើភាសាត្រឹមត្រូវថ្មីណាមួយនៃកិច្ចព្រមព្រៀងនេះ ក្នុងករណីការចូលជាសមាជិកថ្មីរបស់រដ្ឋសមាជិកសហភាពអឺរ៉ុប។

៥- អនុសាសន៍និងសេចក្តីសម្រេចនានា ត្រូវបានអនុម័តដោយឯកច្ឆន្ទ រវាងសហភាពនិងរដ្ឋសមាជិករបស់ខ្លួននៃផ្នែកមួយ និងរដ្ឋសមាជិកអាស៊ានទាំងអស់ដែលធ្វើសកម្មភាពរួមគ្នានៃផ្នែកមួយផ្សេងទៀត។ សេចក្តីសម្រេចដែលធ្វើឡើងដោយគណៈកម្មាធិការចម្រុះត្រូវរួមបញ្ចូលទាំងរដ្ឋភាគី។

**មាត្រា២៤**
**ការអនុវត្ត**

១- គ្មានបទប្បញ្ញត្តិណាមួយចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបកស្រាយថា មានបំណងផ្តល់សិទ្ធិឬកំណត់កាតព្វកិច្ចដែលអាចត្រូវបានកោះហៅពលរដ្ឋនៃភាគីមួយដោយផ្ទាល់ នៅចំពោះមុខតុលាការឬសាលាក្តីនៃភាគី

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- រដ្ឋភាគីត្រូវចាត់វិធានការសមស្របគ្រប់បែបយ៉ាង មិនថាទូទៅឬជាក់លាក់ ដើម្បីធានាការបំពេញកាតព្វកិច្ច ដែលកើតចេញពីកិច្ចព្រមព្រៀងនេះ។

៣- ក្នុងការអនុវត្តសិទ្ធិរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ រដ្ឋភាគីត្រូវចាត់វិធានការសមស្របនិងសមាមាត្រ ទៅនឹងគោលបំណងរៀងៗខ្លួន។

៤- រដ្ឋភាគីត្រូវបដិសេធវិធានការណាដែលបង្កឱ្យគ្រោះថ្នាក់ដល់ការសម្រេចបាននូវគោលបំណងនៃកិច្ចព្រមព្រៀងនេះ។

៥- ភាគីនីមួយៗត្រូវទទួលខុសត្រូវចំពោះការអនុវត្តត្រឹមត្រូវនៃកិច្ចព្រមព្រៀងនេះនៅក្នុងដែនដីផ្ទាល់របស់ខ្លួន។

៦- ស្ថិតក្រោមច្បាប់និងបទប្បញ្ញត្តិនានាដែលអាចអនុវត្តបានរបស់រដ្ឋភាគីរៀងៗខ្លួន ភាគីនីមួយៗត្រូវផ្តល់ឱ្យ ភាគីមួយផ្សេងទៀតនូវព័ត៌មាននិងជំនួយចាំបាច់ទាំងអស់ ក្នុងករណីស៊ើបអង្កេតលើការរំលោភដែលអាច កើតមាន ដែលភាគីផ្សេងទៀតនោះអនុវត្ត ស្របតាមកិច្ចព្រមព្រៀងនេះ។

៧- កិច្ចព្រមព្រៀងនេះមិនត្រូវរារាំងការពិគ្រោះយោបល់និងការពិភាក្សារវាងអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋភាគី នៅខាងក្រៅគណៈកម្មាធិការចម្រុះ រួមទាំងផ្នែកអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវអាកាស សន្តិសុខ សុវត្ថិភាព បរិស្ថាន គោលនយោបាយសង្គម ការគ្រប់គ្រងចរាចរណ៍ផ្លូវអាកាស ហេដ្ឋារចនាសម្ព័ន្ធអាកាសចរណ៍ បញ្ហាការប្រកួតប្រជែង និងការការពារអ្នកប្រើប្រាស់។ រដ្ឋភាគីត្រូវជូនដំណឹងដល់គណៈកម្មាធិការចម្រុះអំពីលទ្ធផលនៃការពិគ្រោះ យោបល់ និងការពិភាក្សាដែលអាចមានផលប៉ះពាល់ដល់ការបកស្រាយ ឬការអនុវត្តកិច្ចព្រមព្រៀងនេះ។

៨- នៅពេលដែលឯកសារយោងត្រូវបានធ្វើឡើងនៅក្នុងកិច្ចព្រមព្រៀងនេះលើកិច្ចសហប្រតិបត្តិការរវាងរដ្ឋភាគី រដ្ឋភាគីត្រូវព្យាយាមស្វែងរកមូលដ្ឋានរួមសម្រាប់សកម្មភាពរួមគ្នា ដើម្បីអភិវឌ្ឍកិច្ចព្រមព្រៀងនេះបន្ថែមទៀត និង/ឬធ្វើឱ្យប្រសើរឡើងនូវមុខងាររបស់ខ្លួននៅក្នុងផ្នែកដែលពាក់ព័ន្ធ ដោយផ្អែកលើការព្រមព្រៀងគ្នាទៅវិញទៅមក។

## មាត្រា២៥
## ការដោះស្រាយវិវាទនិងមជ្ឈត្តកម្ម

១- ដោយគ្មានការរើសអើងចំពោះមាត្រា៥និងមាត្រា៨ វិវាទណាមួយដែលទាក់ទងនឹងការអនុវត្តឬការបកស្រាយ នៃកិច្ចព្រមព្រៀងនេះ ដែលអាចចែងដោយរដ្ឋភាគីមួយឬរដ្ឋភាគីច្រើន ចំពោះយន្តការដោះស្រាយវិវាទដូចបាន ចែងក្នុងមាត្រានេះ។

២- ដោយមិនមានការលម្អៀងចំពោះការពិគ្រោះយោបល់ពីមុនណាមួយរវាងរដ្ឋភាគីក្រោមកិច្ចព្រមព្រៀងនេះ ដែលភាគីមួយចង់ទទួលបានដំណោះស្រាយចំពោះយន្តការដោះស្រាយវិវាទដូចបានកំណត់ក្នុងមាត្រានេះ ត្រូវជូនដំណឹងទៅភាគីមួយឬរដ្ឋភាគីដែលពាក់ព័ន្ធជាលាយលក្ខណ៍អក្សរអំពីបំណងរបស់ខ្លួន និងស្នើសុំកិច្ចប្រជុំគណៈកម្មាធិការចម្រុះសម្រាប់ការពិគ្រោះយោបល់នានា។

៣- (ក) ប្រសិនបើ៖

(i) គណៈកម្មាធិការចម្រុះមិនបានពិភាក្សាអំពីបញ្ហានេះក្នុងរយៈពេល២(ពីរ)ខែ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើដែលមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ ឬតាមកាលបរិច្ឆេទដែលបានព្រមព្រៀងគ្នាដោយរដ្ឋភាគី ឬ

(ii) វិវាទមិនត្រូវបានដោះស្រាយក្នុងរយៈពេល៦(ប្រាំមួយ)ខែនៃសំណើនេះ។

វិវាទអាចត្រូវបានបញ្ជូនទៅបុគ្គលឬស្ថាប័នសម្រាប់ធ្វើការសម្រេចដោយការព្រមព្រៀងគ្នារបស់រដ្ឋភាគីពាក់ព័ន្ធ។

(ខ) ប្រសិនបើរដ្ឋភាគីពាក់ព័ន្ធមិនអាចឈានដល់ការព្រមព្រៀងគ្នាទៅវិញទៅមក ដើម្បីបញ្ជូនវិវាទទៅបុគ្គលឬស្ថាប័នសម្រាប់ធ្វើការសម្រេច នោះវិវាទត្រូវដាក់ជូនទៅមជ្ឈត្តកម្មស្របតាមមាត្រានេះ តាមសំណើរបស់រដ្ឋភាគីណាមួយ។

៤- ទោះបីជាមានចែងក្នុងកថាខណ្ឌទី២និងកថាខណ្ឌទី៣នៃមាត្រានេះក៏ដោយ ប្រសិនបើភាគីណាមួយបានចាត់វិធានការដើម្បីបដិសេធ ដកហូត ព្យួរ ដាក់លក្ខខណ្ឌនានា ឬដាក់កម្រិតការអនុញ្ញាតធ្វើប្រតិបត្តិការ ឬការអនុញ្ញាតផ្នែកបច្ចេកទេសរបស់ក្រុមហ៊ុនអាកាសចរណ៍របស់ភាគីមួយផ្សេងទៀត ឬដើម្បីបដិសេធ ព្យួរ ដាក់លក្ខខណ្ឌនានា ឬដាក់កម្រិតការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនអាកាសចរណ៍មួយរបស់ភាគីផ្សេងទៀតនោះ វិវាទអាចត្រូវបញ្ជូនទៅបុគ្គលឬស្ថាប័នណាមួយជាបន្ទាន់ ដើម្បីធ្វើការសម្រេច ឬបញ្ជូនទៅមជ្ឈត្តកម្ម។ ការកំណត់ពេលវេលារៀងៗខ្លួនដែលមានចែងក្នុងកថាខណ្ឌទី១០ កថាខណ្ឌទី១១ និងកថាខណ្ឌទី១២នៃមាត្រានេះ ត្រូវកាត់បន្ថយពាក់កណ្ដាល។

៥- សំណើសុំមជ្ឈត្តកម្ម ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយភាគីមួយឬរដ្ឋភាគីច្រើន(តទៅនេះហៅកាត់ជារួមថា «ភាគីផ្ដួចផ្ដើម» សម្រាប់គោលបំណងនៃមាត្រានេះ) ទៅកាន់ភាគីឬរដ្ឋភាគីដែលពាក់ព័ន្ធ(តទៅនេះហៅកាត់ជារួមថា «ភាគីឆ្លើយតប» សម្រាប់គោលបំណងនៃមាត្រានេះ)។ នៅក្នុងសំណើសុំរបស់ខ្លួន ភាគីផ្ដួចផ្ដើមត្រូវបង្ហាញបញ្ហាដែលត្រូវដោះស្រាយ ពិពណ៌នាអំពីវង្វាស់នៃបញ្ហា និងពន្យល់ពីមូលហេតុដែលខ្លួនចាត់ទុកថា វិធានការដែលមិនស្របនឹងកិច្ចព្រមព្រៀងនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៦- លុះត្រាតែភាគីផ្តួចផ្តើមនិងភាគីឆ្លើយតបព្រមព្រៀងគ្នាផ្សេងពីនេះ មជ្ឈត្តកម្មត្រូវធ្វើឡើងដោយសាលាក្តីនៃមជ្ឈត្តករបីរូប ដែលត្រូវបានបង្កើតឡើង ដូចខាងក្រោម៖

(ក) ក្នុងរយៈពេល២០(ម្ភៃ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានសំណើសម្រាប់មជ្ឈត្តកម្ម ភាគីផ្តួចផ្តើមនិងភាគីឆ្លើយតបត្រូវតែងតាំងមជ្ឈត្តករមួយរូប។ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីមជ្ឈត្តករទាំងពីរនេះត្រូវបានតែងតាំង ភាគីផ្តួចផ្តើមនិងភាគីឆ្លើយតប ត្រូវមានការព្រមព្រៀងគ្នាតែងតាំងមជ្ឈត្តករទីបី ដែលត្រូវដើរតួជាប្រធានសាលាក្តី។

(ខ) ប្រសិនបើភាគីផ្តួចផ្តើមឬភាគីឆ្លើយតបខកខានក្នុងការតែងតាំងមជ្ឈត្តករមួយរូប ឬប្រសិនបើមជ្ឈត្តករទីបីមិនត្រូវបានតែងតាំងស្របតាមកថាខណ្ឌទី៦ចំណុច(ក)នៃមាត្រានេះ ភាគីផ្តួចផ្តើមឬភាគីឆ្លើយតប អាចស្នើសុំប្រធានក្រុមប្រឹក្សាអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដើម្បីតែងតាំងមជ្ឈត្តករមួយរូបឬមជ្ឈត្តករច្រើនរូបតាមការចាំបាច់ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណើនោះ។ ប្រសិនបើប្រធានក្រុមប្រឹក្សាអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ជាពលរដ្ឋនៃរដ្ឋសមាជិកអាស៊ានមួយ ឬរដ្ឋសមាជិកសហភាពអឺរ៉ុបមួយ អនុប្រធានជាន់ខ្ពស់នៃក្រុមប្រឹក្សានោះ ដែលមិនមែនជាពលរដ្ឋនៃរដ្ឋសមាជិកអាស៊ានមួយឬពលរដ្ឋនៃរដ្ឋសមាជិកសហភាពអឺរ៉ុបមួយ ត្រូវធ្វើការតែងតាំង។

៧- កាលបរិច្ឆេទបង្កើតសាលាក្តី គឺជាកាលបរិច្ឆេទដែលមជ្ឈត្តករចុងក្រោយនៃមជ្ឈត្តករទាំង៣(បី) ទទួលការតែងតាំង។

៨- ដំណើរការមជ្ឈត្តកម្មត្រូវធ្វើឡើងដោយអនុលោមតាមវិធាននីតិវិធីដែលត្រូវអនុម័តដោយគណៈកម្មាធិការចម្រុះនៅក្នុងកិច្ចប្រជុំលើកដំបូងរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៃមាត្រានេះនិងស្របតាមកថាខណ្ឌទី៤ចំណុច(ខ)និងកថាខណ្ឌទី៥នៃមាត្រា២៣។ សាលាក្តីត្រូវបង្កើតវិធាននីតិវិធីផ្ទាល់របស់ខ្លួន រហូតដល់ពេលដែលគណៈកម្មាធិការចម្រុះបានអនុម័តវិធាននីតិវិធីនានា។

៩- តាមសំណើរបស់ភាគីផ្តួចផ្តើមឬភាគីឆ្លើយតប សាលាក្តីអាចរង់ចាំការសម្រេចចុងក្រោយរបស់ខ្លួន បង្គាប់ឱ្យអនុម័តវិធានការដោះស្រាយបណ្តោះអាសន្ន រួមទាំងការកែប្រែឬការព្យួរវិធានការដែលធ្វើឡើងដោយភាគីផ្តួចផ្តើមឬភាគីឆ្លើយតប ស្ថិតក្រោមកិច្ចព្រមព្រៀងនេះ។

១០- សាលាក្តីត្រូវចេញរបាយការណ៍បណ្តោះអាសន្នមួយដល់ភាគីផ្តួចផ្តើមនិងភាគីឆ្លើយតប ដោយកំណត់ការរកឃើញការពិតប្រាកដ ការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធ និងហេតុផលជាមូលដ្ឋាននៅពីក្រោយការរកឃើញ និងអនុសាសន៍ណាមួយដែលខ្លួនបង្កើតមិនលើសពី៩០(កៅសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតរបស់ខ្លួន។

ក្នុងករណីដែលចាត់ទុកថា មិនអាចបំពេញតាមកាលកំណត់នេះ ប្រធានសាលាក្តីត្រូវជូនដំណឹងដល់ភាគីផ្តួចផ្តើម និងភាគីឆ្លើយតបជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីមូលហេតុនៃការពន្យារពេល និងកាលបរិច្ឆេទដែលសាលាក្តីគ្រោងនឹងចេញរបាយការណ៍បណ្តោះអាសន្នរបស់ខ្លួន។ មិនមានករណីណាមួយ ដែលសាលាក្តីត្រូវចេញរបាយការណ៍បណ្តោះអាសន្នលើសពី១២០(មួយរយម្ភៃ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតរបស់ខ្លួន។

១១- នៅក្នុងរង្វង់រយៈពេល១៤(ដប់បួន)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញរបាយការណ៍បណ្តោះអាសន្ន ភាគីផ្តួចផ្តើមឬភាគីឆ្លើយតបអាចដាក់សំណើជាលាយលក្ខណ៍អក្សរទៅកាន់សាលាក្តីដើម្បីពិនិត្យមើលទិដ្ឋភាពជាក់លាក់នៃរបាយការណ៍បណ្តោះអាសន្ន។ បន្ទាប់ពីបានពិនិត្យលើយោបល់ជាលាយលក្ខណ៍អក្សរណាមួយដោយភាគីផ្តួចផ្តើមនិងភាគីឆ្លើយតបលើរបាយការណ៍បណ្តោះអាសន្ននោះ សាលាក្តីអាចកែសម្រួលរបាយការណ៍របស់ខ្លួននិងត្រួតពិនិត្យបន្ថែមទៀត ដែលខ្លួនចាត់ទុកថាសមស្រប។ ការរកឃើញការសម្រេចចុងក្រោយរបស់សាលាក្តី ត្រូវរួមបញ្ចូលការពិភាក្សាលើអំណះអំណាងគ្រប់គ្រាន់ដែលបានធ្វើឡើងនៅដំណាក់កាលត្រួតពិនិត្យបណ្តោះអាសន្ន ហើយត្រូវឆ្លើយយ៉ាងច្បាស់នូវសំណួរ និងការពិនិត្យបន្ថែមរបស់ភាគីផ្តួចផ្តើមនិងភាគីឆ្លើយតប។

១២- សាលាក្តីត្រូវចេញសេចក្តីសម្រេចចុងក្រោយរបស់ខ្លួនដល់ភាគីផ្តួចផ្តើមនិងភាគីឆ្លើយតបនៅក្នុងរង្វង់រយៈពេល១២០(មួយរយម្ភៃ)ថ្ងៃ ចាប់ពីកាលបរិច្ឆេទបង្កើតរបស់ខ្លួន។ ក្នុងករណីដែលចាត់ទុកថា មិនអាចបំពេញតាមកាលកំណត់ នោះប្រធានសាលាក្តីត្រូវជូនដំណឹងដល់ភាគីផ្តួចផ្តើមនិងភាគីឆ្លើយតបជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់ពីមូលហេតុនៃការពន្យារពេលនិងកាលបរិច្ឆេទដែលសាលាក្តីគ្រោងនឹងចេញសេចក្តីសម្រេចរបស់ខ្លួន។ មិនមានករណីណាមួយដែលសាលាក្តីត្រូវចេញសេចក្តីសម្រេចចុងក្រោយរបស់ខ្លួនលើសពី១៥០(មួយរយហាសិប)ថ្ងៃ ចាប់បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតរបស់ខ្លួន។

១៣- បន្ថែមលើករណីដែលមានចែងក្នុងកថាខណ្ឌទី៤នៃមាត្រានេះ ការកំណត់ពេលវេលារៀងៗខ្លួនដែលបានបញ្ជាក់ក្នុងកថាខណ្ឌទី១០ កថាខណ្ឌទី១១ និងកថាខណ្ឌទី១២នៃមាត្រានេះ ត្រូវកាត់បន្ថយពាក់កណ្តាលៈ

(ក) តាមការស្នើសុំរបស់ភាគីផ្តួចផ្តើមឬភាគីឆ្លើយតប ប្រសិនបើសាលាក្តីសម្រេចថា ករណីនេះមានភាពបន្ទាន់នៅក្នុងរង្វង់រយៈពេល១០(ដប់)ថ្ងៃ ចាប់ពីការបង្កើតរបស់ខ្លួន ឬ

(ខ) ប្រសិនបើភាគីផ្តួចផ្តើមនិងភាគីឆ្លើយតបព្រមព្រៀងគ្នា។

១៤- ភាគីផ្តួចផ្តើមនិងភាគីឆ្លើយតបអាចដាក់សំណើសុំការបំភ្លឺអំពីសេចក្តីសម្រេចចុងក្រោយរបស់សាលាក្តី នៅក្នុងរង្វង់រយៈពេល១០(ដប់)ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទចេញប្រកាសរបស់ខ្លួន ហើយការបំភ្លឺណាមួយដោយសាលាក្តីត្រូវបញ្ចប់ក្នុងរង្វង់រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការទទួលយកសំណើនេះ។

១៥- ប្រសិនបើសាលាក្តីសម្រេចថា មានការរំលោភលើកិច្ចព្រមព្រៀងនេះ ហើយភាគីដែលបានរកឃើញថា មានការរំលោភលើកិច្ចព្រមព្រៀងនេះ មិនអនុវត្តស្របតាមសេចក្តីសម្រេចចុងក្រោយរបស់សាលាក្តី ឬមិនឈាន ដល់ការព្រមព្រៀងគ្នាជាមួយភាគីផ្សេងទៀតលើដំណោះស្រាយដែលពេញចិត្តទាំងសងខាងនៅក្នុងរង្វង់ រយៈពេល៤០(សែសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេចចុងក្រោយរបស់សាលាក្តី ភាគីផ្សេង ទៀតអាចព្យួរការអនុវត្តអត្ថប្រយោជន៍ស្រដៀងគ្នាដែលកើតឡើងក្រោមកិច្ចព្រមព្រៀងនេះ រហូតដល់ពេលភាគី បំពានអនុវត្តស្របតាមសេចក្តីសម្រេចចុងក្រោយរបស់សាលាក្តី ឬភាគីផ្តួចផ្តើមនិងភាគីឆ្លើយតបឈានដល់ការ ព្រមព្រៀងគ្នាលើដំណោះស្រាយដែលពេញចិត្តទាំងសងខាង។

## មាត្រា២៦
## ទំនាក់ទំនងជាមួយនឹងកិច្ចព្រមព្រៀងផ្សេងទៀត

១- យោងតាមកថាខណ្ឌទី២និងកថាខណ្ឌទី៧នៃមាត្រានេះ កិច្ចព្រមព្រៀង ឬការរៀបចំសេវាកម្មដឹកជញ្ជូនតាម ផ្លូវអាកាសពីមុនណាមួយរវាងរដ្ឋសមាជិកសហភាពអឺរ៉ុបមួយនិងរដ្ឋសមាជិកអាស៊ានមួយ ឬរវាងសហភាពនិង រដ្ឋសមាជិកអាស៊ានមួយ ត្រូវបានព្យួរខណៈពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមានរវាងរដ្ឋភាគីទាំងអស់នោះ។

២- ដោយមិនមានការលម្អៀងចំពោះកថាខណ្ឌទី១នៃមាត្រានេះ បទប្បញ្ញត្តិនៅក្នុងកិច្ចព្រមព្រៀង ឬការរៀបចំ សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសពីមុន រវាងរដ្ឋសមាជិកសហភាពអឺរ៉ុបមួយ និងរដ្ឋសមាជិកអាស៊ានមួយ ទាក់ទងនឹងបទប្បញ្ញត្តិដែលមានចែងក្នុងមាត្រា៣ មាត្រា៤ មាត្រា១០ និងមាត្រា១៣ ត្រូវបន្តអនុវត្តតាម កិច្ចព្រមព្រៀងនេះ ដែលជាបទប្បញ្ញត្តិមានលក្ខខណ្ឌអនុគ្រោះប្រសើរដល់ក្រុមហ៊ុនអាកាសចរណ៍ពាក់ព័ន្ធ។ សិទ្ធិនិងអត្ថប្រយោជន៍ទាំងអស់ដែលទទួលបានដោយក្រុមហ៊ុនអាកាសចរណ៍របស់រដ្ឋសមាជិកសហភាពអឺរ៉ុប ពាក់ព័ន្ធ ដោយអនុលោមស្របតាមបទប្បញ្ញត្តិទាំងអស់នោះ នឹងកើនឡើងដល់ក្រុមហ៊ុនអាកាសចរណ៍ទាំងអស់ របស់សហភាព។

៣- សម្រាប់គោលបំណងកថាខណ្ឌទី២នៃមាត្រានេះ ភាពខុសគ្នានៃការបកស្រាយណាមួយ ត្រូវដោះស្រាយ ជាមុនសិន តាមរយៈការពិគ្រោះយោបល់រវាងរដ្ឋភាគីពាក់ព័ន្ធ មុននឹងពិគ្រោះយោបល់ជាមួយគណៈកម្មាធិការ ចម្រុះ។ ប្រសិនបើបញ្ហាមិនត្រូវបានដោះស្រាយតាមរយៈគណៈកម្មាធិការចម្រុះនោះទេ ករណីនេះអាចត្រូវបាន បញ្ជូនទៅយន្តការដោះស្រាយវិវាទដែលមានចែងក្នុងមាត្រា២៥។

៤- សិទ្ធិហោះហើរបន្ថែមណាមួយដែលអាចត្រូវបានផ្តល់ទៅឱ្យរដ្ឋសមាជិកសហភាពអឺរ៉ុបមួយដោយរដ្ឋសមាជិក អាស៊ានមួយ ឬត្រូវបានផ្តល់ទៅឱ្យរដ្ឋសមាជិកអាស៊ានមួយដោយរដ្ឋសមាជិកសហភាពអឺរ៉ុបមួយ ត្រូវយោងតាម កិច្ចព្រមព្រៀងនេះ និងមិនមានការរើសអើងរវាងក្រុមហ៊ុនអាកាសចរណ៍នានារបស់សហភាព បន្ទាប់ពីកាល បរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ។ ការរៀបចំទាំងនេះ ត្រូវជូនដំណឹងទៅកាន់គណៈកម្មាធិការ ចម្រុះ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៥- គណៈកម្មាធិការចម្រុះត្រូវបង្កើតនិងរក្សាបច្ចុប្បន្នភាពនូវបញ្ជីព័ត៌មាននៃបទប្បញ្ញត្តិនិងការរៀបចំនានាស្ដីពីសិទ្ធិហោះហើរដែលមានចែងក្នុងកថាខណ្ឌទី២និងកថាខណ្ឌទី៤នៃមាត្រានេះ។

៦- ប្រសិនបើរដ្ឋភាគីក្លាយជាភាគីនៃកិច្ចព្រមព្រៀងពហុភាគី ឬយល់ព្រមលើសេចក្ដីសម្រេចដែលបានអនុម័តដោយអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិឬអង្គការអន្តរជាតិដទៃទៀត ដែលដោះស្រាយបញ្ហានានាគ្របដណ្ដប់ដោយកិច្ចព្រមព្រៀងនេះ រដ្ឋភាគីត្រូវពិគ្រោះយោបល់នៅក្នុងគណៈកម្មាធិការចម្រុះស្របតាមមាត្រា២៣ ដើម្បីកំណត់ថា កិច្ចព្រមព្រៀងនេះ គួរត្រូវបានកែសម្រួលដើម្បីគិតដល់ការអភិវឌ្ឍផងដែរ។

៧- គ្មានបទប្បញ្ញត្តិណាមួយចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវប៉ះពាល់ដល់សុពលភាពនិងការអនុវត្តកិច្ចព្រមព្រៀងដែលមានស្រាប់ និងកិច្ចព្រមព្រៀងនាពេលអនាគតរវាងប្រទេសជាសមាជិកសហភាពអឺរ៉ុបនិងប្រទេសជាសមាជិកអាស៊ាន ទាក់ទងនឹងដែនដីដែលស្ថិតនៅក្រោមអធិបតេយ្យភាពរៀងៗខ្លួន ដែលមិនត្រូវបានគ្របដណ្ដប់ក្នុងនិយមន័យ «ដែនដី» ក្នុងមាត្រា២នោះទេ។

## មាត្រា២៧
## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងនេះ ត្រូវបង្កើតជាផ្នែកសំខាន់នៃកិច្ចព្រមព្រៀងនេះ។ រាល់វិសោធនកម្មនានាចំពោះឧបសម្ព័ន្ធ ត្រូវធ្វើឡើងស្របតាមមាត្រា២៨។

## មាត្រា២៨
## វិសោធនកម្ម

ការធ្វើវិសោធនកម្មណាមួយនៃកិច្ចព្រមព្រៀងនេះ អាចត្រូវបានព្រមព្រៀងគ្នាដោយរដ្ឋភាគី ស្របតាមការពិគ្រោះយោបល់ដែលធ្វើឡើងអនុលោមស្របតាមមាត្រា២៣។ ការធ្វើវិសោធនកម្មនេះ ត្រូវចូលជាធរមានស្របតាមនីតិវិធីដែលមានចែងក្នុងមាត្រា៣៣។

## មាត្រា២៩
## ការបញ្ចប់

១- កិច្ចព្រមព្រៀងនេះ អាចត្រូវបានបញ្ចប់ដោយសហភាពនិងរដ្ឋសមាជិករបស់ខ្លួន ឬដោយរដ្ឋសមាជិកអាស៊ានដែលបានយល់ព្រមធ្វើសកម្មភាពរួមគ្នា ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អគ្គលេខាធិការនៃក្រុមប្រឹក្សាសហភាពអឺរ៉ុបឬអគ្គលេខាធិការអាស៊ាន ខណៈពេលដែលករណីនេះ អាចកើតមានឡើង។ ការបញ្ចប់នេះ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ត្រូវចូលជាធរមានក្នុងរយៈពេលដប់ប្រាំបី(១៨)ខែ បន្ទាប់ពីកាលបរិច្ឆេទទទួលបានការជូនដំណឹងដោយអគ្គលេខាធិការអាស៊ានឬដោយអគ្គលេខាធិការក្រុមប្រឹក្សាសហភាពអឺរ៉ុប ខណៈពេលដែលករណីនេះអាចកើតមានឡើង។

២- ក្នុងករណីដែលរដ្ឋសមាជិកមួយដកខ្លួនចេញពីសហភាពឬពីអាស៊ាន កិច្ចព្រមព្រៀងនេះឈប់អនុវត្តចំពោះរដ្ឋនោះ ដោយយោងតាមមាត្រា៣២ដែលមានសុពលភាពចាប់ពីកាលបរិច្ឆេទនៃការដកខ្លួនចេញពីសហភាពឬពីអាស៊ាន ចាប់ផ្តើមមានប្រសិទ្ធភាពខណៈពេលដែលករណីនេះអាចកើតមានឡើង។

**មាត្រា៣០**

**ការចុះបញ្ជីកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះនិងការធ្វើវិសោធនកម្មណាមួយ ត្រូវបានចុះបញ្ជីនៅពេលចូលជាធរមានជាមួយអង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយអគ្គលេខាធិការអាស៊ាន។

**មាត្រា៣១**

**ការចូលជាសមាជិកថ្មីរបស់រដ្ឋសមាជិកសហភាពអឺរ៉ុប**

១- កិច្ចព្រមព្រៀងនេះ ត្រូវបើកចំហសម្រាប់ការចូលជាសមាជិករបស់រដ្ឋដែលបានក្លាយជារដ្ឋសមាជិកសហភាព បន្ទាប់ពីកាលបរិច្ឆេទចុះហត្ថលេខានៃកិច្ចព្រមព្រៀងនេះ។

២- ការចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះរបស់រដ្ឋសមាជិកសហភាពអឺរ៉ុបមួយ ត្រូវអនុវត្តដោយការតម្កល់លិខិតូបករណ៍ចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះជាមួយអគ្គលេខាធិការក្រុមប្រឹក្សាសហភាពអឺរ៉ុប ដែលត្រូវជូនដំណឹងដល់រដ្ឋភាគីនិងអគ្គលេខាធិការអាស៊ានអំពីការតម្កល់លិខិតូបករណ៍ចូលជាសមាជិកនិងកាលបរិច្ឆេទ។ ការចូលជាសមាជិក ត្រូវចូលជាធរមានចាប់ពី១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដាក់តម្កល់លិខិតូបករណ៍ចូលជាសមាជិក។

៣- កថាខណ្ឌទី១ កថាខណ្ឌទី២ កថាខណ្ឌទី៣និងកថាខណ្ឌទី៧នៃមាត្រា២៦ ត្រូវអនុវត្តតាមការកែសម្រួលឱ្យស្របនឹងស្ថានភាពនៃកិច្ចព្រមព្រៀងដែលមានស្រាប់ និងការរៀបចំកិច្ចព្រមព្រៀងដែលបានធ្វើឡើងនៅពេលមានរដ្ឋសមាជិកសហភាពអឺរ៉ុបមួយ ក្នុងកិច្ចព្រមព្រៀងនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## មាត្រា៣២
## ការអនុវត្តនៃដែនដី

មួយវិញទៀត កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះដែនដីនៃសហភាព ហើយម្យ៉ាងវិញទៀតចំពោះដែនដីនៃបណ្តារដ្ឋសមាជិកអាស៊ាន ដូចបានបញ្ជាក់ក្នុងនិយមន័យកថាខណ្ឌទី១ចំណុច(ឃ)នៃមាត្រា២។

## មាត្រា៣៣
## ការចូលជាធរមាន

១- កិច្ចព្រមព្រៀងនេះ ត្រូវផ្តល់សច្ចាប័ន ទទួលស្គាល់ ឬយល់ព្រមស្របតាមនីតិវិធីរៀងៗខ្លួនរបស់រដ្ឋភាគី។

២- អគ្គលេខាធិការអាស៊ាន ត្រូវផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អគ្គលេខាធិការក្រុមប្រឹក្សាសហភាពអឺរ៉ុបដោយបញ្ជាក់ថា នីតិវិធីរៀងៗខ្លួនសម្រាប់ការផ្តល់សច្ចាប័ន ការទទួលស្គាល់ ឬការយល់ព្រមពីបណ្តារដ្ឋសមាជិកអាស៊ានត្រូវបានបញ្ចប់។ អគ្គលេខាធិការក្រុមប្រឹក្សាសហភាពអឺរ៉ុប ត្រូវផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អគ្គលេខាធិការអាស៊ាន ដោយបញ្ជាក់ថា នីតិវិធីរៀងៗខ្លួនសម្រាប់ការផ្តល់សច្ចាប័ន ការទទួលស្គាល់ ឬការយល់ព្រមពីសហភាពនិងបណ្តារដ្ឋសមាជិករបស់ខ្លួនត្រូវបានបញ្ចប់។

៣- យោងតាមមាត្រាឈ កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមាន៣០(សាមសិប)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលមានចែងក្នុងកថាខណ្ឌទី២នៃមាត្រានេះ។

## មាត្រា៣៤
## អត្ថបទដើម

១- កិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងជាអត្ថបទដើមចំនួនពីរ ជាភាសាប៊ុលហ្គារី ក្រូអាត ឆែក ដាណឺម៉ាក ហូឡង់ អង់គ្លេស អេស្តូនី ហ្វាំងឡង់ បារាំង អាល្លឺម៉ង់ ក្រិក ហុងគ្រី អៀរឡង់ អ៊ីតាលី ឡាតវី លីទុយអានី ម៉ាល់ត៍ ប៉ូឡូញ ព័រទុយហ្គាល់ រូម៉ានី ស្លូវ៉ាគី ស្លូវេនី អេស្ប៉ាញ៉ុល និងស៊ុយអែត ដែលអត្ថបទនីមួយៗមានភាពត្រឹមត្រូវស្មើគ្នា។

២- ក្នុងករណីមានភាពខុសគ្នារវាងការបកប្រែភាសា គណៈកម្មាធិការចម្រុះត្រូវសម្រេចលើភាសានៃអត្ថបទដើមដើម្បីប្រើប្រាស់។

៣- អត្ថបទដើមណាមួយនៃកិច្ចព្រមព្រៀង រួមទាំងការធ្វើវិសោធនកម្មណាមួយ ត្រូវតម្កល់នៅអគ្គលេខាធិការអាស៊ាន ហើយអគ្គលេខាធិការអាស៊ានត្រូវផ្តល់លិខិតបញ្ជាក់ច្បាប់ចម្លងនោះភ្លាមៗទៅកាន់រដ្ឋសមាជិកអាស៊ាននីមួយៗ។ អត្ថបទដើមផ្សេងទៀតនៃកិច្ចព្រមព្រៀង រួមទាំងការធ្វើវិសោធនកម្មណាមួយ ត្រូវតម្កល់នៅអគ្គលេខាធិការក្រុមប្រឹក្សាសហភាពអឺរ៉ុប។

ដើម្បីជាសក្ខីភាព អ្នកដែលចុះហត្ថលេខាខាងក្រោម ដោយទទួលបានសិទ្ធិត្រឹមត្រូវស្របច្បាប់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ជាពីរច្បាប់ ធ្វើនៅក្រុងបាលី សាធារណរដ្ឋឥណ្ឌូណេស៊ី នាថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២។

**តំណាងរដ្ឋាភិបាលនៃព្រុយណេដារូសាឡឹម**

................................................

**ម៉ូហាមម៉ាដ ណាហ្សរី ម៉ូហាម៉ាដ យូសូហ្ស**

**លេខាធិការអចិន្ត្រៃយ៍**

ក្រសួងដឹកជញ្ជូននិងទំនាក់ទំនងព័ត៌មាន

**តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**

................................................

**ម៉ៅ ហាវណ្ណាល់**

**រដ្ឋមន្ត្រី**

ទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូណេស៊ី**

................................................

**នូវៀ រីយ៉ានតូ រ៉ាហាដជោ**

**អគ្គលេខាធិការ**

ក្រសួងដឹកជញ្ជូន



**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

.................................................

**ធៀងសាទាត ស៊ីផាន់ជន**

**រដ្ឋមន្ត្រី**

ក្រសួងសាធារណការនិងដឹកជញ្ជូន

**តំណាងរដ្ឋាភិបាលម៉ាឡេស៊ី**

.................................................

**អ៊ីសាម អ៊ីសាក**

**អគ្គលេខាធិការ**

ក្រសួងដឹកជញ្ជូន

**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា**

.................................................

**ទីន ខាន់**

**លេខាធិការអចិន្ត្រៃយ៍**

ក្រសួងដឹកជញ្ជូននិងគមនាគមន៍

**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋហ្វីលីពីន**

.................................................

**ជេម ជេ. បូទីស្តា**

**រដ្ឋមន្ត្រី**

ក្រសួងដឹកជញ្ជូន

**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសិង្ហបុរី**

.................................................

**ឡូ ម៉ាយ សេង**

**លេខាធិការអចិន្ត្រៃយ៍**

ក្រសួងដឹកជញ្ជូន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ**

.................................................................

**អានីរ៉ាត រតនាសាតេ**

**អនុរដ្ឋមន្ត្រី**

ក្រសួងដឹកជញ្ជូន

**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

.................................................................

**ឡេ អាញ់ ទាន់**

**អនុរដ្ឋមន្ត្រី**

ក្រសួងដឹកជញ្ជូន

**តំណាងសហភាពអឺរ៉ុប**
**តំណាងព្រះរាជាណាចក្របែលហ្ស៊ិក**
**តំណាងសាធារណរដ្ឋប៊ុលហ្គារី**
**តំណាងសាធារណរដ្ឋឆែក**
**តំណាងព្រះរាជាណាចក្រដាណឺម៉ាក**
**តំណាងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**
**តំណាងសាធារណរដ្ឋអេស្តូនី**
**តំណាងប្រទេសអៀរឡង់**
**តំណាងសាធារណរដ្ឋហេឡេនិច**
**តំណាងព្រះរាជាណាចក្រអេស្ប៉ាញ**
**តំណាងសាធារណរដ្ឋបារាំង**
**តំណាងសាធារណរដ្ឋក្រូអាស៊ី**
**តំណាងសាធារណរដ្ឋអ៊ីតាលី**
**តំណាងសាធារណរដ្ឋស៊ីប**
**តំណាងសាធារណរដ្ឋឡេតូនី**
**តំណាងសាធារណរដ្ឋលីទុយអានី**
**តំណាងព្រះរាជាណាចក្រលុចសំបួ**
**តំណាងប្រទេសហុងគ្រី**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**តំណាងសាធារណរដ្ឋម៉ាល់តា**
**តំណាងព្រះរាជាណាចក្រហូឡង់**
**តំណាងសាធារណរដ្ឋប៉ូឡូញ**
**តំណាងសាធារណរដ្ឋព័រទុយហ្កាល់**
**តំណាងប្រទេសរូម៉ានី**
**តំណាងសាធារណរដ្ឋស្លូវេនី**
**តំណាងសាធារណរដ្ឋស្លូវ៉ាគី**
**តំណាងសាធារណរដ្ឋហ្វាំងឡង់ និង**
**តំណាងព្រះរាជាណាចក្រស៊ុយអែត**

**ឧបសម្ព័ន្ធ**
**មាត្រា ក**
**ការបិតាគផ្លូវហោះហើរ**

